សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economique
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាលរាជធានី-ខេត្ត

ស្រាវជ្រាវ ពីថ្ងៃទី ០៣ ខែ មេសា ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **ហេង សៀង**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **សឿន សោភ័ណ**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី **១០** (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៣
ឆ្នាំសរសេរសារណា ២០១៧

# អារម្ភកថា

ក្រោយការសិក្សានូវ ជំនាញរដ្ឋបាលសារណៈរយៈពេល ៤ឆ្នាំមក, ខ្ញុំសង្កេតឃើញ វិស័យរដ្ឋបាលគឺ ជាវិស័យមួយសំខាន់ក្នុងចំណោម វិស័យផ្សេងៗ។ ដោយហេតុថា វិស័យនេះ គឺជាគន្លងសម្រាប់ក្នុងការគ្រប់គ្រងក្រសួង ស្ថាប័ននានា អោយមានប្រព្រឹត្តិទៅដោយរលូន។ ដូច្នេះហើយ រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា បានចាត់ទុកការធ្វើកំណែទម្រង់រដ្ឋបាលសារធារណៈគឺផ្នែកមួយយ៉ាងសំខាន់ក្នុងបណ្តាលវិស័យនានា។ ជាក់ស្តែង ការការចាប់ផ្តើមបង្កើតអោយមានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ គឺជាចក្ខុវិស័យរបស់ រាជរដ្ឋាភិបាលដើម្បីនាំនាវាកម្ពុជា ឈានឆ្ពោះទៅរកការ ធ្វើសមាហរណកម្មនៃតំបន់អាស៊ានក៏ដូចជាពិភពលោកទាំងមូល។ ដោយអនុលោមទៅតាមស្មារតីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ ដែលចង់បង្កើតអោយមានប្រសិទ្ធិភាពក្នុងការគ្រប់គ្រងដែនដីរដ្ឋ បាលនៃព្រះរាជាណាចក្រកម្ពុជានាឆ្នាំ២០០១ រដ្ឋសភាបានធ្វើការអនុម័តយល់ព្រមលើសេចក្តីព្រាងច្បាប់ស្តីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលបានបង្កើតអោយមានឡើងនូវសមូហភាពមូលដ្ឋាន ដែលជាដែនដីរដ្ឋបាល នៅជិតប្រជាពលរដ្ឋដើម្បីផ្តល់ភាពងាយស្រួលក្នុងការផ្តល់សេវាសាធាណៈ ក៏ដូចជាដឹងច្បាស់ពីសុខទុក្ខរបស់ប្រជាពលរដ្ឋ។ នេះគ្រាន់តែជាការចាប់ផ្តើមនៃការធ្វើរដ្ឋបាលសាធារណៈតែប៉ុណ្ណោះ។ នាឆ្នាំ២០០៨ យើងសង្កេតឃើញថា មានវត្តមានច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជ-ធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលនេះបានបង្ហាញអោយឃើញកាន់តែច្បាស់អំពីឆន្ទៈ រាជ-រដ្ឋាភិបាលក្នុងការកែទម្រង់ សេវាសាធារណៈរបស់រដ្ឋ អោយកាន់តែខិតជិតប្រជាពលរដ្ឋ និងការផ្តល់សេវាប្រកបដោយសក្តិសិទ្ធភាពរួមទាំងធ្វើការអភិវឌ្ឍនូវលិទ្ធិប្រជាធិបតេយ្យទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

ចំពោះស្នាដៃនៃការស្រាវជ្រាវនេះ គឺពុំទាន់មានល្អប្រសើរនៅឡើយទេ។ អាស្រ័យហេតុនេះ សូមមេត្តាអធ្យាស្រ័យនូវ ភាពចន្លោះប្រហោង ទាំងផ្នែកទ្រឹស្តី សកម្មភាពនៃ ការប្រព្រឹត្តិនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់រាជធានី ខេត្ត និងកំហុសអក្ខរាវិរុទ្ធផងដែរ។

ជាចុងក្រោយសូមជូនពរដល់ លោកសាស្ត្រាចារ្យ លោកស្រីសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ មិត្តនិស្សិត ទាំងអស់អោយជួបប្រទះតែសំណាងល្អ សុខភាពល្អ ទទួលបានជោគជ័យគ្រប់ភារកិច្ច ដើម្បីរួមចំណែកគ្នាក្នុងការអភិវឌ្ឍនាវាកម្ពុជាឆ្ពោះទៅភាពរីកចម្រើនជាលំដាប់។

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ហេង សៀង** ជានិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ជំនាន់ទី ១០ សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ៖

❖ លោកឪពុក **សៀង ហេង** និង អ្នកម្តាយ **ឃូ ណៃ** ដែលលោកអ្នកមានគុណទាំងទ្វេ ដែលបានចិញ្ចឹមបីបាច់ទំនុកបម្រុងកូនអោយបានបន្តការសិក្សារហូតដល់ថ្នាក់ឧត្តមសិក្សា។ ទាំងនេះហើយជាគុណដែលមិនអាចកាត់ថ្លៃបាន និងជាស្ពានសម្រាប់ចម្លងជីវិតកូនឆ្ពោះទៅរក ភាពជោគជ័យនាថ្ងៃអនាគត។

❖ លោកសាស្ត្រាចារ្យ បណ្ឌិត **សឿន សោភ័ណ** សាកលវិទ្យាធិការរង និងជាសាស្ត្រាចារ្យណែនាំខ្ញុំបាទក្នុងការសរសេរសារណាបញ្ចប់ឆ្នាំ ដែលលោកបានខិតខំអស់កម្លាំងកាយចិត្តក្នុងណែនាំ និងចង្អុលបង្ហាញពីរបៀបនៃការសរសេរ និងការស្វែងរកឯកសារ។

❖ **សមាគមសិស្ស-និស្សិតអាហារូបករណ៍ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានី ហ៊ុន សែន** ដែលមាន **ឯកឧត្តម បណ្ឌិត ហ៊ុន ម៉ាណែត** ជាប្រធានដែលបានផ្តល់អាហារូបករណ៍សិក្សាថ្នាក់បរិញ្ញាបត្រដល់រូបខ្ញុំបាទដើម្បីទទួលបានចំណេះដឹងក្នុងការកសាងខ្លួនជាទំពាំងស្នងឬស្សី នាថ្ងៃអនាគត ។

❖ លោកសាស្ត្រាចារ្យ លោកស្រីសាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូនៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានលះបង់ទាំងកម្លាំងកាយ និងកម្លាំងចិត្តក្នុងបណ្តុះបណ្តាលថ្នាលយុវជនជំនាន់ក្រោយដែលជាទំពាំងស្នងឬស្សី អោយមានទាំង ចំណេះដឹង និងចំណេះធ្វើ ។

❖ លោកគ្រូ អ្នកគ្រូ ដែលបានបង្រៀនខ្ញុំបាទតាំងពីតូចរហូតដល់ បញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិជាគុណ ដែលមិនអាចកាត់ថ្លៃបានដោយ លោកគ្រូអ្នកគ្រូបានបណ្តុះបណ្តាលនូវចំណេះដឹងដ៏សម្បូរបែបសម្រាប់ជាស្ពានឈានសម្រាប់ការសិក្សាថ្នាក់ឧត្តមសិក្សា។

❖ ញាតិមិត្តជិតឆ្ងាយ ទាំងអស់ដែលបានផ្តល់កម្លាំងចិត្ត និងការចែករំលែកបទពិសោធន៍នានាដែលមានតម្លៃសម្រាប់ជាចង្កៀងបំភ្លឺផ្លូវដល់ខ្ញុំបាទក្នុងការតស៊ូជំនះនូវឧបសគ្គ។

# មាតិកា

ទំព័រ

**បញ្ជីតារាង** ..................................................................................... iii

**សេចក្តីផ្តើម** ..................................................................................... ១

**ជំពូកទី ១ ប្រវត្តិរដ្ឋបាលនៅកម្ពុជា** ..................................................................................... ៤

១.១. និយមន័យរដ្ឋបាលសាធារណៈ ..................................................................................... ៤

១.២. រដ្ឋបាលមុនអាណានិគមនិយមបារាំង ..................................................................................... ៤

១.៣. រដ្ឋបាលក្រោមអាណានិគមនិយមបារាំង ..................................................................................... ៥

១.៤. រដ្ឋបាលសម័យព្រះរាជាណាចក្រកម្ពុជាទី២ ..................................................................................... ៥

១.៤.១. រដ្ឋបាលមុនឆ្នាំ ២០០៨ ..................................................................................... ៥

១.៤.២. រដ្ឋបាលឆ្នាំ ២០០៨ ..................................................................................... ៦

**ជំពូកទី ២ ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត** ..................................................................................... ៨

២.១. រចនាសម្ព័ន្ធរាជធានី ខេត្ត ..................................................................................... ៨

២.២. ក្រុមប្រឹក្សារាជធានី ខេត្ត ..................................................................................... ៩

២.៣. គណៈអភិបាលរាជធានី ខេត្ត ..................................................................................... ១៣

២.៣.១. អភិបាល ..................................................................................... ១៥

២.៣.២. អភិបាលរង ..................................................................................... ១៧

២.៤. ទំនាក់ទំនងរវាងក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្ត ..................................................................................... ១៩

២.៥. ទំនាក់ទំនងរវាងរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ..................................................................................... ២០

២.៦. ទំនាក់ទំនងរវាងរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលឃុំ សង្កាត់ ..................................................................................... ២១

**ជំពូកទី ៣ ដំណើរការអនុវត្តកិច្ចរដ្ឋបាល** ..................................................................................... ២៣

៣.១. កិច្ចប្រជុំ ..................................................................................... ២៣

៣.១.១. កិច្ចប្រជុំក្រុមប្រឹក្សា ..................................................................................... ២៤

៣.១.២. កិច្ចប្រជុំគណៈអភិបាល ..................................................................................... ២៦

៣.១.៣. កិច្ចប្រជុំគណៈកម្មាធិការ ..................................................................................... ២៦

៣.១.៤. កិច្ចប្រជុំអន្តរទីចាត់ការ ..................................................................................... ២៨

៣.១.៥. កិច្ចប្រជុំផ្ទៃក្នុងទីចាត់ការ ..................................................................................... ២៩

៣.២. លិខិតបទដ្ឋានគតិយុត្ត ........................................................................ ២៩
៣.២.១. ដីកា ........................................................................................ ២៩
៣.២.២. សេចក្តីសម្រេច ............................................................................ ៣១
៣.២.៣. សេចក្តីណែនាំ.............................................................................. ៣២
៣.៣. ការផ្ទេរសិទ្ធិ....................................................................................... ៣២
៣.៣.១. ការផ្ទេរសិទ្ធិដោយស្វ័យប្រវត្តិធ្វើជាអធិបតីអង្គប្រជុំក្រុមប្រឹក្សា............ ៣២
៣.៣.២. ការផ្ទេរសិទ្ធិរបស់ប្រធានគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា.......... ៣៣
៣.៣.៣. ការផ្ទេរសិទ្ធិរបស់អភិបាល ............................................................ ៣៣
៣.៤. ការប្រគល់សិទ្ធិចុះហត្ថលេខា ................................................................ ៣៣
៣.៥. ការផ្តល់សេវាសាធារណៈនៅរាជធានី ខេត្ត............................................ ៣៤
៣.៦. បញ្ហាប្រឈម.......................................................................................... ៣៧
៣.៧. ដំណោះស្រាយ ....................................................................................... ៣៧
**សេចក្តីសន្និដ្ឋាន** ........................................................................................ ៣៩
**អនុសាសន៍**.................................................................................................. ៤០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីតារាង

**ទំព័រ**

តារាងទី១៖ ផែនទីរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជា មុនឆ្នាំ២០០៨............................. ៥

តារាងទី២៖ ឈ្មោះខេត្ត ក្រុង នៃព្រះរាជាណាចក្រកម្ពុជា មុនឆ្នាំ២០០៨......................... ៦

តារាងទី៣៖ រចនាសម្ព័ន្ធរដ្ឋបាលរាជធានីភ្នំពេញ ......................................................... ៨

តារាងទី៤៖ រចនាសម្ព័ន្ធរដ្ឋបាលខេត្ត ......................................................................... ៩

តារាងទី៥៖ គំរូតម្លៃសេវារដ្ឋបាលថ្នាក់រាជធានី ខេត្ត.................................................. ៣៥

តារាងទី៦៖ តម្លៃសេវារដ្ឋបាលរាជធានីភ្នំពេញ......................................................... ៣៦

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសនីមួយៗអាចនឹងអភិវឌ្ឍជឿនលឿនទៅបាន គឺអាស្រ័យដោយមានការរីកចម្រើនលូតលាស់ទាំងវិស័យសេដ្ឋកិច្ច និងរដ្ឋបាល។ ការរៀបចំអោយមាន ការអភិវឌ្ឍសេដ្ឋកិច្ចទៅបានគឺអាស្រ័យលើការរៀបចំផែនការ និងបែបផែន ដែលធ្វើអោយសេដ្ឋកិច្ចលូតលាស់បាន គឺជារបៀបវារៈរបស់អ្នកនយោបាយ តែអ្នកអនុវត្ត គឺជាប្រជាពលរដ្ឋសាមញ្ញ និងមន្ត្រីរដ្ឋបាល។

នៅក្នុងកិច្ចការរដ្ឋបាលសាធារណៈ ថ្វីត្បិតតែវាគ្មានទំនាក់ទំនងដោយផ្ទាល់ទៅនឹងការរីកលូតនៃវិស័យសេដ្ឋកិច្ចយ៉ាងណាក៏ដោយ តែវាជាកម្លាំងចលករយ៉ាងមានប្រសិទ្ធិភាព ក្នុងការកំណត់គោលបំណងដែលបានកំណត់ដោយគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ជាការពិតណាស់ រាជរដ្ឋាភិ-បាលនៃបណ្តាលប្រទេសនានាលើសកលលោកតែងតែសម្របសម្រួលកែប្រែជាបន្តបន្ទាប់នូវ វិស័យរដ្ឋបាលរបស់ខ្លួន អោយមានភាពសាមញ្ញ និងការផ្តល់នូវសេវាប្រកបដោយប្រសិទ្ធិភាពខ្ពស់ដើម្បីបំពេញតម្រូវការជូនប្រជាពលរដ្ឋរបស់ខ្លួន។ រដ្ឋបាលមួយដែលមាន ភាពសាមញ្ញ តម្លាភាព និងប្រសិទ្ធិភាព នឹងដឹកនាំសង្គមមួយអោយមាន ការរីកចម្រើនលូតលាស់ និងអាចសម្រេចនូវលទ្ធផល ដែលបានកំណត់ទុកក្នុងរបៀបវារៈនយោបាយរបស់ជាតិ។ ពោលគឺរដ្ឋបាលចំណាយតិច តែប្រសិទ្ធិភាពការងារខ្ពស់ ក្នុងការផ្តល់សេវារដ្ឋបាលនានាដែលតម្រូវការ ប្រជាពលរដ្ឋបានយ៉ាងល្អ នោះវាជួយជំរុញដល់ការអភិវឌ្ឍវិស័យសេដ្ឋកិច្ចផងដែរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា បានធ្វើកំណែទម្រង់នូវប្រព័ន្ធរដ្ឋបាលដោយបានធ្វើប្រតិភូកម្មនូវមុខងារជាច្រើន និងបន្តបន្ទាប់ដល់រដ្ឋបាលថ្នាក់រាជធានី ខេត្ត ដើម្បីអាចមានសមត្ថកិច្ចក្នុងការដោះស្រាយ និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាព តែយើងក៏សង្កេតឃើញថា ការអនុវត្តកិច្ចការទាំងនេះរបស់រដ្ឋបាលរាជធានី ខេត្តហាក់ដូចមានៅមានភាពចន្លោះប្រហោង ទើបមានមតិមួយចំនួនលើកឡើងថា ៖

- តើការអនុវត្តមុខងារ និងតួនាទីរបស់ក្រុមប្រឹក្សាថ្នាក់រាជធានី ខេត្តមានអ្វីខ្លះ ហើយនៅក្នុងមានទំនាក់ទំនងអ្វីខ្លះនៅក្នុង ការអនុវត្តមុខងារ របស់ក្រុមប្រឹក្សា គណៈអភិបាល ក៏ដូចជា អង្គភាពពាក់ព័ន្ធ?
- តើការអនុវត្តមុខងារទាំងនេះ មានបញ្ហាប្រឈមអ្វីខ្លះ?
- តើរាជរដ្ឋាភិបាល បានដាក់ចេញនូវវិធីសាស្ត្របែបណាខ្លះដើម្បីដោះស្រាយនូវបញ្ហាប្រឈមទាំងអស់នោះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ មានគោលបំណងក្នុងការចូលរួមចែករំលែកនូវចំណេះដឹងទាក់ទងនឹងរដ្ឋបាល រាជធានី ខេត្ត ដែលរួមមានដំណើរការអនុវត្តការងារកិច្ចការរដ្ឋបាល ទំនាក់ទំនងរវាងរដ្ឋបាលរាជធានី ខេត្ត និងអង្គភាពចំណុះ ក៏ដូចជាអង្គភាពពាក់ព័ន្ធ ។ គោលបំណងនៃសារណានេះ ផ្តោតសំខាន់ទៅលើចំណុចមួយចំនួនដូចជា ៖

- សិក្សាអំពីដំណើរការទូទៅនៃការអនុវត្តកិច្ចការរដ្ឋបាលថ្នាក់រាជធានី ខេត្ត
- សិក្សាអំពីតួនាទី ភារកិច្ច និងមុខងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី ខេត្ត
- សិក្សាអំពីទំនាក់ទំនងផ្សេងៗរបស់រដ្ឋបាលរាជធានី ខេត្ត
- សិក្សាអំពីបញ្ហាប្រឈម និងដំណោះស្រាយរបស់រាជរដ្ឋាភិបាល

ការស្រាវជ្រាវនេះដែរ ផ្តោតទៅលើការវិភាគការគ្រប់គ្រងរដ្ឋបាលថ្នាក់រាជធានី ខេត្ត និងយុទ្ធសាស្ត្រ ពាក់ព័ន្ធដើម្បីស្វែងរកចំណុចខ្វះខាតមួយចំនួន ដំណោះស្រាយមួយចំនួនរបស់ រាជរដ្ឋាភិ-បាល រួចធ្វើការសន្និដ្ឋាន និងចូលរួមផ្តល់អនុសាសន៍មួយចំនួនផងដែរក្នុងជានិស្សិត។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះត្រូវបានកំណត់អំពី វិសាលភាពដែលយោងទៅតាមកម្រិត និងរយៈពេល នៃការស្រាវជ្រាវប្រធានបទ "ការគ្រប់គ្រងរដ្ឋបាលរាជធានី~ខេត្ត" ។ ការស្រាវជ្រាវនេះ ផ្តោតទៅលើការអនុវត្តមុខងារ និងតួនាទីរបស់ក្រុមប្រឹក្សា និងគណៈអភិបាលខេត្ត ទំនាក់ទំនងរវាងក្រុមប្រឹក្សា និងគណៈអភិបាលខេត្ត បញ្ហាប្រឈមនៃការអនុវត្តមុខងារ និងគោលនយោបាយ ក៏ដូចជាដែលយុទ្ធសាស្ត្រដែលចេញដោយរាជរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនេះ។ ការស្រាវជ្រាវទៅលើប្រធានបទ "ការគ្រប់គ្រងរដ្ឋបាលរាជធានី~ខេត្ត" ស្ថិតក្នុងរយៈពេលជាក់លាក់មួយគឺចាប់ពី ឆ្នាំ ២០០៨ រហូតដល់ឆ្នាំ២០១៦ ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់ទៅលើប្រធានបទនេះ នឹងចូលរួមវិភាគទានដ៏សំខាន់ក្នុង ការអភិវឌ្ឍចំណេះដឹងរបស់មិត្តនិស្សិតពាក់ព័ន្ធ និងរដ្ឋបាលរាជធានី ខេត្ត ស្វែងយល់ពីការធ្វើវិមជ្ឈការ និង ការធ្វើវិសមជ្ឈការរបស់រាជរដ្ឋាភិបាលក្នុងការធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវទៅលើប្រធានបទ "ការគ្រប់គ្រងរដ្ឋបាលរាជធានី~ខេត្ត" នេះបានផ្អែកទៅលើជាការពិតវិធីសាស្ត្រនៃការស្រាវជ្រាវឯកសារ គឺជាករស្វែងរកព័ត៌មានដែលពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋ

បាល ដូចជា ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ , ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលជាអត្ថបទច្បាប់គោល ហើយបានកំណត់អំពីតួនាទីភារកិច្ច មុខងាររបស់រដ្ឋបាលរាជធានី ខេត្ត ហើយក្នុងនេះក៏មានសៀវភៅណែនាំកិច្ចការរដ្ឋបាលរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបានបោះពុម្ពផ្សាយដើម្បីជួយពង្រឹងដល់ការអនុវត្តកិច្ចការរដ្ឋបាល របស់រាជធានី ខេត្ត។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ ត្រូវបានបែងចែកដូចខាងក្រោម៖

សេចក្តីផ្តើម ៖ បង្ហាញអំពីលំនាំបញ្ហា ចំណោទបញ្ហា គោលបំណង ទំហំដែនកំណត់ សារសំខាន់នៃការស្រាវជ្រាវ វិធីសាស្ត្រស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការសរសេរសារណា។

ជំពូកទី១ ៖ ប្រវត្តិរដ្ឋបាលនៅកម្ពុជា ក្នុងជំពូកនេះបង្ហាញលក្ខណៈទូទៅនៃ រដ្ឋបាលសាធាណៈ មានដូចជានិយមន័យរដ្ឋបាលសាធារណៈ ប្រវត្តិនៃរដ្ឋបាលសាធារណៈរបស់កម្ពុជា តាំងពីសម័យមុនអាណានិគមនិយមបារាំង សម័យអាណានិគមនិយមបារាំង សម័យព្រះរាជាណាចក្រកម្ពុជាទី២ មុនឆ្នាំ ២០០៨ និងក្រោយឆ្នាំ ២០០៨។

ជំពូកទី២ ៖ ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត សិក្សាពីរចនាសម្ព័ន្ធរបស់រដ្ឋបាលរាជធានី ខេត្ត តួនាទីភារកិច្ច និងមុខងាររបស់ក្រុមប្រឹក្សារាជធានី ខេត្ត គណៈអភិបាលរាជធានី ខេត្តទំនាក់ទំនងរវាងរដ្ឋបាលរាជធានី ខេត្ត នឹងរដ្ឋបាលថ្នាក់ជាតិ ក្រុង ស្រុក ខណ្ឌ ឃុំសង្កាត់។

ជំពូកទី៣ ៖ ដំណើរការអនុវត្តការងាររដ្ឋបាល បង្ហាញអំពីកិច្ចការរដ្ឋបាលនានារបស់រដ្ឋបាលរាជ-ធានី ខេត្តដូចជាកិច្ចប្រជុំ លិខិតបទដ្ឋានគតិយុត្តិរបស់រដ្ឋបាលរាជធានី ខេត្ត ការផ្ទេរសិទ្ធិ ការផ្តល់សេវាសារធារណៈ ការប្រគល់សិទ្ធិចុះហត្ថលេខា បញ្ហាប្រឈម និងដំណោះស្រាយ។

សេចក្តីសន្និដ្ឋាន

អនុសាសន៍

ឯកសារយោង

ឧបសម្ព័ន្ធ

# ជំពូកទី ១

# ប្រវត្តិរដ្ឋបាលនៅកម្ពុជា

# ជំពូកទី ១
# ប្រវត្តិរដ្ឋបាលនៅកម្ពុជា

## ១.១. និយមន័យរដ្ឋបាលសាធារណៈ

រដ្ឋបាលសាធារណៈ គឺមកពីថា រដ្ឋ ជាពាក្យបាលីប្រែថានគរ ប្រទេស ដែន[1] , បាល ជាពាក្យបាលីសំស្ក្រឹត ប្រែថា គ្រប់គ្រងថែរក្សា ការពារ ផ្គត់ផ្គង់ បីបាច់មើលការទទួលខុសត្រូវ[2]។ សាធារណៈ គឺជាពាក្យបាលីសំស្ក្រឹត ដែលបានន័យថាប្រើប្រាស់បានទាំងអស់គ្នា[3]។ រួមសេចក្តីមក មានន័យថា ការគ្រប់គ្រងថែរក្សារដ្ឋ ដូចជាកិច្ចការគ្រប់គ្រង កិច្ចការទំនាក់ទំនង ដែលប្រជាពលរដ្ឋរស់នៅក្នុងប្រទេសនេះ អាចទទួលបាននូវសេវាទាំងនេះ ដោយមិនប្រកាន់ឋានៈ ទ្រព្យធន។

តាមទស្សនវិទូ Raul P. De Guzment: ទីណាមានរដ្ឋាភិបាល ទីនោះមានរដ្ឋបាលសាធារណៈ មានន័យថា រដ្ឋបាល សាធារណៈ គឺជាកិច្ចសហប្រតិបត្តិការរវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល ដើម្បីសម្រេចគោលដៅអ្វី មួយ ក្នុងការបម្រើប្រយោជន៍សាធារណៈ[4] ។

រដ្ឋបាលសាធាណៈ គឺជាស្ថាប័នទាំងឡាយណាដែលមាននៅក្នុងរដ្ឋនីមួយៗ មានតួនាទី បម្រើផលប្រយោជន៍សាធារណៈ ឬ ប្រយោជន៍ទូទៅ ហើយជាទូទៅស្ថិតនៅ ក្រោមអំណាចនីតិប្រតិបត្តិ។[5]

## ១.២. រដ្ឋបាលមុនអាណានិគមនិយមបារាំង

ព្រះរាជាណាចក្រកម្ពុជា មុនសម័យអាណានិគមនិយមបារាំងជា ប្រទេសដែលប្រកាន់យករបប រាជានិយម ដែលមានព្រះមហាក្សត្រសោយរាជ្យ ហើយអំណាចទាំងអស់ប្រមូលផ្តុំលើទ្រង់ ដែលក្នុងនេះ មានអំណាចនយោបាយ អំណាចរដ្ឋបាល និងអំណាចតុលាការ។ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា គឺយកចេញពីគម្ពីរវេទ និងទំនៀមទម្លាប់មកប្រតិបត្តិ។

ព្រះមហាក្សត្រជាធម្មតា ទ្រង់ធ្វើសវនាការកិច្ចការរដ្ឋបាល ២ដង ក្នុងមួយថ្ងៃ[6]។ ទ្រង់ជាអធិបតី នៃ សេនាបតីសភា (ការប្រជុំគណៈរដ្ឋមន្ត្រី) ដើម្បីដោះស្រាយរាល់កិច្ចការ និងបញ្ហាជាតិ។

---

[1] វចនានុក្រមសម្តេចព្រះសង្ឃរាជជួន ណាត រដ្ឋ

[2] វចនានុក្រមសម្តេចព្រះសង្ឃរាជជួន ណាត បាល

[3] វចនានុក្រមសម្តេចព្រះសង្ឃរាជជួន ណាត សាធារណៈ

[4] ឈួន ឆាម, "កំណែទម្រង់រដ្ឋបាល"(បទបង្ហាញនៅសាលាភូមិន្ទរដ្ឋបាល, មករា ២០១៤)។

[5] កៅ មុយថង, ម៉ី វិចិត្រ, វ៉ាន់ ចន្ទតារា, គង់ជួរ, ទេព វិសុល, កែ វឌ្ឍរ៉, រៀបរៀង, *ប្រព័ន្ធរដ្ឋបាលកម្ពុជា* (ភ្នំពេញ៖ គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ, ២០០៨), ៨៣ ។

[6] ឈួន ឆាម, "កំណែទម្រង់រដ្ឋបាល"(បទបង្ហាញនៅសាលាភូមិន្ទរដ្ឋបាល, មករា ២០១៤)។

## ១.៣. រដ្ឋបាលក្រោមអាណានិគមនិយមបារាំង

ក្រោយសន្ធិសញ្ញាឆ្នាំ១៨៦៣ បារាំងបានប្រែក្លាយព្រះរាណាចក្រកម្ពុជាអោយស្ថិតនៅក្រោមអាណានិគមនិយមបារាំង រួចហើយនេះ បារាំងបានដកអំណាចពិតប្រាកដទាំងអស់ ចេញពីព្រះមហាក្សត្រ រួចធ្វើការផ្ទេរទៅអោយ លោក Resident Superieur ។ កិច្ចការរដ្ឋបាល ដែល ព្រះមហាក្សត្រធ្លាប់បានបំពេញ ត្រូវប្រគល់អោយ ទៅបារាំងជាអ្នកគ្រប់គ្រង។ កិច្ចប្រជុំសេនាបតីសភា ត្រូវស្ថិតក្រោមអធិបតីរបស់លោក Resident Superieur ។[7]

## ១.៤. រដ្ឋបាលសម័យព្រះរាជាណាចក្រទី២

### ១.៤.១. រដ្ឋបាលមុនឆ្នាំ ២០០៨

ក្រោយថ្ងៃ ៧ មករា ឆ្នាំ ១៩៧៩ រដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជាបានចាប់កកើតឡើងដោយអនុវត្តនូវរបបកុម្មុយនីស្ត ដែលអំណាចទាំងអស់ស្ថិតនៅលើ គណៈមជ្ឈឹមបក្សកុម្មុយនីស្ត។ រហូតដល់ឆ្នាំ ១៩៩៣ មានបោះឆ្នោតដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិ ទើបព្រះរាជាណាចក្រកម្ពុជា បានផ្លាស់ប្តូរមកជារបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រទី២ បានចាប់បដិសន្ធិនៅឆ្នាំ១៩៩៣ បានកំណត់ការគ្រប់គ្រងរដ្ឋបាលនៅកម្ពុជា បែងចែកជាខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់គឺជាមណ្ឌលរដ្ឋបាល។ យោងតាមខ្លឹមសារនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជាណាចក្រកម្ពុជាគឺជា រដ្ឋទោលមិនអាចបំបែកបាន ហើយទឹកដីនៃព្រះរាជាណាចក្រត្រូវបែងចែកចេញជាខេត្ត និង ក្រុង។ ខេត្ត ចែកជាស្រុក ស្រុក ចែកជាឃុំ។ ក្រុង ចែកជាខណ្ឌ ខណ្ឌ ចែកជាសង្កាត់។ ប្រទេសកម្ពុជាចែកចេញជា ២០ ខេត្ត និង ៤ក្រុង មាន ១៧១ស្រុក ១៤ខណ្ឌ ហើយមាន ១,៥១០ ឃុំ និង ១១១ សង្កាត់។[8]

តារាង ១៖ ផែនទីរដ្ឋបាលនៃព្រះរាជាណាចក្រ កម្ពុជា មុនឆ្នាំ ២០០៨៖




[7] ឈួន ឆាម, "កំណែទម្រង់រដ្ឋបាល"(បទបង្ហាញនៅសាលាភូមិន្ទរដ្ឋបាល, មករា ២០១៤)។

[8] កៅ មុយថង, ម៉ី វិចិត្រ, វ៉ាន់ច័ន្ទតារា, គង់ជូរ, ទេព វិសុល, កែ វឌ្ឍរ៉ា, រៀបរៀង, *ប្រព័ន្ធរដ្ឋបាលកម្ពុជា* (ភ្នំពេញ៖ គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ, ២០០៨), ២៦៤ ។

តារាង ២ ៖ ឈ្មោះខេត្ត ក្រុង នៃព្រះរាជាណាចក្រកម្ពុជា មុនឆ្នាំ២០០៨ ៖

| | |
|---|---|
| ១. បន្ទាយមានជ័យ | ១៣. ឧត្តរមានជ័យ |
| ២. បាត់ដំបង | ១៤. ក្រុង ប៉ៃលិន |
| ៣. កំពង់ចាម | ១៥. ក្រុង ភ្នំពេញ |
| ៤. កំពង់ឆ្នាំង | ១៦. ក្រុង ព្រះសីហនុ |
| ៥. កំពង់ស្ពឺ | ១៧. ព្រះវិហារ |
| ៦. កំពង់ធំ | ១៨. ពោធិសាត់ |
| ៧. កំពត | ១៩. ព្រៃវែង |
| ៨. កណ្តាល | ២០. រតនៈគិរី |
| ៩. កោះកុង | ២១. សៀមរាប |
| ១០. ក្រុង កែប | ២២. ស្ទឹងត្រែង |
| ១១. ក្រចេះ | ២៣. ស្វាយរៀង |
| ១២. មណ្ឌលគិរី | ២៤. តាកែវ |

ដោយយោងទៅតាមស្មារតីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ត្រូវគ្រប់គ្រងតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការមួយ។ រាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា ត្រូវបង្កើតអោយមានការធ្វើវិមជ្ឈការ ឬវិសមជ្ឈការ ដែលបាន កំណត់ក្នុងរដ្ឋធម្មនុញ្ញ។ ក្នុងនេះក្រសួងមហាផ្ទៃ ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលត្រូវមាន តួនាទីសំខាន់ ក្នុងការជួយរៀបចំអោយ ច្បាប់ ឬយុទ្ធសាស្ត្ររាជរដ្ឋាភិបាលអាចសម្រេចទៅបាន ដោយជោគជ័យ។

**១.៤.២. រដ្ឋបាលឆ្នាំ ២០០៨**

ថ្វីត្បិតតែរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មិនបានកំណត់ច្បាស់លាស់អំពីការតួនាទី មុខងារ និងភារកិច្ចក្នុងការគ្រប់គ្រងរដ្ឋបាលក៏ដោយ ប៉ុន្តែយោងតាមស្មារតីរបស់រដ្ឋធម្មនុញ្ញ តម្រូវ ស្ថាប័នសំខាន់បី គឺ ព្រឹទ្ធសភា រដ្ឋសភា និង រាជរដ្ឋាភិបាលដើរតួនាទី ក្នុងរៀបចំអោយមានគោល នយោបាយ និងប្រព័ន្ធអភិបាលកិច្ចទាំងនោះ។ នាឆ្នាំ ២០០១ រដ្ឋសភាបានអនុម័តយល់ព្រមលើ

ច្បាប់ស្តីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលនេះបានបង្ហាញពីឆន្ទៈរបស់រាជរដ្ឋាបាលក្នុងអនុវត្ត អោយស្របតាមរដ្ឋធម្មនុញ្ញ និងការកាត់បន្ថយនូវ អំណាចរបស់រដ្ឋបាលកណ្តាល។

ក្រោយមកទៀត នៅឆ្នាំ ២០០៨ ប្រព័ន្ធរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានធ្វើការផ្លាស់ប្តូរម្តងទៀតដែលការផ្លាស់ប្តូរលើកនេះ គឺជាការជំរុញនូវប្រសិទ្ធិភាពនៃការធ្វើវិមជ្ឈការ និងវិសមជ្ឈការ អោយបានពេញលេញដោយ បានអនុម័តច្បាប់ស្តីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។ ហើយក៏មានការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដោយធ្វើការកែប្រែទឹកដី ព្រះរាជាណាចក្រកម្ពុជាពី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ទៅជា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ ដែលនេះបានកំណត់អំពីការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជាត្រូវបែងចែកចេញជា ពីរប្រភេទ គឺ រដ្ឋបាលថ្នាក់តំបន់ និងរដ្ឋបាលថ្នាក់មូលដ្ឋាន ។ រដ្ឋបាលតំបន់ គឺសំដៅទៅលើរដ្ឋបាលខេត្ត។ រដ្ឋបាលមូលដ្ឋានដែលមាន ៣ថ្នាក់គឺ រដ្ឋបាលរាជធានី ខណ្ឌ សង្កាត់ រដ្ឋបាលមូលដ្ឋានដែលមាន ២ថ្នាក់គឺ រដ្ឋ-បាលក្រុង សង្កាត់ និងរដ្ឋបាលស្រុក ឃុំ។ បច្ចុប្បន្ននៅទូទាំង ប្រទេសមានរួមមាន រាជធានី ១ ខេត្ត ២៤ ក្រុងចំនួន២៦ ស្រុកចំនួន១៥៩ ខណ្ឌចំនួន១២ ឃុំ សង្កាត់ចំនួន១៦៣៣ និងភូមិចំនួន១៤.១៤៧។[9]

[9] គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, *ផែនការអនុវត្តបីឆ្នាំដំណាក់កាលទីពីរ(២០១៥-២០១៧) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(ផអ៣ទី២)* (ភ្នំពេញ ៖ ធ្នូ ២០១៤), ១។

# ជំពូកទី ២

# ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត

# ជំពូកទី ២
# ការគ្រប់គ្រងរដ្ឋបាលថ្នាក់រាជធានី ខេត្ត

ឆ្លងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺមានគោលបំណងកំណត់ពីការគ្រប់គ្រងរដ្ឋបាលនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ដែលនៅក្នុងនេះ រាជធានី ខេត្ត ត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាពដើម្បីបង្កើត ជំរុញ និងធ្វើអោយមានចីរភាពដល់អភិឌ្ឍន៍ តាមបែបលទ្ធិប្រជាធិបតេយ្យ។ ការបង្កើតអោយមាន រដ្ឋបាលឯកភាពគឺសំដៅដល់ការពង្រឹងអង្គឯកភាពរបស់រដ្ឋ ដើម្បីសម្របសម្រួលនូវរាល់ សកម្មភាពរដ្ឋបាលសាធារណៈនៅក្នុងដែនដីរបស់ខ្លួន។

រដ្ឋបាលរាជធានី ខេត្ត មានសាលារាជធានី ខេត្ត មន្ទីរ ការិយាល័យ និងមន្ត្រីជាច្រើន។ ប្រសិទ្ធិភាពនៃការងារអាចកើតមានឡើងអាស្រ័យទៅលើ អ្នកប្រតិបត្តិ មានគំនិតផ្តួចផ្តើម និងទំនួលខុសត្រូវដោយផ្ទាល់។

## ២.១. រចនាសម្ព័ន្ធរាជធានី ខេត្ត

តារាងទី៣៖ រចនាសម្ព័ន្ធរដ្ឋបាលរាជធានី



តារាងទី៤៖ រចនាសម្ព័ន្ធរដ្ឋបាលខេត្ត



## ២.២. ក្រុមប្រឹក្សារាជធានី ខេត្ត

ច្បាប់ស្តីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ កំណត់អោយរដ្ឋបាលរាជធានី ខេត្ត ក៏ដូចជារដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវមានក្រុមប្រឹក្សារបស់ខ្លួន ដែលត្រូវបានជ្រើសរើសឡើង តាមការបោះឆ្នោតជាអសកល ស្របតាមនីតិវិធីកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ដែលហៅកាត់ថា ក្រុមប្រឹក្សា ។ ក្រុមប្រឹក្សានីមួយៗត្រូវធ្វើជាតំណាង និងធ្វើសកម្មភាពក្នុងនាមប្រជាពលរដ្ឋទាំងអស់ ដែលរស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រុមប្រឹក្សា នីមួយៗត្រូវបង្កើត ជំរុញ និងធ្វើអោយមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅក្នុង ដែនសមត្ថកិច្ចរបស់ខ្លួន។

ក្រុមប្រឹក្សាមានអាណត្តិ ប្រាំ(៥)ឆ្នាំ[10] ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មី ចូលកាន់តំណែង។ អាណត្តិរបស់ក្រុមប្រឹក្សា ត្រូវគិតចាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងផុតកំណត់នៅថ្ងៃបោះឆ្នោតបន្ទាប់។ ក្នុងពេលរង់ចាំក្រុមប្រឹក្សាថ្មី ចូលកាន់តំណែង ក្រុមប្រឹក្សាដែលចប់អាណត្តិ មានសិទ្ធិអនុវត្តតែកិច្ចការរដ្ឋបាលប្រចាំថ្ងៃប៉ុណ្ណោះ។

ក្រុមប្រឹក្សា ត្រូវមានប្រធាន មួយរូប។ ប្រធានក្រុមប្រឹក្សា គឺជាបេក្ខជនដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃបញ្ជីបេក្ខជន ដែលមានអាសនៈច្រើនជាងគេនៅក្នុងក្រុមប្រឹក្សា។

[10] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, ២២ ឧសភា ២០០៨, មាត្រា ១៥។ (ចាប់ពីពេលនេះទៅ ហៅច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត)

ក្នុងករណីដែល បញ្ជីបេក្ខជនមានអាសនៈស្មើគ្នានៅក្នុងក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សា ត្រូវជ្រើសរើសយក បេក្ខជនដែលមានលេខរៀងលើគេ នៃបញ្ជីបេក្ខជនដែលមានសម្លេងឆ្នោតបានការច្រើនជាងគេ។

ចំនួនសមាជិកនៃក្រុមប្រឹក្សា ត្រូវកំណត់ដោយផ្អែកតាមកត្តាប្រជាសាស្ត្រ និងកត្តាភូមិសាស្ត្រ[11] ដូចខាងក្រោម ៖

- ក្រុមប្រឹក្សារាជធានីភ្នំពេញ ត្រូវមានសមាជិកមិនលើសពី ម្ភៃមួយ (២១) រូប ។
- ក្រុមប្រឹក្សាខេត្ត ត្រូវមានសមាជិកចាប់ពី ប្រាំបួន (៩) រូប ដល់ ម្ភៃមួយ (២១) រូប ។

ចំនួនជាក់ស្តែងនៃ សមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរ របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេលយ៉ាងតិច មួយរយម្ភៃ(១២០)ថ្ងៃ មុនពេលផុតកំណត់ អាណត្តិរបស់ក្រុមប្រឹក្សា។ ក្នុងករណីគ្មានអនុក្រឹត្យចែងអំពី ចំនួនក្រុមប្រឹក្សាអាណត្តិបន្ទាប់ទេ ចំនួនក្រុមប្រឹក្សាសម្រាប់អាណត្តិថ្មីត្រូវយកតាមចំនួនសមាជិកក្រុមប្រឹក្សាអាណត្តិចាស់។

តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា គឺក្រុមប្រឹក្សាមានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចនូវគោលបំណងក្នុងការបង្កើតការជំរុញ និងការធ្វើអោយមានចីរភាពដល់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ ព្រមទាំងដើម្បីបំពេញ មុខងារភារកិច្ចដែលបានប្រគល់ និងដែលបានធ្វើប្រតិភូកម្មតាមច្បាប់ ឬស្របតាមច្បាប់។

ក្រុមប្រឹក្សា មានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ ។ ក្រុមប្រឹក្សា ត្រូវបំពេញមុខងារ និងភារកិច្ច ដោយធ្វើសេចក្តីសម្រេចនៅក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាសេចក្តីសម្រេចនោះត្រូវបានអនុវត្ត។ ក្រុមប្រឹក្សា ប្រើប្រាស់សិទ្ធិអំណាចបញ្ញត្តិរបស់ខ្លួន ដោយការធ្វើ ដីកា ។

ក្រុមប្រឹក្សា ប្រើប្រាស់សិទ្ធិអំណាចប្រតិបត្តិ របស់ខ្លួនដោយធ្វើសេចក្តីសម្រេច នៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សា។ ក្រុមប្រឹក្សាត្រូវមាន គណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋទាំងអស់អំពីជម្រើសជាអទិភាព ដើម្បីធ្វើសេចក្តីសម្រេចធានាបាន ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងដែនដីរបស់ខ្លួន។ ក្រុមប្រឹក្សាអាចធ្វើការអង្កេតលើ ករណីទាំងឡាយណា ដែលខ្លួនយល់ឃើញថាមាន សារៈសំខាន់ដល់ ប្រជាពលរដ្ឋដែលខ្លួនជាតំណាង ព្រមទាំងផ្សព្វផ្សាយលទ្ធផលនៃការធ្វើអង្កេតនោះ រួចហើយត្រូវផ្តល់គោលការណ៍ណែនាំ អនុវត្តដល់គណៈអភិបាល និងអភិបាល។

[11] ច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត , មាត្រា ១៨។

ក្រុមប្រឹក្សាត្រូវមាន គណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការប្រតិបត្តិតាម រដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និង លិខិតបទដ្ឋានគតិយុត្តនានា។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានបំណងឈរឈ្មោះជាបេក្ខជននៃក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវបំពេញនូវលក្ខខ័ណ្ឌ និងមានលក្ខណសម្បត្តិ[12] ដូចខាងក្រោម ៖

- ត្រូវមានសញ្ជាតិខ្មែរតាំងពីកំណើត
- មានអាយុយ៉ាងតិច ម្ភៃប្រាំ (២៥) ឆ្នាំ គិតដល់ថ្ងៃបោះឆ្នោត
- មានសិទ្ធិបោះឆ្នោត
- ត្រូវជាសមាជិកគណបក្សនយោបាយដែលស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ ។

បេក្ខជនគ្មានសិទ្ធិឈរឈ្មោះជាបេក្ខភាពក្រុមប្រឹក្សារាជធានី ខេត្ត [13] ៖

- សមាជិករដ្ឋសភា ព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញ រាជរដ្ឋាភិបាល និងចៅក្រម
- អភិបាល អភិបាលរង រាជធានី ខេត្ត
- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការរៀបចំ ការបោះឆ្នោត និងមន្ត្រី បុគ្គលិកបម្រើការងាររៀបចំការបោះឆ្នោតគ្រប់លំដាប់
- មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ នគរបាលជាតិក្នុងមុខតំណែង
- មន្ត្រីបុគ្គលិករបស់ក្រុមប្រឹក្សាគ្រប់លំដាប់ថ្នាក់
- ជនដែលត្រូវបានផ្តន្ទាទោសដកសិទ្ធិបោះឆ្នោត
- ព្រះសង្ឃ ឬ បព្វជិតសាសនា។

សមាជិកក្រុមប្រឹក្សាត្រូវបាត់បង់សមាជិកភាពពី ក្រុមប្រឹក្សាក្នុងករណីណាមួយចំនួនគឺ[14] ៖

- សាមីខ្លួនបាត់បង់លក្ខណសម្បត្តិ និង លក្ខខណ្ឌសម្រាប់ឈរឈ្មោះជាបេក្ខជនបោះឆ្នោតក្រុមប្រឹក្សា

[12] ច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត , មាត្រា ២១។

[13] ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខនស/រកម/០៥០៨/០១៨ , ២៤ ឧសភា ២០០៨, មាត្រា ១៧ ។

[14] ច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត , មាត្រា ២២។

- សាមីខ្លួនសុំលាឈប់ពីក្រុមប្រឹក្សា តាមការដាក់ពាក្យសុំលាឈប់ ជាលាយលក្ខណ៍អក្សរទៅប្រធាន ក្រុមប្រឹក្សា
- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនមិនបានចូលរួមប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាជាប់ៗគ្នាចាប់ពី ពីរ(២)ដងឡើងទៅដោយមិនមានច្បាប់អនុញ្ញាត
- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬមជ្ឈិម ណាមួយ
- សាមីខ្លួនបាត់បង់សមាជិកភាពពិគណបក្សនយោបាយរបស់ខ្លួន
- សាមីខ្លួនត្រូវបានបណ្តេញចេញពីសមាជិកក្រុមប្រឹក្សាអនុលោមតាមច្បាប់ នីតិវិធី ឬបទបញ្ជាផ្ទៃក្នុង នៃក្រុមប្រឹក្សា ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសម្រេច និងប្រកាសពីការបាត់បង់សមាជិកភាពពីក្រុមប្រឹក្សា។ នៅពេលដែលមានសមាជិកណាមួយ បាត់បង់សមាជិកភាពនោះ ត្រូវជ្រើសរើសបេក្ខជនលំដាប់លេខរៀងបន្ទាប់ពីក្នុងបញ្ជីបេក្ខជនជាមួយមកជំនួសក្នុងរយៈពេលយ៉ាងយូរ ដប់បួន(១៤)ថ្ងៃដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ប្រសិនបើក្រុមប្រឹក្សាណាមួយអនុវត្តផ្ទុយពីបទប្បញ្ញត្តិណាមួយនៃ រដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើការណែនាំជាលាយលក្ខណ៍អក្សរដល់ ក្រុមប្រឹក្សានោះអោយគោរព និងអនុវត្តតាមបទប្បញ្ញត្តិអោយបានត្រឹមត្រូវ។ ក្នុងករណីក្រុមប្រឹក្សានោះនៅតែមិនព្រមអនុវត្តតាម ការណែនាំរាជរដ្ឋាភិបាលត្រូវរំសាយក្រុមប្រឹក្សាដោយ អនុក្រឹត្យតាមសំណើរ របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរៀបចំឡើងវិញ ដើម្បីជ្រើសរើសក្រុមប្រឹក្សាក្នុងករណីក្រុមប្រឹក្សាត្រូវបានរំសាយ ដោយការអនុវត្តផ្ទុយពីបទប្បញ្ញត្តិជាធរមាន និងកែប្រែតាមការណែនាំរបស់ ក្រសួងមហាផ្ទៃ ត្រូវធ្វើឡើងរយៈពេលយ៉ាងយូរ មួយរយម្ភៃ(១២០) ថ្ងៃ។

ក្រុមប្រឹក្សាដែលកើតថ្មីមានអាណត្តិស្មើនឹងអាណត្តិនៅសល់នៃក្រុមប្រឹក្សាដែលត្រូវបានរំសាយ ។ ក្រុមប្រឹក្សាណាមួយត្រូវរំសាយ ដែលអាណត្តិនៅសល់មិនលើសពី មួយរយប៉ែតសិប ថ្ងៃនេះការបោះឆ្នោត ត្រូវមិនត្រូវធ្វើឡើងឡើយ។ ក្នុងករណីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃចាត់វិធានដើម្បីគ្រប់គ្រងជំនួស រហូតដល់មានក្រុមប្រឹក្សាថ្មីចូលកាន់តំណែង[15]។

[15] ច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត , មាត្រា ២៧។

## ២.៣. គណៈអភិបាលរាជធានី ខេត្ត

រាជធានី ខេត្ត ត្រូវរៀបចំអោយមានគណៈអភិបាល។ គណៈអភិបាលត្រូវផ្តល់យោបល់ជូនក្រុមប្រឹក្សា រាយការណ៍ជូនក្រុមប្រឹក្សា និងជាអ្នកអនុវត្ត សេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។ គណៈអភិបាល ត្រូវជួយក្រុមប្រឹក្សា ដើម្បីអោយក្រុមប្រឹក្សាសម្រេចបាន នូវការអនុវត្តមុខងារ សិទ្ធិអំណាច និងភារកិច្ចរបស់ខ្លួន។ គណៈអភិបាលត្រូវជួយក្រុមប្រឹក្សាក្នុងការ ពិនិត្យមើលមុខងារ ភារកិច្ច និងធនធានទាំងអស់ដែលបានបែងចែក ឬបានផ្ទេរទៅអោយ រដ្ឋបាល ថ្នាក់ក្រោមជាតិ ហើយត្រូវផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សា អំពីរបៀបបំពេញមុខងារ ភារកិច្ច និងការ ចាត់ចែងធនធានទាំងនោះ។

គណៈអភិបាល ដែលបានសម្រេច ឬអនុវត្តកិច្ចការណាមួយដែលស្ថិត ក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សា ការសម្រេច ឬសកម្មភាពនោះពុំមានសុពលភាពឡើយ ។ គណៈអភិបាល ត្រូវរាយការណ៍ជូនក្រុមប្រឹក្សាអំពីការអនុវត្តសេចក្តីសម្រេចរបស់ ក្រុមប្រឹក្សា និងសកម្មភាពដែលបានអនុវត្តដោយគណៈអភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាក្នុងចន្លោះអង្គប្រជុំសាមញ្ញមួយទៅអង្គប្រជុំសាមញ្ញមួយទៀតរបស់ ក្រុមប្រឹក្សា។

គណៈអភិបាលត្រូវផ្តល់យោបល់ និងរាយការណ៍ជូនក្រុមប្រឹក្សាពីការរៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធានរបស់ក្រុមប្រឹក្សា ដើម្បីទទួលយក មុខងារ ភារកិច្ច និងធនធានដែលនឹងត្រូវផ្ទេរទៅឱ្យ ក្រុមប្រឹក្សាដោយច្បាប់នេះ ឬដែលស្របតាមច្បាប់នេះ។ គណៈអភិបាល ក្នុងនាមក្រុមប្រឹក្សា ត្រូវមានវិធានការដើម្បីធានាឱ្យ មន្ត្រី អង្គភាពនិងបុគ្គលិករបស់ក្រុមប្រឹក្សាបំពេញតួនាទីភារកិច្ចរបស់ខ្លួន និងបំពេញការងារប្រចាំថ្ងៃរបស់ក្រុមប្រឹក្សាព្រមទាំងអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រកបដោយប្រសិទ្ធភាព។ គណៈអភិបាល ត្រូវផ្តល់អនុសាសន៍ និងដាក់ជូនក្រុមប្រឹក្សា ដើម្បីពិភាក្សាសម្រេចអំពី[16] ៖

- ការបង្កើត ឬ រំសាយអង្គភាព
- ការរៀបចំតួនាទី ភារកិច្ច និងលក្ខខណ្ឌការងាររបស់បុគ្គលិក
- ការតែងតាំង ការដំឡើងឋានន្តរស័ក្តិ និងការបញ្ឈប់បុគ្គលិកដោយផ្អែកតាមបទប្បញ្ញត្តិនៃការគ្រប់គ្រងបុគ្គលិករបស់ក្រុមប្រឹក្សា
- ការកំណត់លក្ខណសម្បត្តិនៃការជ្រើសរើស ការតែងតាំង ការកំណត់ប្រាក់បៀវត្សនិងប្រាក់កម្រៃផ្សេងៗទៀតនៃបុគ្គលិករបស់ក្រុមប្រឹក្សា
- ការកំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុ សម្រាប់អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា

[16] ច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត , មាត្រា ១៦២។

- ការកំណត់យុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សា និងបុគ្គលិករបស់ខ្លួន។

គណៈអភិបាល ត្រូវរៀបចំដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនដើម្បីពិនិត្យ និងអនុម័តនូវ[17] :

- កម្មវិធីវិនិយោគបី (០៣) ឆ្នាំរំកិលប្រចាំឆ្នាំ និងគម្រោងថវិកាប្រចាំឆ្នាំ ផែនការអភិវឌ្ឍរយៈពេលប្រាំ (០៥) ឆ្នាំនិង ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមដែលត្រូវធ្វើបច្ចុប្បន្នភាពរៀងរាល់ឆ្នាំ និង របាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាដើម្បីផ្សព្វផ្សាយជូនប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ច របស់ខ្លួន។

គណៈអភិបាល ត្រូវលើកសំណើរទៅក្រុមប្រឹក្សា ដើម្បីកំណត់អំពីយុទ្ធសាស្ត្រ និងរបៀបនៃការពិគ្រោះយោបល់លើបញ្ហាចាំបាច់ផ្សេងៗរួមទាំងផែនការ អភិវឌ្ឍជាមួយ[18] :

- ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា
- ផ្នែកផ្សេងទៀតនៃក្រុមប្រឹក្សាដែលអនុវត្តមុខងារ និងភារកិច្ចនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានារបស់រដ្ឋាភិបាល
- ដៃគូពាក់ព័ន្ធដទៃទៀត។

ការពិគ្រោះយោបល់លើបញ្ហាចាំបាច់ផ្សេងៗ រួមទាំងផែនការអភិវឌ្ឍន៍ដែលត្រូវធ្វើឡើងដោយក្រុមប្រឹក្សាផ្ទាល់ ឬ ដោយគណៈអភិបាលក្នុងនាមក្រុមប្រឹក្សា។

គណៈអភិបាល ត្រូវរាយការណ៍ជូនគ្រប់អង្គប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា ជាមួយនឹងអនុសាសន៍ចាំបាច់នានា សម្រាប់លើកកម្ពស់ការអនុវត្ត[19] :

- មុខងារជាកាតព្វកិច្ចដែលបានផ្ទេរឱ្យក្រុមប្រឹក្សា
- មុខងារជាជម្រើសរបស់ក្រុមប្រឹក្សា
- គម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ស្ថានភាពហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ដីការបស់ក្រុមប្រឹក្សា ។

[17] ច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត , មាត្រា ១៦៣។
[18] ច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត , មាត្រា ១៦៤។
[19] ច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត , មាត្រា ១៦៥។

គណៈអភិបាល ត្រូវពិគ្រោះយោបល់ជាមួយ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដើម្បីធានាឱ្យផែនការសកម្មភាព និងថវិការបស់បណ្តាក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា របស់រាជរដ្ឋាភិបាលដែលផ្តល់សេវា សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធ ដោយផ្ទាល់នៅក្នុង ដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា បានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ ព្រមទាំងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

គណៈអភិបាល ត្រូវលើកទឹកចិត្ត សម្របសម្រួល និងគាំទ្រដល់ សមាជិកក្រុមប្រឹក្សាបុគ្គលិករបស់ក្រុមប្រឹក្សា ដើម្បីរាយការណ៍ជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សា និងរដ្ឋមន្រ្តីក្រសួងមហាផ្ទៃជាបន្ទាន់ នៅពេលដែលបានឃើញ ឬ ដែលបានសង្ស័យដោយមានហេតុផល ឬ ដែលមានការប្តឹងតវ៉ា ឬ ប្តឹងបរិហារ អំពីការរំលោភអំណាចដោយបុគ្គលណាម្នាក់នៅក្នុងដែនសមត្ថកិច្ចរបស់ ក្រុមប្រឹក្សា។

គណៈអភិបាល ត្រូវផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាពីការបង្កើតគណៈកម្មាធិការនានា តាមការចាំបាច់ដើម្បីជួយដល់ក្រុមប្រឹក្សាក្នុងការអនុវត្តការងារ។ គណៈអភិបាលត្រូវធានាឱ្យមានក្តារបិទផ្សាយព័ត៌មាន និងមធ្យោបាយផ្សព្វផ្សាយ ព័ត៌មានផ្សេងៗទៀត តាមតម្រូវការរបស់ក្រុមប្រឹក្សារបស់ខ្លួន។ រាល់ឯកសារទាំងអស់ដែលបាន បោះពុម្ពផ្សាយ ត្រូវតែបិទផ្សាយនៅលើក្តារព័ត៌មាន ឬត្រូវផ្សព្វផ្សាយតាមមធ្យោបាយ បានផ្សេងៗទៀតក្នុង ដែនសមត្ថកិច្ចរបស់ខ្លួន។ គណៈអភិបាល ត្រូវធានាឱ្យសាធារណជនមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការពិនិត្យមើលព័ត៌មាននានានៅលើ ក្តារបិទផ្សាយព័ត៌មាន ហើយត្រូវធានាថែរក្សាការពារសុវត្ថិភាពក្តារព័ត៌មាន ដែលមានក្នុងដែនសមត្ថ-កិច្ចរបស់ក្រុមប្រឹក្សា។

គណៈអភិបាល ត្រូវធ្វើការបែងចែកភារកិច្ចជាលាយល័ក្ខណ៍អក្សរនូវកិច្ចការដែលស្ថិតនៅក្នុងសិទ្ធិអំណាចរបស់ខ្លួន។ គណៈអភិបាលត្រូវមាន ប្រធានមួយរូប ដែលហៅថាអភិបាល និងអភិបាលរងមួយចំនួន។ គណៈអភិបាលរាជធានីភ្នំពេញ មានយ៉ាងច្រើន ប្រាំពីរ (៧) រូប និង គណៈអភិបាលខេត្តមានចំនួនចាប់ពី បី(៣) រូប ទៅ ប្រាំពីរ(៧ )រូប [20]។

## ២.៣.១. អភិបាល

អភិបាលរាជធានី ខេត្តមានអំណាច ជាតំណាងរាជរដ្ឋាភិបាលក្នុងវិស័យនយោបាយ និង រដ្ឋបាលរាជធានី ខេត្តរបស់ខ្លួន អភិបាលរាជាធានី ខេត្ត ត្រូវស្ថិតក្រោមការដឹកនាំផ្ទាល់របស់ក្រសួងមហាផ្ទៃ និងជាតំណាងអោយរដ្ឋមន្រ្តីនៃក្រសួងស្ថាប័ន នៅថ្នាក់ជាតិ។ អភិបាលរាជធានី ខេត្ត មានតួនាទីទទួលខុសត្រូវចំពោះមុខ រាជរដ្ឋាភិបាល អំពីកិច្ចការទូទៅដែលកើតមាននៅក្នុងរាជធានី ខេត្ត

[20] ច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត , មាត្រា ១៨០។

របស់ខ្លួន និងជាធានានារ៉ាបរងមិនអោយមាន ការបែងចែកទឹកដី រក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ធានាអោយមានការអនុវត្តច្បាប់។

អភិបាលរាជធានី ខេត្ត ដឹកនាំសម្របសម្រួល ជំរុញការត្រួតពិនិត្យសកម្មភាពខាងរដ្ឋបាលជំនាញ មានអំណាចអាណាព្យាបាលលើ សមូហភាពដែនដី គ្រឹះស្ថានសាធារណៈ និង សម្របសម្រួលសកម្មភាព អង្គភាពនានាដែលមាននៅក្នុងរាជធានី ខេត្តរបស់ខ្លួន អោយស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និង កម្មវិធីអភិវឌ្ឍន៍របស់រាជធានី ខេត្ត ។ ផ្សព្វផ្សាយ អនុវត្តជំរុញ និងតាមដានការអនុវត្តច្បាប់បទប្បញ្ញត្តិ និងសេចក្តីសម្រេចផ្សេងៗ និងមានអំណាចបញ្ជាលើកម្លាំងនគរបាលក្នុងដែនគ្រប់គ្រងរបស់ខ្លួន។ មានអំណាចគ្រប់គ្រងលើមន្ត្រីរាជការតាមខ្សែបណ្តោយ និងខ្សែទទឹងដែលបំពេញការងារ នៅតាមមន្ទីរនានានៅក្នុងរាជធានី ខេត្ត។ មានអំណាចសម្របសម្រួល ជំរុញអនុវត្ត និងត្រួត ពិនិត្យ លើមន្ត្រីរាជការលើបណ្តា មន្ទីរជំនាញនានា របស់រដ្ឋដែលបានដាក់តាំងនៅក្នុងរាជធានី ខេត្ត លើកលែងតែការងារឯកទេសរបស់តុលាការ។

អភិបាលរាជធានី ខេត្ត ត្រូវតែងតាំងដោយ ព្រះរាជក្រឹត្យតាមសំណើររបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ អភិបាលរាជធានី ខេត្ត មិនមែនជាសមាជិករបស់ក្រុមប្រឹក្សារាជធានី ខេត្តទេ។ អភិបាលអាចចូលរួមប្រជុំ និងមានសិទ្ធិបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាតែមិនអាចធ្វើការបោះឆ្នោតបានឡើយ។ អភិបាល មានអាណត្តិការងារមិនលើសពី បួន(៤)ឆ្នាំ ហើយអាចត្រូវបានតែងតាំងបាន បួន(៤)ឆ្នាំទៀត សម្រាប់អាណត្តិទី ២របស់ខ្លួននៅក្នុងដែនសមត្ថ-កិច្ចដដែល ។

អភិបាលរាជធានី ខេត្ត ត្រូវជ្រើសចេញពីក្នុងចំណោមមន្ត្រីទាំងពីរភេទដែលស្ថិតក្នុងក្របខណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ដែលមានលក្ខណៈសម្បត្តិដូចខាងក្រោម[21] ៖

- មានឋានន្តរសក្តិឧត្តមមន្ត្រី
- មានអាយុចាប់ពី សាមសិបប្រាំ (៣៥) ឆ្នាំឡើងគិតដល់ថ្ងៃតែងតាំង
- មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួន ប្រាំពីរ (៧) ឆ្នាំ ឬ/និងមានសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជននិងកីឡា
- មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង
- មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ ។

[21] ច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត , មាត្រា ១៤២។

ក្នុងករណីចាំបាច់អភិបាល អាចជ្រើសរើសពីក្នុង ចំណោមមន្ត្រីទាំងពីរភេទដែលស្ថិតក្នុង ក្របខណ្ឌមន្ត្រីរាជការស៊ីវិល ក្រៅពីក្របខណ្ឌក្រសួងមហាផ្ទៃបាន ប៉ុន្តែមន្ត្រីនោះត្រូវមាន លក្ខណសម្បត្តិសមស្របតាមការរៀបរាប់ខាងលើ។

អភិបាល ត្រូវបញ្ឈប់ពីមុខតំណែងនៅមុនពេលបញ្ចប់អាណត្តិរបស់ខ្លួន ប្រសិនបើ[22] ៖

- ដាក់ពាក្យលាលែងជាលាយលក្ខណ៍អក្សរជូនទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ត្រូវបានដកហូតពីមុខតំណែង។

អភិបាលត្រូវដកហូតពីមុខតំណែង មុនពេលពបញ្ចប់អាណត្តិការងារ ក្នុងករណីមួយចំនួនដូចខាងក្រោម[23] ៖

- បាត់បង់លក្ខណសម្បត្តិជាអភិបាល
- បំពេញការងារមិនបានល្អ
- បោះបង់ចោលការងារ
- មានបញ្ហាសុខភាព ឬបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច
- ប្រព្រឹត្តិខុសឆ្គងក្រមសីលធម៌វិជ្ជាជីវៈ ។

ក្រុមប្រឹក្សា អាចស្នើជាលាយលក្ខណ៍អក្សរទៅ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីដកហូត អភិបាលចេញពីមុខតំណែងដោយផ្អែកតាមករណីណាមួយក្នុងចំណោមករណីខាងលើ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់នូវ សំណើរខាងលើនេះ ដើម្បីធ្វើសេចក្តីរាយការណ៍ ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យសម្រេចចំពោះអភិបាលរាជធានី ខេត្ត។

### ២.៣.២. អភិបាលរង

អភិបាលរងរាជធានី ខេត្ត ត្រូវទទួលខុសត្រូវចំពោះមុខអភិបាលរាជធានី ខេត្ត។ រួមជាមួយអភិបាលដើម្បីសម្រេចកិច្ចការនានា។ ក្នុងពេលអភិបាលរាជធានី ខេត្ត ជាប់បេសកម្ម ឬអវត្តមានអភិបាល អភិបាលរងរាជធានីខេត្ត មានសិទ្ធិជំនួស និងសម្រេចនូវរាល់កិច្ចការ ដែលបានចាត់ចែងប្រគល់ពីអភិបាលរាជធានី ។ អភិបាលរងរាជធានីខេត្ត ត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ អភិបាលរងរាជធានី ខេត្ត មិនមែនជាសមាជិករបស់ក្រុមប្រឹក្សារាជធានី ខេត្តទេ។

[22] ច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត , មាត្រា ១៥០។
[23] ច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត , មាត្រា ១៥១។

អភិបាលរងអាចចូលរួមប្រជុំ និងមានសិទ្ធិបញ្ចេញមតិ ក្នុងអង្គប្រជុំក្រុមប្រឹក្សាតែមិនអាច ធ្វើការបោះឆ្នោតបានឡើយ។ អភិបាលរង មានអាណត្តិការងារមិនលើសពី បួន(៤)ឆ្នាំ ហើយអាចត្រូវបានតែងតាំងបាន បួន(៤)ឆ្នាំទៀត សម្រាប់អាណត្តិទី ២របស់ខ្លួននៅក្នុងដែនសមត្ថកិច្ចដដែល។

អភិបាលរង រាជធានី ខេត្តត្រូវជ្រើសចេញពីក្នុងចំណោមមន្ត្រីទាំងពីរភេទដែលស្ថិតក្នុងក្របខណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ដែលមានលក្ខណៈសម្បត្តិដូចខាងក្រោម[24] ៖

- មានឋានន្តរសក្តិវិរៈមន្ត្រី ឡើងទៅ
- មានអាយុចាប់ពី សាមសិបប្រាំ (៣៥) ឆ្នាំឡើងគិតដល់ថ្ងៃតែងតាំង
- មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួន ប្រាំ (៥) ឆ្នាំ ឬ/និងមានសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជននិងកីឡា
- មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង
- មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ ។

ក្នុងករណីចាំបាច់អភិបាលរង អាចជ្រើសរើសពីក្នុង ចំណោមមន្ត្រីទាំងពីរភេទដែលស្ថិតក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិល ក្រៅពីក្របខណ្ឌក្រសួងមហាផ្ទៃបាន ប៉ុន្តែមន្ត្រីនោះត្រូវមាន លក្ខណសម្បត្តិសមស្របតាមការរៀបរាប់ខាងលើ។

អភិបាលរង ត្រូវបញ្ឈប់ពីមុខតំណែងនៅមុនពេលបញ្ចប់អាណត្តិរបស់ខ្លួន ប្រសិនបើ [25] ៖

- ដាក់ពាក្យលាលែងជាលាយលក្ខណ៍អក្សរជូនទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ឬ ត្រូវបានដកហូតពីមុខតំណែង។

អភិបាលរងត្រូវដកហូតពីមុខតំណែងមុនពេលពបញ្ចប់អាណត្តិការងារក្នុងករណីមួយចំនួនដូច[26] ៖

- បាត់បង់លក្ខណសម្បត្តិជាអភិបាល
- អសមត្ថភាព
- បំពេញការងារមិនបានល្អ
- មានបញ្ហាសុខភាព ឬបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច

[24] ច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត , មាត្រា ១៤៣។
[25] ច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត , មាត្រា ១៥០។
[26] ច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត , មាត្រា ១៥១។

- បោះបង់ចោលការងារ
- ប្រព្រឹត្តិខុសឆ្គងក្រមសីលធម៌វិជ្ជាជីវៈ ។

ក្រុមប្រឹក្សា អាចស្នើជាលាយលក្ខណ៍អក្សរទៅ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីដកហូត អភិបាលចេញពីមុខតំណែងដោយផ្អែកតាមករណីណាមួយក្នុងចំណោមករណីខាងលើ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់នូវ សំណើរខាងលើនេះ ដើម្បីធ្វើសេចក្តីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យសម្រេចចំពោះអភិបាលរាជធានី ខេត្ត។

## ២.៤. ទំនាក់ទំនងរវាងក្រុមប្រឹក្សា និងគណៈអភិបាលរាជធានីខេត្ត

ក្រុមប្រឹក្សា និងគណៈអភិបាលរាជធានីខេត្ត មានទំនាក់ទំនងគ្នាយ៉ាងស្អិតរមួតដែលពុំអាចកាត់ផ្តាច់បានព្រោះ ក្រុមប្រឹក្សាមាននូវអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិដែលសម្រេចឡើងដើម្បីដោះស្រាយបញ្ហាដែលកើតមានក្នុងដែនដីរបស់ខ្លួន។

ចំណែកគណៈអភិបាលរាជធានីខេត្ត ចាំបាច់ ទទួលខុសត្រូវក្នុងការចាត់ចែងអនុវត្តកិច្ចការទាំងអស់នេះ ក្នុងនាមក្រុមប្រឹក្សា។ ក្រៅពីនេះទៀត ក្រុមប្រឹក្សា និងគណៈអភិបាលនៅមានទំនាក់ទំនងគ្នាដូចខាងក្រោម៖

- ក្រុមប្រឹក្សា ត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើកិច្ចការដែលអនុវត្តដោយ គណៈអភិបាល ដើម្បីធានាថាការអនុវត្តការងារទាំងនេះស្របតាមច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តិជាធរមាន
- គណៈអភិបាល ត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សា រៀងរាល់កិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ខ្លួន
- គណៈអភិបាលត្រូវមានគណនេយ្យភាពចំពោះប្រជាជន និងក្រុមប្រឹក្សា
- គណៈអភិបាល ធ្វើសេចក្តីរាយការណ៍អំពីសកម្មភាព និងលទ្ធផលនៃការអនុវត្ត តួនាទីជាតំណាងរាជរដ្ឋាភិបាល និងតំណាងក្រសួង ស្ថាប័ននានា ព្រមទាំងស្ថានភាពនៃការងារទាំងនោះក្នុងរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ត្រូវរាយការណ៍ជូនក្រុមប្រឹក្សា
- ករណីមានបញ្ហាពាក់ព័ន្ធ ការអនុវត្តតួនាទីរបស់អភិបាល ក្នុងនាមជាតំណាងក្រុមប្រឹក្សា តំណាងក្រសួងស្ថាប័ន តំណាងរាជរដ្ឋាភិបាល ហើយមានផលប៉ះពាល់ដល់ ផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ ឬមានការទាមទារតវ៉ា ក្រុមប្រឹក្សាអាចតម្រូវ អោយអភិបាលខេត្តធ្វើសេចក្តីរាយការណ៍ជាពិសេសជូនកិច្ចប្រជុំក្រុមប្រឹក្សា

- ក្រុមប្រឹក្សា អាចផ្តល់អនុសាសន៍ និងការណែនាំដល់អភិបាលអំពីការអនុវត្តតួនាទី ដើម្បីឆ្លើយតបតម្រូវការជាអទិភាព និងបញ្ហាប្រឈមជាមូលដ្ឋាន។ គណៈអភិបាល ត្រូវទទួលយកអនុសាសន៍ និងការណែនាំក្រុមប្រឹក្សា ដើម្បីធ្វើការណែនាំ សម្រប សម្រួល និងតម្រង់ទិសដល់មន្ទីរ អង្គភាពពាក់ព័ន្ធក្នុងការឆ្លើយតបតម្រូវការហើយត្រូវរាយការណ៍ជូនក្រុមប្រឹក្សាវិញ[27] ។

## ២.៥. ទំនាក់ទំនងរវាងរដ្ឋបាលរាជធានីខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ

ក្រៅពីទំនាក់ទំនងភារកិច្ច និងរបៀបរបបការងាររបស់ ក្រុមប្រឹក្សារាជធានី ខេត្ត គណៈអភិបាលរាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅមានទំនាក់ទំនងមួយចំនួនទៀតដូចជា ៖

- ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សារាជធានីខេត្ត
- ដីកា ឬសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌត្រូវស្ថិតនៅក្រោមការ ពិនិត្យនីត្យានុកុលភាពរបស់ក្រុមប្រឹក្សារាជធានីខេត្ត ដោយឈរលើមូលដ្ឋានច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តិនានា ព្រមធានាថា ក្រុង ស្រុក ខណ្ឌឆ្លើយតបយ៉ាងប្រសើរបំផុតនូវសេចក្តីត្រូវការនានារបស់ប្រជាពលរដ្ឋ។ ក្នុងករណី ពិនិត្យឃើញភាពមានស្របតាមច្បាប់ ឬហួសនូវដែនសមត្ថកិច្ចដែលបានធ្វើប្រតិភូកម្ម គណៈអភិបាល ត្រូវធ្វើការណែនាំជាលាយលក្ខណ៍អក្សរជូនដល់ ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដោយបញ្ជាក់ចំពោះការធ្វើសេចក្តីសម្រេច ឬសកម្មភាពមិនស្របរបស់ក្រុមប្រឹក្សា
- ក្រុមប្រឹក្សារាជធានីខេត្ត ត្រូវធានាធ្វើប្រតិភូកម្មនូវមុខងារ និងភារកិច្ចសមស្របដល់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដើម្បីអោយក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌលើកកម្ពស់ការ ចូលរួម និងភាពជាម្ចាស់របស់ប្រជាពលរដ្ឋ សំដៅបង្កើតជំរុញ និងធ្វើអោយមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមក្រុង ស្រុក ខណ្ឌនីមួយៗ
- ក្នុងនាមរាជរដ្ឋាភិបាល គណៈអភិបាលរាជធានី ខេត្ត ត្រូវធ្វើការដឹកនាំ ណែនាំ សម្របសម្រួលដល់ គណៈអភិបាលខណ្ឌ ដើម្បីការគោរពច្បាប់ក្នុង ដែនសមត្ថកិច្ច រក្សាសណ្តាប់ធ្នាប់ សន្តិសុខសាធារណៈ ការគោរពសិទ្ធិមនុស្ស ក្នុងដែនសមត្ថកិច្ចរបស់រាជ-ធានី ខេត្ត

[27] ហៀង សាង, ប៉េង ឆុង, *សមត្ថកិច្ច និងរបៀបរបបការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ*, ២៧។

- ក្រុមប្រឹក្សារាជធានីត្រូវធានាផ្តល់មធ្យោបាយ សម្ភារៈ ធនធាននានារួមទាំង ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងការបណ្តុះបណ្តាល ដល់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ រួមទាំងបុគ្គលិករបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដើម្បីអនុវត្តមុខងារ និងភារកិច្ច ដែលប្រគល់ជូន
- ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌត្រូវអនុវត្តមុខងារ និងភារកិច្ចដែលក្រុមប្រឹក្សារាជធានី ខេត្ត បានធ្វើប្រតិភូកម្ម និងត្រូវទទួលខុសត្រូវ និង មានគណនេយ្យភាព ដោយផ្ទាល់ ចំពោះប្រជាពលរដ្ឋ, ក្រុមប្រឹក្សាឃុំ សង្កាត់ដែលខ្លួនគ្រប់គ្រង និងចំពោះក្រុមប្រឹក្សារាជ-ធានី ខេត្ត ដែលជាម្ចាស់ប្រតិភូកម្ម [28]។

## ២.៦. ទំនាក់ទំនងរវាងរដ្ឋបាលរាជធានីខេត្ត និងរដ្ឋបាលឃុំ សង្កាត់

ទំនាក់ទំនងរវាងរដ្ឋរាជធានី ខេត្ត និងរដ្ឋបាលឃុំ សង្កាត់ ក៏ដូចជារវាងក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាទំនាក់ទំនងមួយដែលមិនអាចកាត់ផ្តាច់បាន ព្រោះរដ្ឋបាលឃុំ សង្កាត់ ក៏ជាក្រុមប្រឹក្សាឃុំ សង្កាត់ ជាអាជ្ញាធរដែនដី ដែលនៅកៀរជិតប្រជាពលរដ្ឋ ដែលពួកគាត់បានដឹង យ៉ាងពី តម្រូវការរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានដែលហេតុនាំអោយមូលដ្ឋានមានការអភិវឌ្ឍបានយ៉ាង រលូន។ ប្រសិនបើមូលដ្ឋានមានការអភិវឌ្ឍន៍នេះ ការអភិវឌ្ឍរាជធានីខេត្ត ក៏មានភាពងាយស្រួលផងដែ រ។ ដូច្នេះហើយរាជធានីខេត្ត ត្រូវមានទំនាក់ទំនង យ៉ាងល្អប្រសើរជាមួយ មូលដ្ឋាន ដែលក្នុងចំណុច យើងអាចសង្កេតមានទំនាក់ទំនងគ្នាដូចខាងក្រោមៈ

- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវស្ថិតក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សា រាជ-ធានី ខេត្ត
- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវស្ថិតក្រោមការត្រួតពិនិត្យនីត្យានុកុលភាព នៃការអនុវត្តមុខងារ ភារកិច្ចដែលបានធ្វើប្រតិភូកម្មអោយឃុំ សង្កាត់ ដោយផ្អែកលើច្បាប់ និងលិខិតបទដ្ឋានគតិ-យុត្តដែលពាក់ព័ន្ធ
- ក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ មុនធ្វើ ប្រតិភូកម្មមុខងារ ភារកិច្ចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីធានាថាក្រុមប្រឹក្សាអាចអនុវត្តមុខ ងារបានល្អ និងអាចឆ្លើយតបទៅតាមតម្រូវការរបស់ប្រជាពលរដ្ឋ។ ក្រៅពីនេះទៀត ក្រុមប្រឹក្សា ឃុំ សង្កាត់ត្រូវមានគណនេយ្យភាពចំពោះពលរដ្ឋ និង ចំពោះក្រុមប្រឹក្សារាជធានីខេត្ត

[28] ហៀង សាង ,ប៉េង ឆុង ,*សមត្ថកិច្ច និងរបៀបរបបការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ*, ៨៧។

មុខងារ និងភារកិច្ចដែលក្រុមប្រឹក្សារាជធានី ខេត្តត្រូវធ្វើប្រតិភូកម្មដល់ក្រុមប្រឹក្សា ឃុំ សង្កាត់ គឺជាមុខងារ ភារកិច្ចដែលមានពាក់ព័ន្ធដោយផ្ទាល់ដល់ការផ្តល់សេវាកម្ម ការអភិវឌ្ឍ និងសេចក្តីត្រូវការជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ តាមឃុំ សង្កាត់ ក្រុមប្រឹក្សារាជធានី ខេត្តត្រូវផ្តល់នូវមធ្យោបាយដល់ឃុំ សង្កាត់ដើម្បីអនុវត្តកិច្ចការ។

# ជំពូកទី ៣
# ដំណើរការអនុវត្តកិច្ចការរដ្ឋបាល

# ជំពូកទី ៣
# ដំណើរការអនុវត្តកិច្ចការរដ្ឋបាល

## ៣.១. កិច្ចប្រជុំ

កិច្ចប្រជុំរដ្ឋបាលរាជធានី ខេត្ត គឺជាការជួបប្រជុំគ្នាដែលមានគោលបំណងច្បាស់លាស់ ដោយប្រកាន់យកការផ្លាស់ប្តូរយោបល់ និងការពិគ្រោះពិភាក្សា ជាមធ្យោបាយដ៏ចម្បង ក្នុងការសម្រេចនូវគោលបំណងទាំងនោះ។

ជាទូទៅ កិច្ចប្រជុំចែកចេញជាកិច្ចប្រជុំសាមញ្ញ និងកិច្ចប្រជុំវិសាមញ្ញ ដែលអាចរៀបចំឡើងជាសាធារណៈ ឬ ដោយសម្ងាត់ អាស្រ័យទៅនឹងគោលបំណង និងឬការតម្រូវដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។

កិច្ចប្រជុំសាមញ្ញ គឺជាកិច្ចប្រជុំដែលត្រូវរៀបចំឡើងជាទៀងទាត់ ទៅតាមពេលវេលាកំណត់ជាក់លាក់ណាមួយ[29] ។

កិច្ចប្រជុំវិសាមញ្ញ គឺជាកិច្ចប្រជុំដែលត្រូវរៀបចំជាបន្ទាន់ដោយពុំអាចរង់ចាំការប្រជុំ សាមញ្ញបាន ដើម្បីដោះស្រាយបញ្ហាបន្ទាន់ ឬពិសេស[30] ។

កិច្ចប្រជុំដែលរៀបចំជាសាធារណៈ គឺជាកិច្ចប្រជុំមួយដែលអនុញ្ញាតអោយអ្នក ដែលមានចំណាប់អារម្មណ៍នានាចូលរួមប្រជុំ ក្នុងនាមជាអ្នកសង្កេតការ[31] ។

កិច្ចប្រជុំដែលរៀបចំឡើងជាសម្ងាត់ គឺជាកិច្ចប្រជុំមួយ ដែលអនុញ្ញាតអោយចូលរួមចំពោះតែអ្នកដែលមានសមត្ថកិច្ច ឬអ្នកដែលពាក់ព័ន្ធប៉ុណ្ណោះ ដោយពុំអនុញ្ញាតអោយអ្នក មានចំណាប់អារម្មណ៍នានាចូលរួមប្រជុំឡើយ[32] ។

នៅរដ្ឋបាលរាជធានី ខេត្តរួមមានកិច្ចប្រជុំដូចខាងក្រោម ៖

- កិច្ចប្រជុំក្រុមប្រឹក្សា
- កិច្ចប្រជុំគណៈកម្មាធិការនានា
- កិច្ចប្រជុំគណៈអភិបាល
- កិច្ចប្រជុំអន្តរទីចាត់ការ
- កិច្ចប្រជុំផ្ទៃក្នុងទីចាត់ការ

[29] អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ, *សៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ* (ភ្នំពេញ ៖ ២០១៥), ១៩៦។

[30] ដូច 33, ទំព័រ១៩៦។

[31] ដូច 33, ទំព័រ១៩៦។

[32] ដូច 33, ទំព័រ១៩៦។

ក្រៅពីកិច្ចប្រជុំទាំងនេះ រដ្ឋបាលរាជធានី ខេត្តអាចមានកិច្ចប្រជុំមួយចំនួនទៀត ដូចជាកិច្ចប្រជុំជាមួយបុគ្គលិកក្រោមឱវាទទាំងអស់នៃរដ្ឋបាលរាជធានី ខេត្ត, កិច្ចប្រជុំជាមួយអង្គភាពជំនាញនានាដែលប្រតិបត្តិនៅក្នុង ដែនសមត្ថកិច្ចរបស់ខ្លួន និងកិច្ចប្រជុំផ្សេងៗទៀត ដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ដើម្បីអោយកិច្ចប្រជុំក្រុមប្រឹក្សាដំណើរការបាន តម្រូវអោយមានចំនួនកូរ៉ុមគ្រប់ចំនួន បើពុំមានកូរ៉ុមគ្រប់គ្រាន់ទេ កិច្ចប្រជុំត្រូវប្រកាសរំសាយ។ ការពិនិត្យចំនួនកូរ៉ុមត្រូវធ្វើឡើងមុនពេលបើកកិច្ចប្រជុំ អ្នកទទួលខុសត្រូវពិនិត្យចំនួនកូរ៉ុម គឺអធិបតីអង្គប្រជុំ និងនាយករដ្ឋបាល។ ក្នុងករណីមានសមាជិកក្រុមប្រឹក្សាម្នាក់ ឬច្រើននាក់ចាកចេញពីកិច្ចប្រជុំក្នុងកំឡុងពេលប្រជុំ ដែលធ្វើអោយកូរ៉ុម មិនគ្រប់គ្រាន់សម្រាប់ដំណើរការប្រជុំបន្តទៀត អធិបតីអង្គប្រជុំត្រូវបញ្ឈប់កិច្ចប្រជុំភ្លាម ហើយរបៀបវារៈដែលមិនទាន់បានពិភាក្សា និងអនុម័ត ត្រូវបន្តពិភាក្សានៅក្នុងសម័យប្រជុំដដែលនេះ ដោយបន្តកិច្ចប្រជុំនេះនៅពេលម៉ោង ឬថ្ងៃការងារបន្ទាប់។ ក្នុងករណីនេះ អធិបតីអង្គប្រជុំត្រូវជម្រាប ដល់អ្នកចូលរួមទាំងអស់អំពីពេលវេលា និងទីកន្លែងដែលត្រូវបន្តសម័យប្រជុំនេះ។

### ៣.១.១. កិច្ចប្រជុំក្រុមប្រឹក្សា

កិច្ចប្រជុំក្រុមប្រឹក្សារួមមានកិច្ចប្រជុំសាមញ្ញ និងកិច្ចប្រជុំវិសាមញ្ញដែលត្រូវធ្វើឡើងជាសាធាណៈនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន លើកលែងតែរបៀបវារៈណាមួយដែលតម្រូវអោយមាន ការប្រជុំពិភាក្សាដោយសម្ងាត់។ ក្រុមប្រឹក្សា ត្រូវរៀបចំកិច្ចប្រជុំសាមញ្ញ របស់ខ្លួនជាទៀងទាត់ យ៉ាងតិច១២ដងក្នុង មួយឆ្នាំទៅតាមប្រតិទិនប្រជុំប្រចាំឆ្នាំដែលខ្លួនបានអនុម័ត។ ក្រុមប្រឹក្សាត្រូវរៀបចំផ្សព្វផ្សាយជាសាធារណៈ នូវប្រតិទិនប្រជុំសាមញ្ញប្រចាំឆ្នាំរបស់ខ្លួន។

ក្រុមប្រឹក្សាអាចប្រជុំវិសាមញ្ញរបស់ខ្លួន នៅពេលណាមួយតាមការចាំបាច់ ដើម្បីពិភាក្សាលើបញ្ហាពិសេស ឬបន្ទាន់ណាមួយ តាមការស្នើសុំរបស់ប្រធានក្រុមប្រឹក្សា ឬសមាជិកក្រុមប្រឹក្សាមួយភាគបី (១/៣)[33] នៃសមាជិកក្រុមប្រឹក្សាទាំងមូល ឬអភិបាល ឬគណៈអភិបាល ។

រាល់កិច្ចប្រជុំ ក្រុមប្រឹក្សារាជធានីខេត្ត ត្រូវធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ ឬធ្វើសេចក្តីសម្រេចខាងប្រតិបត្តិដែលជាគោលការណ៍ គោលនយោបាយរបស់ រដ្ឋបាលរាជធានី និងជា វិធានការ បែបបទ នីតិវិធីចាត់ចែងការងារតាមការចាំបាច់ទាក់ទងទៅនឹង ៖

- ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មីដែលស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

[33] ដូច 33, ទំព័រ១៥១។

- ការអនុវត្តមុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត
- ការអនុវត្តមុខងារជម្រើសរបស់ក្រុមប្រឹក្សារាជធានី ខេត្ត
- ផែនការអភិវឌ្ឍន៍រយៈពេល ប្រាំឆ្នាំ និងកម្មវិធីវិនិយោគ បីឆ្នាំរំកិលប្រចាំឆ្នាំ
- ថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលរាជធានីខេត្ត
- បញ្ហាហិរញ្ញវត្ថុផ្សេងទៀត របស់ក្រុមប្រឹក្សា
- ការរៀបចំរចនាសម័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងការរៀបចំគណៈកម្មាធិការ ទីចាត់ការ និងបុគ្គលិករបស់ក្រុមប្រឹក្សា
- ការបែងចែកភារកិច្ច ដល់សមាជិកក្រុមប្រឹក្សារាជធានី ដើម្បីជួបប្រាស្រ័យទាក់ទង ជាមួយប្រជាពលរដ្ឋ និងតាមដានការងារតាមតម្រូវការរបស់ក្រុមប្រឹក្សា
- ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋបាលរាជធានីខេត្ត
- ដំណើរការពិគ្រោះយោបល់ជាមួយសាធារណៈជន ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- សមិទ្ធផល បញ្ហាប្រឈមនៃកិច្ចការនានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា[34]។

ក្រៅពីកិច្ចប្រជុំដែលក្រុមប្រឹក្សា ត្រូវធ្វើការសម្រេចដូចរៀបរាប់ខាងលើ ក្រុមប្រឹក្សា អាចធ្វើការសម្រេចក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ខ្លួននូវកិច្ចការផ្សេងៗទៀតរួមមាន ៖

- ការកោះអញ្ជើញអភិបាល ឬអភិបាលរង ឬគណៈអភិបាល ឬបុគ្គលដែលពាក់ព័ន្ធ មកសាកសួរអំពីការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ឬហេតុការណ៍ណាមួយដែលកើតមានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឬការដោះស្រាយបញ្ហាបន្ទាន់ណាមួយ
- ការពិនិត្យ និងដោះស្រាយវិវាទនៅមូលដ្ឋាន ស្របទៅតាមច្បាប់ ឬនីតិវិធីជាធរមាន
- ការសម្រេចចិត្តអោយធ្វើការស្រាវជ្រាវ ឬការស៊ើបអង្កេតលើករណីទាំងឡាយណា ដែលក្រុមប្រឹក្សា យល់ថាមានសារៈសំខាន់ដល់ ប្រជាពលរដ្ឋដែលខ្លួនជាតំណាងនិងសម្រេច អោយធ្វើការផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ ឬការអង្កេតនេះព្រមទាំង ណែនាំដល់គណៈអភិបាលអំពីវិធានការដោះស្រាយតាមលទ្ធផលនៃការស្រាវជ្រាវ

[34] ហៀង សាង, ប៉េង ធុង, *សមត្ថកិច្ច និងរបៀបរបបការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ*, ៩០។

- ការពិនិត្យស្រាវជ្រាវ និងធ្វើសេចក្តីរាយការណ៍ជូនក្រុងមហាផ្ទៃ ក្នុងករណីមានការរំលោភអំណាចក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ការពិនិត្យដោះស្រាយចំពោះ ទង្វើមិនស្របច្បាប់ ដែលប្រព្រឹត្តិដោយក្រុមប្រឹក្សាគណៈអភិបាល ឬដោយបុគ្គលិកនៃក្រុមប្រឹក្សា
- ការពិនិត្យរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំដែលរៀបចំដោយគណៈអភិបាល
- ការពិនិត្យ និងដោះស្រាយសំណូមពររបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

### ៣.១.២. កិច្ចប្រជុំគណៈអភិបាល

កិច្ចប្រជុំរបស់គណៈអភិបាល គឺជាកិច្ចប្រជុំរវាងអភិបាល និងអភិបាលរង នៅក្នុងគណៈអភិបាលខ្លួន។ គណៈអភិបាលត្រូវជួបជុំគ្នាជាទៀងទាត់ប្រចាំអឌ្ឍមាស។ ការប្រជុំអឌ្ឍមាសទី២នៃខែនីមួយៗគឺជាកិច្ចប្រជុំប្រចាំខែ។ ក្រៅពីការប្រជុំប្រចាំអឌ្ឍមាស និងការប្រជុំប្រចាំខែ គណៈអភិបាលអាចជួបជុំប្រជុំតាមការចាំបាច់ ទៅតាមសំណើររបស់អភិបាល។ អភិបាល គឺជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ។ ក្នុងករណីអភិបាលអវត្តមាន អភិបាលស្តីទី ជាអ្នកកោះប្រជុំ និងជា អធិបតីនៃអង្គប្រជុំគ្រប់កិច្ចប្រជុំរបស់គណៈអភិបាលត្រូវមានកំណត់ហេតុ ដែលរៀបចំឡើងដោយ នាយករដ្ឋបាល និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

អភិបាល អាចអញ្ជើញអ្នកពាក់ព័ន្ធនានាចូលរួម កិច្ចប្រជុំគណៈអភិបាលរបស់ខ្លួនតាមការចាំបាច់។ នាយករដ្ឋបាល និងនាយករងរដ្ឋបាល មានភារកិច្ចចូលរួមគ្រប់កិច្ចប្រជុំរបស់គណៈអភិបាលទាំងអស់ ដើម្បីផ្តល់យោបល់បច្ចេកទេសផ្នែកច្បាប់ ទៅតាមការស្នើសុំ។

រាល់សេចក្តីសម្រេចទាំងអស់របស់គណៈអភិបាលអាចយកជាការបាន លុះត្រាតែមានសំឡេងអនុម័តលើសពីពាក់កណ្តាលនៃសមាសភាពគណៈអភិបាលទាំងមូល។ ក្នុងករណីមានសំឡេង ស្មើគ្នាសំឡេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព។

### ៣.១.៣. កិច្ចប្រជុំគណៈកម្មាធិការ

#### ក. កិច្ចប្រជុំគណៈកម្មាធិការសម្រួលបច្ចេកទេស

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ត្រូវរៀបចំ កិច្ចប្រជុំវិសាមញ្ញ របស់ខ្លួនអោយបានទៀងទាត់ យ៉ាងតិច ០២ខែម្តង និងអាចរៀបចំកិច្ចប្រជុំវិសាមញ្ញទៅតាមការចាំបាច់។ កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ត្រូវធ្វើឡើង ជាសាធារណៈ លើកលែងតែរបៀបវារៈណាមួយដែលតម្រូវអោយមានការប្រជុំពិភាក្សាដោយសម្ងាត់។

កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស អាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកលើសពី ពាក់កណ្ដាល នៃចំនួនសមាជិកគណៈកម្មាធិការទាំងមូល។

សេចក្ដីសម្រេចនៃកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសអាចយកជាការបាន លុះត្រាតែមានសំឡេង អនុម័តលើសពីពាក់កណ្ដាលនៃ ចំនួនសមាជិកទាំងមូល។ ក្នុងករណីសម្លេងស្មើគ្នា សំឡេងរបស់អធិបតីអង្គប្រជុំមានឧត្តមានុភាព។

ប្រធានគណៈកម្មាធិការ ជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ។ គ្រប់កិច្ចប្រជុំគណៈកម្មាធិការ ត្រូវមានកំណត់ហេតុដែលរៀបចំដោយនាយករដ្ឋបាល និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

**ខ. កិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ**

កិច្ចប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ អាចធ្វើឡើងប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ។ កិច្ចប្រជុំវិសាមញ្ញរបស់ខ្លួន អាចធ្វើឡើងនៅពេលណាមួយតាមការចាំបាច់ ដើម្បីពិភាក្សាលើបញ្ហាពិសេស ឬបន្ទាន់ណាមួយ តាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មាធិការ ឬតាមសំណើររបស់ក្រុមប្រឹក្សា ឬតាមសំណើររបស់អភិបាលឬតាមសំណើរសមាជិកគណៈកម្មាធិការ មួយភាគបី (១/៣) នៃសមាជិកគណៈកម្មាធិការទាំងមូល។

កិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ត្រូវធ្វើឡើងជាសាធារណៈ លើកលែងតែរបៀបវារៈណាមួយដែលតម្រូវអោយមានការប្រជុំពិភាក្សាដោយសម្ងាត់។

កិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ អាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកលើសពី ពាក់កណ្ដាល នៃចំនួនសមាជិកគណៈកម្មាធិការទាំងមូល។

សេចក្ដីសម្រេចនៃកិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ អាចយកជាការបាន លុះត្រាតែមានសំឡេង អនុម័តលើសពីពាក់កណ្ដាលនៃចំនួនសមាជិកទាំងមូល។ ក្នុងករណីសម្លេង ស្មើគ្នា សំឡេងរបស់អធិបតីអង្គប្រជុំមានឧត្តមានុភាព។

ប្រធានគណៈកម្មាធិការ ជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ។ ក្នុងករណីប្រធានអវត្តមាន ប្រធានស្ដីជាអ្នកកោះប្រជុំ និងជាអធិបតីនៃបអង្គប្រជុំ។ គ្រប់កិច្ចប្រជុំគណៈកម្មាធិការ ត្រូវមានកំណត់ហេតុដែលរៀបចំដោយ អនុប្រធានអចិន្ត្រៃនៃគណៈកម្មាធិការ និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

**គ. កិច្ចប្រជុំគណៈកម្មាធិការលទ្ធកម្ម**

គណៈកម្មាធិការលទ្ធកម្ម ត្រូវរៀបចំកិច្ចប្រជុំខ្លួន ទៅតាមការជាក់ស្តែងនៃរដ្ឋបាលនីមួយៗ ពាក់ព័ន្ធនឹងការងារលទ្ធកម្ម។

សេចក្តីសម្រេចនៃ កិច្ចប្រជុំគណៈកម្មាធិការអាចយកជាការបាន លុះត្រាតែមានសំឡេងអនុម័តភាគច្រើន។ ក្នុងករណីសម្លេង ស្មើគ្នា សំឡេងរបស់អធិបតីអង្គប្រជុំមានឧត្តមានុភាព។

សមាជិកគណៈកម្មាធិការទាំងអស់ត្រូវ ចូលរួមប្រជុំតាមការអញ្ជើញរបស់ ប្រធានគណៈកម្មាធិការ។ ដំណើរការនៃកិច្ចប្រជុំ ត្រូវអនុវត្តតាមនីតិវិធី ដែលមានក្នុងលិខិតបទដ្ឋានគតិយុត្តិទាក់ទងកិច្ចលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត។

អង្គភាពលទ្ធកម្មមានតួនាទីក្នុងការរៀបចំនូវរាល់កិច្ចប្រជុំរបស់គណៈកម្មាធិការលទ្ធកម្ម។

**៣.១.៤. កិច្ចប្រជុំអន្តរទីចាត់ការ**

កិច្ចប្រជុំអន្តរទីចាត់ការ នៅរដ្ឋបាលរាជធានី ខេត្ត ដែលសមាសភាព ចូលរួមកិច្ចប្រជុំនេះរួម មាននាយករដ្ឋបាល នាយករងរដ្ឋបាល នាយកទីចាត់ការ នាយករងទីចាត់ការ ប្រធានអង្គភាព និង អនុប្រធានអង្គភាពទាំងអស់ចំណុះរដ្ឋបាលរាជធានី ខេត្ត។

នាយករដ្ឋបាលជាអ្នកកោះប្រជុំ និងជាអធិបតីភាពនៃអង្គប្រជុំ។ ក្នុងករណីនាយករដ្ឋបាល អវត្ត-មាននាយករដ្ឋបាលស្តីទី ជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ។ នាយករដ្ឋបាលអាចអញ្ជើញអ្នកពាក់ព័ន្ធនានា ចូលរួមកិច្ចប្រជុំ តាមការចាំបាច់។

កិច្ចប្រជុំនេះត្រូវធ្វើឡើងទៀងទាត់រាល់ខែ។ ក្រៅពីប្រចាំខែ នាយករដ្ឋបាលអាចកោះប្រជុំកិច្ចប្រជុំនេះ តាមការចាំបាច់។ នាយករដ្ឋបាលត្រូវកំណត់កាលវិភាគ និងពេលវេលានៃកិច្ចប្រជុំប្រចាំឆ្នាំនីមួយៗ ។

គោលបំណងនៃកិច្ចប្រជុំ គឺដើម្បី[35] ៖

- ចាត់ចែងការអនុវត្តសេចក្តីសម្រេច និងអនុសាសន៍របស់ក្រុមប្រឹក្សា គណៈអភិបាល គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា។
- ពិនិត្យលទ្ធផល និងបញ្ហាប្រឈមក្នុងការអនុវត្ត ការងារ
- ពិនិត្យ និងដោះស្រាយបញ្ហាប្រឈមនានាដែលកើតមានឡើងក្នុងការអនុវត្តការងារ
- រៀបចំផែនការការងារ ឬទិសដៅការងារសម្រាប់អង្គភាពនីមួយៗ
- លើកយោបល់ និងអនុសាសន៍ ជូនថ្នាក់ដឹកនាំតាមឋានានុក្រមពិនិត្យ និងដោះស្រាយ ។

[35] ដូច 33 ,ទំព័រ១៧៩។

### ៣.១.៥. កិច្ចប្រជុំផ្ទៃក្នុងទីចាត់ការ

កិច្ចប្រជុំផ្ទៃក្នុងអង្គភាព គឺជាកិច្ចប្រជុំនៅក្នុងទីចាត់ការ អង្គភាពនីមួយៗ ចំណុះ រដ្ឋបាលរាជធានី ខេត្ត។ កិច្ចប្រជុំ ត្រូវរៀបចំឡើងជាទៀងទាត់ប្រចាំខែ។ ប្រធានអង្គភាព នីមួយៗត្រូវកំណត់កាលវិភាគ និងពេលវេលា នៃកិច្ចប្រជុំប្រចាំខែសម្រាប់ឆ្នាំនីមួយៗ ដើម្បីអោយមន្ត្រីក្រោមឱវាទទាំងអស់អាចត្រៀមលក្ខណៈចូលរួមប្រជុំបានគ្រប់គ្នា។

## ៣.២. លិខិតបទដ្ឋានគតិយុត្ត

លិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលរាជធានី ខេត្ត គឺជាលិខិតដែលកំណត់នូវវិធាន បទប្បញ្ញត្តិ បទបញ្ជា ឬគោលការណ៍នានា សម្រាប់ការគ្រប់គ្រង ការតែងតាំង ការបង្កើតឡើងនូវយន្តការ និងការណែនាំអនុវត្តនានា។

លិខិតបទដ្ឋានបទដ្ឋានទាំងនេះរួមមាន ដីកា សេចក្តីសម្រេច និងសេចក្តីណែនាំ។

### ៣.២.១. ដីកា

ដីកា គឺជាវិធានខាងផ្លូវច្បាប់ មានលក្ខណៈជាបទបញ្ញាទូទៅ ឬមានលក្ខណៈជាឯកត្តភូត ដែលអនុម័តដោយ ក្រុមប្រឹក្សាក្នុងដែននៃសិទ្ធិអំណាចរបស់ខ្លួន សម្រាប់អនុវត្តកិច្ចការ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន [36] ។ នៅក្នុងរដ្ឋបាលរាជធានី ខេត្ត គឺជាលិខិតបទដ្ឋានគតិយុត្តដែលមានលំដាប់ខ្ពស់ជាងគេសម្រាប់គ្រប់គ្រងនិងដោះស្រាយបញ្ហាជាក់លាក់ណាមួយ។

ដីការមាន ពីរ(២)ប្រភេទ គឺជាដីកាដែលមានលក្ខណៈជាបទបញ្ញាទូទៅ និងដីកាដែលមានលក្ខណៈជាឯកត្តភូត [37] ។

#### ក. ដីកាដែលមានលក្ខណៈជាបទបញ្ញាទូទៅ

ដីកាដែលមានលក្ខណៈជាបទបញ្ញាទូទៅ គឺជាការណែនាំការអនុវត្ត ឬការបញ្ជាក់បន្ថែមខ្លឹម សាររបស់ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាស និងការណែនាំអនុវត្តកិច្ចការដែលស្ថិតក្នុងដែន សមត្ថកិច្ចរបស់ក្រុមប្រឹក្សា។

ក្រុមប្រឹក្សា ប្រើប្រាស់សិទ្ធិអំណាចខាងប្បញ្ញត្តិ តាមរយៈការដាក់ចេញដីកា ការកែប្រែ និងការលុបចោលដីកាស្របតាមនីតិវីធីជាធរមាន។

ក្រុមប្រឹក្សាមានសិទ្ធិដាក់ចេញដីកា ដែលស្ថិតក្នុងវិសាលភាពនៃ ៖

- តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា

---

[36] ដូច 33, ទំព័រ៣២។

[37] ដូច 33, ទំព័រ៣២។

- មុខងារ និងឬធនធានដែលប្រគល់ទៅអោយក្រុមប្រឹក្សា
- មុខងារ និងឬធនធានដែលបានធ្វើប្រតិភូកម្មទៅក្រុមប្រឹក្សា ក្នុងករណីដែលការធ្វើប្រតិភូកម្មនោះមិនកំណត់ដោយផ្នែកខ្លះ ឬទាំងស្រុងនូវសិទ្ធិក្នុងការអនុម័តដីកា

កិច្ចការណាមួយដែលច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន ដែលតម្រូវអោយក្រុមប្រឹក្សាដាក់ចេញដីកា។

ក្នុងគោលការណ៍ដាក់ចេញនូវដីកាបទបញ្ជាទូទៅ ត្រូវគោរពតាមគោលកាណ៍សំខាន់[38] ៖

- ដីកាបទបញ្ជាទូទៅ ត្រូវអនុម័តដោយក្រុមប្រឹក្សា និងចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សា
- ដីកាបទបញ្ជាទូទៅ ណាមួយដែលមានខ្លឹមសារផ្ទុយពីរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជ-ក្រឹត្យ អនុក្រឹត្យ ប្រកាស ឬលិខិតបទដ្ឋានគតិយុត្តនានាដែលមានឋានានុក្រមខ្ពស់ ជាងដីកានោះនឹងពុំមានសុពលភាពឡើយ
- ដីការបទបញ្ជាទូទៅ ណាមួយដែលធ្វើឡើងដោយមាន ការរើសអើង ក្នុងន័យជាអវិជ្ជមាន ឬអនុវត្តចំពោះបុគ្គលណាម្នាក់ ឬក្រុមណាមួយដោយផ្អែកលើកត្តាជាតិ សាសន៍ សាសនា ភេទ អាយុ ពណ៌សម្បុរ ជាតិឬជាតិកំណើត ឬអសមត្ថភាពខាងស្មារតី ឬខាងកាយសម្បទា ដីកានោះនឹងពុំមានសុពលភាពឡើយ។

ក្រុមប្រឹក្សាត្រូវធានាអោយមានការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានាក្នុងដំណើរការរៀបចំដីកាបទបញ្ជាទូទៅ លើកលែងតែក្នុងករណីចាំបាច់ដែលតម្រូវ អោយក្រុមប្រឹក្សាចេញនូវដីកាបទបញ្ជាទូទៅ ដើម្បីដោះស្រាយ ឬចាត់វិធានការបន្ទាន់ ។

ដីកាបទបញ្ជាទូទៅ ដែលអនុម័តរួច ត្រូវចូលជាធរមាននៅថ្ងៃដែលដីនោះត្រូវបានចុះហត្ថលេខា ឬអាចកំណត់យកកាលបរិច្ឆេទណាមួយនាពេលអនាគតសម្រាប់ការ ចូលជាធរមាននូវដីកាទាំងមូល ឬផ្នែកខ្លះនៃដីកា។ ដីកាបទបញ្ជាទូទៅ មិនមានអនុភាពប្រតិសកម្មឡើយ។

រដ្ឋបាលរាជធានីខេត្ត ត្រូវបញ្ជូននូវរាល់ដីកា ដែលបានអនុម័តដោយក្រុមប្រឹក្សារបស់ខ្លួនទៅក្រសួងមហាផ្ទៃយ៉ាងយូរ ប្រាំថ្ងៃ(៥)ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ផ្តើមពីថ្ងៃចេញដីកាដើម្បីពិនិត្យនីត្យានុកូលភាព។ ក្រសួងមហាផ្ទៃត្រូវសហការជាមួយក្រសួង ស្ថាប័ននានាដើម្បីសហការពិនិត្យលើដីការបស់ក្រុមប្រឹក្សារាជធានីខេត្ត។

[38] ដូច 33 ,ទំព័រ៣៣។

ក្នុងករណីពិនិត្យឃើញ ក្រសួងមហាផ្ទៃត្រូវជូនដំណឹង ជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សា រាជធានី ខេត្តដែលចេញដីកានេះ ដោយបញ្ជាក់ហេតុផល ឬចំណុចដែលផ្ទុយពីបទប្បញ្ញត្តិណាមួយ នៃរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមានដើម្បីអោយក្រុមប្រឹក្សាធ្វើការកែតម្រូវ។

ក្រោយទទួលបានសេចក្តីជូនដំណឹង ក្រុមប្រឹក្សាត្រូវណែនាំអោយអង្គភាពទទួលភារកិច្ចធ្វើសេចក្តីព្រាងដីកា នេះកែសម្រួលក្នុងកំឡុងពេល សាមសិប(៣០)ថ្ងៃ នៃថ្ងៃធ្វើការ។ ហើយដាក់ជូនគណៈអភិបាល និងក្រុមប្រឹក្សារាជធានី ខេត្ត ពិនិត្យ និងអនុម័តឡើងវិញនូវចំណុចកែតម្រូវនេះ ដោយចេញនូវដីកាកែសម្រួល។ ករណីដែលមិនបានធ្វើការកែតម្រូវតាមការណែនាំ នោះក្រសួងមហាផ្ទៃអាចចាត់វិធានការចាំបាច់នានាដើម្បី អោយមានការកែសម្រួល ឬលុបចោលដីកានោះ។

ក្រុមប្រឹក្សាអាចកែសម្រួល ឬលុបចោលដីកាណាមួយរបស់ខ្លួនបាន ដោយផ្អែកតាមស្ថានភាពបញ្ហា តម្រូវការ ឬសំណូមពរពីមូលដ្ឋាន និងដោយផ្អែកតាមការច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ឬលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬតាមការណែនាំពីក្រសួងរបស់រាជរដ្ឋាភិបាល។ ការកែប្រែដីកា អាចធ្វើឡើងដោយបន្ថែមប្រការថ្មី ឬកែប្រែប្រការណាមួយនៃ ដីកាដែលមានស្រាប់។ ក្រុមប្រឹក្សាអាចសម្រេចលុបចោលដីណាមួយ តាមរយៈដីការបស់ខ្លួន។

**ខ. ដីកាដែលមានលក្ខណៈជាឯកត្តភូត**

ដីកាដែលមានលក្ខណៈជាឯកត្តភូត គឺជាដីកាដែលទាក់ទង ឬសំដៅចំឈ្មោះបុគ្គលក្នុងការតែងតាំង ឬប្រគល់ភារកិច្ច ឬការផ្លាស់ប្តូរ ឬការបញ្ចប់ភារកិច្ចរបស់បុគ្គលិកណាម្នាក់។ ដីកាដែលមានលក្ខណៈឯកត្តភូតត្រូវអនុម័តដោយក្រុមប្រឹក្សា និងចុះហត្ថលេខាដោយអភិបាល។

### ៣.២.២. សេចក្តីសម្រេច

សេចក្តីសម្រេច គឺជាលិខិតបទដ្ឋានគតិយុត្ត ដែលចេញដោយរដ្ឋបាលរាជធានី ខេត្ត ដោយផ្អែកលើ មូលដ្ឋានច្បាប់ លិខិតបទដ្ឋានគតិយុត្តថ្នាក់ជាតិ ដីការបស់ក្រុមប្រឹក្សា ឬតម្រូវការរបស់មូលដ្ឋាន ក្នុងការសម្រេចកិច្ចការអ្វីមួយដែលមានលក្ខណៈ មិនស្ថិតស្ថេរ យូរអង្វែង ។

ការដាក់ចេញសេចក្តីសម្រេច [39]គឺ៖

- អនុវត្តខ្លឹមសាររបស់ដីកា និងលិខិតបទដ្ឋានថ្នាក់ជាតិ
- ណែនាំអនុវត្ត កិច្ចការណាមួយដែលស្ថិតក្នុងសិទ្ធិអំណាច និងសមត្ថកិច្ចរស់ខ្លួន

[39] ដូច 33,ទំព័រ៦០។

- បង្កើតឡើងនូវគណៈកម្មាធិការ អនុគណៈកម្មាធិការ គណៈកម្មការ និងការងាររបស់រដ្ឋបាលរាជធានី ខេត្ត
- ប្រគល់ភារកិច្ចជូនថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិករបស់រដ្ឋបាលរាជធានី ខេត្ត

សេចក្តីសម្រេច ដែលផ្ទុយនឹងខ្លឹមសារនៃរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស លិខិតបទដ្ឋានគតិយុត្តថ្នាក់ជាតិ ឬដីការបស់ក្រុមប្រឹក្សាខ្លួន នោះនឹងពុំមានសុពលភាពឡើយ ។

### ៣.២.៣. សេចក្តីណែនាំ

សេចក្តីណែនាំ គឺជាលិខិតបទដ្ឋានគតិយុត្តមួយប្រភេទ ដែលរដ្ឋបាលរាជធានី ខេត្ត រៀបចំ ឡើង ដើម្បីណែនាំ ឬកំណត់អំពីបែបបទនីតិវិធីអនុវត្តនានាសម្រាប់បម្រើ ផលប្រយោជន៍សាធារណៈ [40] ។ តម្រូវការនៃការដាក់ចេញសេចក្តីណែនាំ ត្រូវបានកំណត់ដោយផ្អែកតាម លិខិតបទដ្ឋានគតិយុត្តរបស់ថ្នាក់ជាតិ ឬដីកា និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ឬតម្រូវការក្នុងមូលដ្ឋាន។ ការដាក់ចេញ សេចក្តីណែនាំ ផ្អែកតាមតម្រូវការក្នុងមូលដ្ឋាន ត្រូវសម្រេចដោយ អភិបាលរាជធានី ខេត្ត។

## ៣.៣. ការផ្ទេរសិទ្ធិ

ការផ្ទេរសិទ្ធិ គឺជាការផ្ទេរការទទួលខុសត្រូវ ជាលាយលក្ខណ៍អក្សររបស់បុគ្គលណាម្នាក់ ដែលមានមុខតំណែងដឹកនាំក្នុងអង្គភាព ទៅអោយបុគ្គលម្នាក់ទៀតដែលមានមុខតំណែងបន្ទាប់ ដើម្បីបន្តនិរន្តភាពដឹកនាំ និងចាត់ចែងការងារប្រចាំថ្ងៃជំនួស ក្នុងពេលខ្លួនអវត្តមាន ដោយត្រូវកំណត់ អំពីពេលវេលា និងឬសមត្ថកិច្ចច្បាស់លាស់[41] ។ អ្នកដែលត្រូវធ្វើការផ្ទេរសិទ្ធិអវត្តមានចាប់ពី មួយ(១)ថ្ងៃឡើងទៅ ត្រូវធ្វើការផ្ទេរសិទ្ធិ។

### ៣.៣.១.ការផ្ទេរសិទ្ធិដោយស្វ័យប្រវត្តិធ្វើជាអធិបតីអង្គប្រជុំក្រុមប្រឹក្សា

ក្នុងករណីអវត្តមានប្រធានក្រុមប្រឹក្សា សមាជិកដែលស្ថិតនៅ លេខរៀងលំដាប់បន្តបន្ទាប់នៃ បញ្ជីបេក្ខជន ជាមួយប្រធានក្រុមប្រឹក្សា ត្រូវធ្វើជាប្រធានអង្គប្រជុំ។

ករណីដែលសមាជិកក្រុមប្រឹក្សា ដែលស្ថិតនៅលេខរៀងលំដាប់បន្ទាប់ ជាមួយប្រធានក្រុមប្រឹក្សាអវត្តមានសមាជិកក្រុមប្រឹក្សាដែលស្ថិតនៅលេខរៀងលើគេនៃបញ្ជីបេក្ខជនជាប់ឆ្នោតលំដាប់លេខ ២ ត្រូវធ្វើជាប្រធានក្រុមប្រឹក្ស អង្គប្រជុំ។

[40] ដូច 33, ទំព័រ៧៥។

[41] ដូច 33, ទំព័រ១០៣។

### ៣.៣.២. ការផ្ទេរសិទ្ធិរបស់ប្រធានគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា

ក្នុងករណីប្រធានគណៈកម្មាធិការអវត្តមាន ឬពុំអាចបំពេញការងារបានប្រធានគណៈកម្មាធិការ អាចផ្ទេរសិទ្ធិអោយទៅអនុប្រធាន ឬសមាជិកណាម្នាក់បាន អាស្រ័យទៅនឹងការកំណត់នៅក្នុងសេចក្តីសម្រេចស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការនោះ។

ករណីដែលប្រធានក្រុមប្រឹក្សាពុំបានផ្ទេរសិទ្ធិ ហើយសេចក្តីសម្រេចស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការនោះ ពុំបានកំណត់អំពីអ្នកទទួលសិទ្ធិដោយស្វ័យប្រវត្តិ ក្រុមប្រឹក្សាត្រូវប្រជុំសម្រេចប្រគល់សិទ្ធិអោយទៅអនុប្រធាន ឬសមាជិកណាម្នាក់ ដើម្បីដឹកនាំ និងចាត់ចែងការងាររបស់គណៈកម្មាធិការនោះ។

### ៣.៣.៣. ការផ្ទេរសិទ្ធិរបស់អភិបាល

ក្នុងករណីអភិបាលអវត្តមាន អភិបាល ត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរជូនអភិបាលរងមួយរូបនៅក្នុង គណៈអភិបាលរបស់ខ្លួន អោយទទួលសិទ្ធិជាអភិបាលស្តីទី ដើម្បីធានានិរន្តភាពការងាររដ្ឋបាលរាជធានី ខេត្ត។ អភិបាលរង ដែលទទួលការផ្ទេរសិទ្ធិ ពុំមានសិទ្ធិក្នុងការផ្ទេរសិទ្ធិបន្តទៅអោយអភិបាលរងណាមួយក្នុងគណៈអភិបាលរបស់ខ្លួនបានឡើយ។

ការផ្ទេរសិទ្ធិរបស់អភិបាលរាជធានី ខេត្ត ត្រូវចម្លងជូនគ្រប់អង្គភាពចំណុះរដ្ឋបាលរាជធានី ខេត្ត មន្ទីរ អង្គភាពជំនាញជុំវិញរាជធានី ខេត្ត និងក្រសួងមហាផ្ទៃ។ ប្រសិនអភិបាលអវត្តមានដោយមិនបានផ្ទេរសិទ្ធិ អភិបាលរងដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃអនុក្រឹត្យ តែងតាំងអភិបាលរងនៃគណៈអភិបាលនេះ ត្រូវបានផ្លាស់ចេញ ឬអវត្តមាន អភិបាលរងដែលនៅលំដាប់លេខរៀងបន្ទាប់ត្រូវផ្តល់អាទិភាពសម្រាប់ធ្វើជាអភិបាលស្តីទី។

ក្នុងករណីអភិបាលស្តីទីអវត្តមាន នាយករដ្ឋបាលរាធានី ខេត្ត ត្រូវធ្វើសេចក្តីរាយការណ៍ជាបន្ទាន់ជូនក្រសួងមហាផ្ទៃ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញប្រកាសដើម្បីប្រគល់ភារកិច្ចជូនអភិបាលរងរាជធានី ខេត្ត មួយរូប អោយទទួលជាអភិបាលស្តីទី។ អភិបាលស្តីទីត្រូវរាយការណ៍រាល់កិច្ចការដែលបានអនុវត្តជូនអភិបាល នៅពេលដែលអភិបាលមានវត្តមានវិញ។

## ៣.៤. ការប្រគល់សិទ្ធិចុះហត្ថលេខា

ជាគោលការណ៍ អភិបាល ជាអ្នកចុះហត្ថលេខាលើ លិខិតទាំងអស់របស់រដ្ឋបាលខ្លួន លើកលែង តែលិខិតដែលតម្រូវអោយប្រធានក្រុមប្រឹក្សា និងប្រធានគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាចុះហត្ថលេខា ទៅតាមការកំណត់របស់ច្បាប់ និងការសម្រេចរបស់ក្រុមប្រឹក្សាប៉ុណ្ណោះ។

អភិបាលអាចប្រគល់សិទ្ធិដល់ អភិបាលរងនានាក្នុងគណៈអភិបាលរបស់ខ្លួន ក្នុងការចុះហត្ថលេខាលើលិខិតចាំបាច់មួយចំនួនរបស់រដ្ឋបាលខ្លួន ក្នុងក្របខ័ណ្ឌនៃភារកិច្ចដែលបានបែងចែកជូនអភិបាលរងនីមួយៗ។ ការប្រគល់សិទ្ធិចុះហត្ថលេខា នេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។

អភិបាលត្រូវទទួលខុសត្រូវអំពីភាពត្រឹមត្រូវតាមច្បាប់ និងបែបបទ នីតិវិធីចំពោះលិខិតដែលបានប្រគល់សិទ្ធិចុះហត្ថលេខាដល់អភិបាលរងនោះ។ អភិបាល មានសិទ្ធិដកហូតមកវិញនូវសិទ្ធិចុះហត្ថលេខាពីអភិបាលរងណាមួយដែលប្រើប្រាស់អំណាចនេះ មិនស្របច្បាប់ និងមិនស្របបែបបទនីតិវិធី ។ ការប្រគល់ និងការដកហូតមកវិញនូវសិទ្ធិចុះហត្ថលេខានេះ អភិបាលត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន។ ក្រៅពីនេះ អភិបាលអាចប្រគល់សិទ្ធិដល់នាយករដ្ឋបាល ក្នុងការចុះហត្ថលេខាលើកិច្ចការមួយចំនួនដែលអភិបាលបានសម្រេចរួចហើយ។ ការប្រគល់សិទ្ធិចុះហត្ថលេខានេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ ការចុះហត្ថលេខានេះ ហៅថាការចុះហត្ថលេខាតាមបញ្ជារបស់អភិបាល ។

## ៣.៥. ការផ្តល់សេវាសាធារណៈនៅរាជធានីខេត្ត

សេវារដ្ឋបាល ដែលផ្តល់ដោយរដ្ឋបាលថ្នាក់រាជធានី ខេត្ត ត្រូវបានរៀបចំជាកម្រងរដ្ឋបាលដែលមានរាយលម្អិត អំពីតម្លៃសេវារយៈពេលអតិបរមានៃការផ្តល់សេវា និងសុពលភាពទៅតាមប្រភេទសេវារដ្ឋបាលនីមួយៗ។ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់រាជធានី ខេត្ត ត្រូវដាក់ចេញនូវដីកាដើម្បី កំណត់សេវារដ្ឋបាលជាក់ស្តែង សម្រាប់ប្រតិបត្តិក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយផ្អែកតាមស្ថានភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ប៉ុន្តែមិនត្រូវលើសពីតម្លៃអតិបរមាដែលបានកំណត់ដោយប្រកាសក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនោះទេ។ ចំពោះតម្លៃសេវាដែលបានកំណត់ជាក់លាក់ហើយនេះ ក្រុមប្រឹក្សារាជធានីខេត្ត មិនអាចសុំកែសម្រួលបាននោះទេ។ រដ្ឋបាលរាជធានី ខេត្តមានភារកិច្ចប្រមូលចំណូល ទទួលខុសត្រូវប្រាក់ចំណូលដែលប្រមូល បានពីកម្រៃនៃសេវារដ្ឋបាលរបស់ខ្លួន។

## តារាងទី៥៖ គំរូតម្លៃសេវារដ្ឋបាលថ្នាក់រាជធានី ខេត្ត ៖

តារាងឧបសម្ព័ន្ធ

ភ្ជាប់នឹងអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ [illegible] ឆ្នាំ២០១៦ ស្ដីពីការផ្ដល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ក. រដ្ឋបាលរាជធានី ខេត្ត

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | | រយៈពេលអតិបរមា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|---|
| | | តម្លៃអតិបរមា | តម្លៃជាក់លាក់ | | | |
| **១. [illegible] (ការបញ្ជាក់លើឯកសារផ្សេងៗ)** | | | | | | |
| ១ | សេចក្ដីអនុញ្ញាតឱ្យប្រកបអាជីវកម្ម [illegible] | ២០ ០០០ | | ៥ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |
| ២ | លក្ខន្តិកៈក្រុមហ៊ុនអាជីវកម្ម [illegible] វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុន លិខិតក្រសួងពាណិជ្ជកម្ម [illegible] | ១០ ០០០ | | ៥ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |
| ៣ | [illegible] | ២ ០០០ | | ៥ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |
| ៤ | វិញ្ញាបនបត្របញ្ជាក់ម្ចាស់កម្មសិទ្ធិអចលនវត្ថុ | ២ ០០០ | | ៥ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |
| ៥ | សញ្ញាបត្របញ្ជាក់ការសិក្សា (ក្នុងប្រទេស) | ២ ០០០ | | ៥ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |
| ៦ | សញ្ញាបត្រទុតិយភូមិសិក្សា | ២ ០០០ | | ៥ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |
| ៧ | លិខិតអនុញ្ញាតចុះបញ្ជីសមាគម សង្គម ព្រះវិហារសាសនា និងសហគមន៍ | ១ ០០០ | | ៥ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |
| ៨ | លិខិត ឬឯកសារផ្សេងៗទៀត (ដែលមិនមែនជាសមត្ថកិច្ចរបស់ស្ថាប័នណាមួយ) | ១ ០០០ | | ៥ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |
| **២. ការងាររដ្ឋបាល** | | | | | | |
| ១ | ការអនុញ្ញាតឱ្យជីកក្នុងផ្លូវ ឬតាមបណ្ដោយផ្លូវក្នុងរាជធានីភ្នំពេញ (ចំពោះ [illegible] ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសដូចដើម គឺជាភារកិច្ចរបស់ [illegible]) | ៥០០ ០០០ | | ១៥ ថ្ងៃ | កំណត់ពេល | ១ ច្បាប់ |
| ២ | ការអនុញ្ញាតឱ្យជីកក្នុងផ្លូវ ឬតាមបណ្ដោយផ្លូវក្នុងខេត្ត (ចំពោះ [illegible] ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសដូចដើម គឺជាភារកិច្ចរបស់ [illegible]) | ២០០ ០០០ | | ១៥ ថ្ងៃ | [illegible] | ១ ច្បាប់ |

ទំព័រទី ១ នៃ ៣១

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | | រយៈពេលអតិបរមា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|---|
| | | តម្លៃអតិបរមា | តម្លៃជាក់លាក់ | | | |
| ៣ | លិខិត/ប័ណ្ណឆ្លងព្រំដែន (laissez-passer) | | ២០ ០០០ | ៥ ថ្ងៃ | ១ លើក | ១ ច្បាប់ |
| ៤ | ការចេញលិខិតអនុញ្ញាតបំពេញអាចម៍ដីកម្មសិទ្ធិឯកជន | | | | | |
| ៤.១ | ដីក្នុងរាជធានីភ្នំពេញ ឬក្នុងក្រុងនៃខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | | | | | |
| | - ដីដែលមានទំហំចាប់ពី ១ ០០០ម៉ែត្រការ៉េ ដល់ក្រោម ៥ ០០០ម៉ែត្រការ៉េ | ៦០០ ០០០ | | ១០ ថ្ងៃ | | ១ ច្បាប់ |
| | - ដីដែលមានទំហំចាប់ពី ៥ ០០០ម៉ែត្រការ៉េ ដល់ក្រោម ១០ ០០០ម៉ែត្រការ៉េ | ៨០០ ០០០ | | ១០ ថ្ងៃ | | ១ ច្បាប់ |
| | - ដីដែលមានទំហំចាប់ពី ១០ ០០០ម៉ែត្រការ៉េឡើង | ១ ៦០០ ០០០ | | ១០ ថ្ងៃ | | ១ ច្បាប់ |
| ៤.២ | ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | | | | | |
| | - ដីដែលមានទំហំចាប់ពី ១ ០០០ម៉ែត្រការ៉េ ដល់ក្រោម ៥ ០០០ម៉ែត្រការ៉េ | ៣០០ ០០០ | | ១០ ថ្ងៃ | | ១ ច្បាប់ |
| | - ដីដែលមានទំហំចាប់ពី ៥ ០០០ម៉ែត្រការ៉េ ដល់ក្រោម ១០ ០០០ម៉ែត្រការ៉េ | ៤០០ ០០០ | | ១០ ថ្ងៃ | | ១ ច្បាប់ |
| | - ដីដែលមានទំហំចាប់ពី ១០ ០០០ម៉ែត្រការ៉េឡើង | ៨០០ ០០០ | | ១០ ថ្ងៃ | | ១ ច្បាប់ |
| ៥ | លិខិតអនុញ្ញាតទីតាំងចាំណតរថយន្ត (គិតក្នុង ១ម៉ែត្រការ៉េ) | ១០០ ០០០ | | ៤៥ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ៦ | ការចុះបញ្ជីវិនិយោគជាគម្រោងមានលក្ខណសម្បត្តិគ្រប់គ្រាន់នៅអនុគណៈ [illegible] វិនិយោគរាជធានី ខេត្ត (ទុនវិនិយោគក្រោម ២លានដុល្លារអាមេរិក) | | ៧ ០០០ ០០០ | ២៨ ថ្ងៃ | [illegible] | ១ ច្បាប់ |

ទំព័រទី ២ នៃ ៣១

តារាងទី៦៖ តម្លៃសេវាជាក់ស្តែងនៃរាជធានីភ្នំពេញ៖

## ការងារនិត្យានុកូលកម្ម

| ល.រ | បរិយាយ | តំលៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|
| ១ | សេចក្តីអនុញ្ញាតឲ្យប្រកបអាជីវកម្ម អាហារីណានិហារីណសណាគារ វិនិយោគទុនបរទេស | ២០.០០០ | ៥ថ្ងៃ | អចិន្ត្រៃយ៍ | ១ច្បាប់ |
| ២ | លក្ខន្តិកៈក្រុមហ៊ុនអាជីវកម្មនានា វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុន លិខិតក្រសួងពាណិជ្ជកម្មកិច្ចសន្យា | ១០.០០០ | ៥ថ្ងៃ | អចិន្ត្រៃយ៍ | ១ច្បាប់ |
| ៣ | ប្លង់សាងសង់ | ២.០០០ | ៥ថ្ងៃ | អចិន្ត្រៃយ៍ | ១ច្បាប់ |
| ៤ | ប័ណ្ណសាងសង់ | ២.០០០ | ៥ថ្ងៃ | អចិន្ត្រៃយ៍ | ១ច្បាប់ |
| ៥ | វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ កម្មសិទ្ធ លិខិតផ្ទេរសិទ្ធិ ឬផ្ទះ | ២.០០០ | ៥ថ្ងៃ | អចិន្ត្រៃយ៍ | ១ច្បាប់ |
| ៦ | សញ្ញាបត្រក្រោយឧត្តមសិក្សា | ២.០០០ | ៥ថ្ងៃ | អចិន្ត្រៃយ៍ | ១ច្បាប់ |
| ៧ | សញ្ញាបត្រពុទ្ធិកសិក្សា | ២.០០០ | ៥ថ្ងៃ | អចិន្ត្រៃយ៍ | ១ច្បាប់ |
| ៨ | លិខិតអនុញ្ញាតចុះបញ្ជីសមាគម អង្គការ ព្រះវិហារសាសនា និង សហគមន៍ | ១.០០០ | ៥ថ្ងៃ | អចិន្ត្រៃយ៍ | ១ច្បាប់ |
| ៩ | ប័ណ្ណបើកបររថយន្ត | ១.០០០ | ៥ថ្ងៃ | អចិន្ត្រៃយ៍ | ១ច្បាប់ |
| ១០ | លិខិត ឬឯកសារផ្សេងៗទៀត( ដែលមិនមែនជាសមត្ថកិច្ចរបស់ ស្ថាប័នណាមួយ ) | ១.០០០ | ៥ថ្ងៃ | អចិន្ត្រៃយ៍ | ១ច្បាប់ |

## ការងារវិនិយោគ

| ល.រ | បរិយាយ | តំលៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|
| ១ | ការចុះបញ្ជីវិនិយោគជាគម្រោងមានលក្ខណសម្បត្តិគ្រប់គ្រាន់នៅ អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត (ទុនវិនិយោគក្រោម ២លានដុល្លារអាមេរិក ) | ៧. ០០០,០០០ | ២៨ថ្ងៃ | ១ លើក | ១ច្បាប់ |

## ការងាររដ្ឋបាល

| ល.រ | បរិយាយ | តំលៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|
| ១ | ការអនុញ្ញាត ឲ្យជីកឆ្លងផ្លូវក្នុងរាជធានីភ្នំពេញ( ចំពោះការផុសជុល ផ្លូវឡើងវិញ ឲ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសដូចដើម គឺជា ភារកិច្ចរបស់អ្នកស្នើសុំ ) | ២០.០០០ | ៥ថ្ងៃ | ១លើក | ១ច្បាប់ |
| ២ | ការអនុញ្ញាត ឲ្យជីកឆ្លងផ្លូវក្នុងខេត្ត( ចំពោះការជុសជុលផ្លូវឡើង វិញឲ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសដូចដើមគឺជា ភារកិច្ចរបស់ អ្នកស្នើសុំ ) | ១០.០០០ | ៥ថ្ងៃ | ១លើក | ១ច្បាប់ |
| ៣ | លិខិត/ប័ណ្ណឆ្លងដែន( laissez-passer) | ២.០០០ | ៥ថ្ងៃ | ១លើក | ១ច្បាប់ |
| ៤ | ការចេញលិខិតអនុញ្ញាតបំពេញអាចម៍ដីកម្មសិទ្ធឯកជនក្រោម១ហិកតា | ២.០០០ | ៥ថ្ងៃ | ១លើក | ១ច្បាប់ |
| | – ដីក្នុងរាជធានីភ្នំពេញឬក្នុងក្រុងខេត្តកណ្តាល ខេត្តព្រះសីហនុនិងខេត្តសៀមរាប | ២.០០០ | ៥ថ្ងៃ | ១លើក | ១ច្បាប់ |
| | – ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | ១.០០០ | ៥ថ្ងៃ | ១លើក | ១ច្បាប់ |
| ៥ | ការចេញលើលិខិតស្នើសុំពំពេញអាចម៍ដីកម្មសិទ្ធឯកជន ចាប់ពី១ហិកតា ឡើងទៅ | ១.០០០ | ៥ថ្ងៃ | ១លើក | ១ច្បាប់ |
| | – ដីក្នុងរាជធានីភ្នំពេញឬក្នុងក្រុងនៃខេត្តកណ្តាល ខេត្តព្រះសីហនុនិងខេត្តសៀមរាប | ១.០០០ | ៥ថ្ងៃ | ១លើក | ១ច្បាប់ |
| | - ដីក្នុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | ១.០០០ | ៥ថ្ងៃ | ១លើក | ១ច្បាប់ |
| ៦ | លិខិតអនុញ្ញាតទីតាំងបំណាស្តអចល័ត ( គិតក្នុង ១ម៉ែតការ៉េ ) | ១.០០០ | ៥ថ្ងៃ | ១ឆ្នាំ | ១ច្បាប់ |

## ៣.៦ បញ្ហាប្រឈម

ទន្ទឹមនឹងការដាក់អោយអនុវត្តនូវការគ្រប់គ្រងរដ្ឋបាលថ្នាក់រាជធានី ខេត្ត មានផ្តល់នូវសារប្រយោជន៍ ហើយនេះ ក្នុងនេះដែរវាក៏នូវមានបញ្ហាប្រឈមមួយចំនួនផងដែរ ៖

ទី១ នីតិវិធីមួយចំនួនក្នុងការផ្តល់សេវានូវមានភាពស្មុគស្មាញ ប្រមូលផ្តុំ។ ទន្ទឹមនឹងការប្រើប្រាស់ព័តិមានវិទ្យាក្នុងការផ្តល់សេវានៅមានកម្រិត ។

ទី២ យន្តការ និងប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃគុណភាពនៃសេវាសាធារណៈ មិនទាន់បានដាក់អោយដំណើរការប្រេបកដោយប្រសិទ្ធិភាព ។

ទី៣ សមត្ថភាពធនធានមនុស្ស នៅរដ្ឋបាលថ្នាក់រាជធានីខេត្ត និងអង្គភាពពាក់ព័ន្ធ នៅមានកម្រិតក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។ ប្រព័ន្ធបៀវត្ស មិនទាន់ឆ្លើយតបនឹងចំណាយសម្រាប់ជីវភាពប្រចាំថ្ងៃរបស់មន្ត្រីរាជការ ។

ទី៥ ការកសាងផែនការអភិវឌ្ឍនៃសម្រាប់រាជធានី ខេត្តនៅមានកម្រិតដែលបណ្តាលមកពីកញ្ចប់ថវិកា និងការប្រមូលចំណូលពីការផ្តល់សេវា ។

ទី៦ ក្រុមប្រឹក្សា នៅមិនមែនទាន់ភាពច្បាស់លាស់ទាក់ទងទៅនឹងតួនាទី មុខងារ សមត្ថកិច្ចរបស់ខ្លួន ។ ចំនួននៃបុគ្គលិក ក៏ដូចជាមន្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅពុំទាន់មានភាពគ្រប់គ្រាន់។

## ៣.៧. ដំណោះស្រាយ

ក្រោយពីសង្កេតឃើញនូវបញ្ហាប្រឈមមួយចំនួនបានកើតឡើងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវផែនការសកម្មភាពមួយចំនួនដូចខាងក្រោម៖

ទី១ ការបង្កើតនូវការិយាល័ច្រកចេញចូលតែមួយ ដើម្បីលុបបំបាត់នូវការយកកម្រៃសេវាក្រៅផ្លូវការ និងមានទំនុកចិត្តប្រកបដោយប្រសិទ្ធិភាព។ ការធ្វើនូវប្រតិភូកម្មមុខងារពីបណ្តាលក្រសួងស្ថាប័នកាន់តែមានភាពសម្បូរបែប ដែលកាត់បន្ថយនូវការរង់ចាំរបស់ប្រជាពលរដ្ឋ និងធ្វើអោយការផ្តល់សេវានូវថ្នាក់រាជធានី ខេត្តកាន់តែមានប្រសិទ្ធិភាព ។

ទី២ រាជរដ្ឋាភិបាល បានកែសម្រួលប្រព័ន្ធបៀវត្ស របស់មន្ត្រីរាជការ និងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយបង្កើតអោយមាននូវ ព្រះរាជក្រឹត្យស្តីពី លក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ជាមួយគ្នានោះផងដែរក៏បាន រៀបចំតួនាទី ភារកិច្ច របៀបគ្រប់គ្រង និងចាត់ចែងការងារអោយមានភាពច្បាស់លាស់ ។ ហើយអនុញ្ញាតអោយរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិអំណាចក្នុងការរៀបចំជ្រើសរើសមន្ត្រីរាជការតាមជំនាញ និងចំនួនមន្ត្រីរាជការ ទៅតាមជំនាញដែលខ្លួនត្រូវការ ។

ទី៣ ពង្រឹងវិន័យ និងក្រមសីលធម៌របស់មន្រ្តីរាជការដោយកែប្រែទម្លាប់នៃការធ្វើការរបស់មន្រ្តីរាជការដែល តាំងខ្លួនជាអ្នកគ្រប់គ្រងរាស្រ្ត អោយ ទៅជាអ្នកបម្រើរាស្រ្ត ។

ទី៤ ក្រសួងស្ថាប័ននានា បានរៀបចំកម្មវិធីសិក្ខាសាលានានា ដើម្បីធ្វើការណែនាំដល់ក្រុមប្រឹក្សា សមាជិកក្រុមប្រឹក្សា គណៈអភិបាល និងមន្រ្តីរាជការពាក់ព័ន្ធទាំងអស់បន្ថែមទៅលើចំណេះដឹង និងរបៀបរបបការងារ ជាពិសេសក្រសួងមហាផ្ទៃ បានបង្កើតអោយមាននូវសៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

# សេចក្តីសន្និដ្ឋាន
# និង អនុសាសន៍

# សេចក្តីសន្និដ្ឋាន

ឆ្លងកាត់តាមការបកស្រាយខាងលើ យើងសង្កេតឃើញព្រះរាជាណាចក្រកម្ពុជា បានចាប់ផ្តើម ធ្វើកំណែទម្រង់វិស័យរដ្ឋបាលសាធារណៈ អោយកាន់តែស៊ីជម្រៅចាប់តាំងពីឆ្នាំ២០០៨ ដែលមកទល់នឹងបច្ចុប្បន្នមានរយៈកាល ៩ឆ្នាំមកហើយ។ ដែលនៅក្នុងរយៈកាល ៩ឆ្នាំនេះ ការគ្រប់គ្រងរដ្ឋបាលនៅថ្នាក់រាជធានី ខេត្ត សម្រេចបាននៅសមិទ្ធិផលជាច្រើន ហើយក៏មានចំនុចខ្វះខាតផងដែរ ។ រដ្ឋបាលរាជធានី ខេត្តមានការលំបាកក្នុងការអនុវត្តភារកិច្ចដែលបានធ្វើប្រតិភូកម្មដោយរាជរដ្ឋាភិបាល ក្រសួងស្ថាប័ន នៅថ្នាក់ជាតិដោយសារការមិនចូលរួមពេញលេញពីសំណាក់ភាគីដែល ពាក់ព័ន្ធ និងខ្វះខាតធនធានក្នុងការគាំទ្រ ។

សរុបសេចក្តីមក លទ្ធផលនៃការអនុវត្តដំណើរការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត នៅមិនទាន់មានភាពរលូន ១០០ភាគរយនេះទេ ដោយរដ្ឋបាលរាជធានី ខេត្ត មានភាពខ្វះខាតទៅលើចំណុចមួយចំនួនដូចជា (១) កត្តាធនធានហិរញ្ញវត្ថុ ដែលជាចំណុចសំខាន់មួយដោយហេតុថាកញ្ចប់ថវិកានៃការទទួលបានរបស់រដ្ឋបាលរាជធានី ខេត្តនៅមានកម្រិត ដែលជួនកាលមិនអាចបំពេញនូវការអនុវត្តនៅផែនការមួយចំនួនរបស់ខ្លួនបានដោយរលូន ដោយ ត្រូវរង់ចាំកញ្ចប់ថវិកានៃថ្នាក់ជាតិ ដែល នាំអោយមានការរាំងស្ទះ ដល់ការអនុវត្តគម្រោង ក៏ដូចជាការដោះស្រាយបញ្ហាអោយទាន់ពេលវេលាផងដែរ ។ (២) កត្តាធនធានមនុស្ស ថ្វីត្បិតតែរដ្ឋបាលរាជធានី ខេត្តមានសិទ្ធិជ្រើសរើសចាត់ចែង បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិទៅតាមតម្រូវការរបស់ខ្លួនក៏ពិតមែន ប៉ុន្តែរដ្ឋបាលថ្នាក់ក្រោមជាតិ ពុំសូវមានធនធានមនុស្ស សម្បូរបែប ដូចរដ្ឋបាល ថ្នាក់កណ្តាលនេះទេ ដែលជាទូទៅត្រូវរង់ចាំការបែងចែកធនធានមនុស្សពីថ្នាក់កណ្តាលមកវិញ ដើម្បីបម្រើការងារ ដែលវាអាចមានផលប៉ះពាល់មួយចំនួនដល់កិច្ចបម្រើការរបស់ខ្លួន និងសមត្ថភាព មន្ត្រីរាជការដែលមានស្រាប់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ មួយចំនួននៅមានកម្រិតសិក្សាទាប និងមានគំនិតអភិរក្សដែលសម្អាងលើបទពិសោធន៍ការងារដែលខ្លួនមាននានាពេលកន្លងមក ដោយមិនបានព្យាយាមអភិវឌ្ឍខ្លួនទៅតាមភាពរីកចម្រើននៃប្រទេស។ (៣) ការធ្វើប្រតិភូកម្មមុខងារ របស់ក្រសួងស្ថាប័ន នៅមានកម្រិត ដែលធ្វើអោយការផ្តល់សេវាសារធារណៈរបស់ រដ្ឋបាលថ្នាក់ក្រោមជាតិនៅមានកម្រិត និងការផ្ទេរនូវមុខងារពុំទាន់មានភាពច្បាស់លាស់។

# អនុសាសន៍

ផ្អែកលើសេចក្តីសន្និដ្ឋានខាងលើ កត្តាមួយចំនួនដែល អាចជួយបង្កើនដល់ការអភិវឌ្ឍន៍សមត្ថភាពរបស់ក្រុមប្រឹក្សារាជធានី ខេត្ត និងបុគ្គលិកនៃសាលារាជធានី ខេត្ត ដើម្បី អនុវត្ត អោយបានការផ្តល់នូវសេវាសាធារណៈប្រកបដោយប្រសិទ្ធិភាពនោះ ៖

- ក្រសួង ស្ថាប័ន ត្រូវធានាអោយមាននូវ ការផ្ទេរមុខងារយ៉ាងច្បាស់លាស់ពីក្រសួងស្ថាប័នទៅអោយ រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយនៅក្នុងនេះភ្ជាប់ជាមួយការផ្ទេរធនធាននានារួមទាំងធនធានមនុស្សនិងធនធានហិរញ្ញវត្ថុ ដើម្បីបង្វិតការផ្តល់សេវាអោយកាន់តែកៀកជិតប្រជា-ពលរដ្ឋ។ ដោយឡែកសិទ្ធិអំណាច និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សា និងគណៈអភិបាលក៏ចាំបាច់ត្រូវមានការបកស្រាយអោយបានច្បាស់លាស់ និងពង្រឹងបន្ថែមទៀតទាំងក្នុងក្របខណ្ឌលិខិតបទដ្ឋានគតិយុត្ត ក៏ដូចជាការអនុវត្តជាក់ស្តែង។ ការប្រាស្រ័យទាក់ទងគ្នា រវាងរដ្ឋបាលថ្នាក់រាជធានី ខេត្ត និងរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ និងអង្គភាពពាក់ព័ន្ធ ជាកត្តាមួយសំខាន់ជួយជំរុញអោយមាន អភិវឌ្ឍបានល្អប្រសើរ និងស្របតាមគោលដៅ ដែលរាជរដ្ឋាភិបាលចង់សម្រេចអោយបាន។
- មូលនិធិរាជធានី ខេត្ត ចាំបាច់ត្រូវមានថវិកាសមស្រប ដើម្បីផ្តល់លទ្ធភាពអោយរាជ-ធានី ខេត្ត អាចចូលរួមអភិវឌ្ឍតំបន់របស់ខ្លួន តាមរយៈមុខងារនូវអាណត្តិរបស់ខ្លួន ហើយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រាជធានី ខេត្ត ក៏ត្រូវធ្វើការកែលម្អ ដើម្បីធានាអោយការប្រើប្រាស់មូលនិធិនេះកាន់តែមានប្រសិទ្ធិភាព។ ទន្ទឹមនឹងនេះ យន្តការប្រមូលផ្ទាល់ក៏ត្រូវមានការរៀបចំកែសម្រួលផងដែរ ដែលអាចអោយរដ្ឋបាលរាជធានី ខេត្ត មានចំណូលបន្ថែមដើម្បីទ្រទ្រង់គម្រោងនិងការអនុវត្តកិច្ចការនានា។
- ការអភិវឌ្ឍសមត្ថភាពធនធានមនុស្សរបស់រដ្ឋបាលរាជធានី ខេត្ត គឺមានសារៈសំខាន់ណាស់ដែលតាមរយៈនេះ រាជរដ្ឋាភិបាលអាចបង្កើតអោយមាន មជ្ឈមណ្ឌលបណ្តុះបណ្តាលធនធានមនុស្សនៅតាមរាជធានី ខេត្ត ដែលប្រមូលនូវអ្នកដែលមានសមត្ថភាពក្នុងការចូលរួមអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិកនៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងចំណេះដឹងជំនាញការប្រើប្រាស់ព័ត៌មានវិទ្យា និងឥរិយាបថក្នុងនាមជាមន្ត្រីរាជការ រួមទាំងសមត្ថភាពជាអ្នកដឹកនាំផងដែរ ដើម្បីអោយពួកគាត់មានសមត្ថភាព ពេញលេញក្នុងការអនុវត្តការងារប្រកបដោយប្រសិទ្ធិភាព ៕

# ឯកសារយោង

# ឯកសារយោង

## ក. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត


រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃ២១ ខែកញ្ញា ឆ្នាំ១៩៩៣ ប្រកាសអោយប្រើនៅថ្ងៃ ២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ។

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, ២២ ឧសភា ២០០៨។

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខនស/រកម/០៥០៨/ ០១៨ , ២៤ ឧសភា ២០០៨។

ព្រះរាជក្រឹត្យស្តីពី លក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ, លេខនស/រកត/០៤១៦/ ៣៧៣, ០៤ មេសា ២០១៦។

ប្រកាសអន្តរក្រសួងស្តីពី ការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ, លេខ១៤៣៨២/ប្រក, ២៩ ធ្នូ ២០១៦។


## ខ. គោលនយោបាយ និងយុទ្ធសាស្ត្រជាតិ


យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ នៃរាជរដ្ឋាភិបាល អាណត្តិទី ៥

កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ឆ្នាំ២០១៥-២០១៨


## គ. សៀវភៅ និងបទបង្ហាញ


កៅ មុយថង, ម៉ី វិចិត្រ, វ៉ាន់ ច័ន្ទតារា, គង់ ជួរ, ទេព វិសុល, កែ វឌ្ឍរ៉ា, រៀបរៀង.២០០៨. *ប្រព័ន្ធរដ្ឋបាលកម្ពុជា.* ភ្នំពេញ៖ គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ។

កៅ មុយថង, រៀបរៀង. *ការគ្រប់គ្រងរដ្ឋបាលដែនដីនៅកម្ពុជា.* ២០១០. ភ្នំពេញ៖ គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ។

គណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ. ២០១៤ . *ផែនការអនុវត្តបីឆ្នាំដំណាក់កាលទីពីរ(២០១៥-២០១៧) នៃកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ (ផអ៣ទី២).* ភ្នំពេញ៖ ខែ ធ្នូ ។

ឈួន ឆាម.២០១៤. "កំណែទម្រង់រដ្ឋបាល." បទបង្ហាញនៅសាលាភូមិន្ទរដ្ឋបាល, ខែមករា ។

សាយ បូរី. ២០០៤. *នីតិរដ្ឋបាលទូទៅ*, បោះពុម្ពលើកទី៣. ភ្នំពេញ៖ ប្លុស្សំឡូទីស ។

សាយ បូរី. ២០០៧. *វិទ្យាសាស្ត្ររដ្ឋបាល*. ភ្នំពេញ៖ បណ្ណាគារអង្គរ ។

ហៀង សាង និងប៉េង ឆុង. *សមត្ថកិច្ច និងរបៀបរបបការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ* ។

អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ. ២០១៥. *សៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ*. ភ្នំពេញ ។

## ឃ. គេហទំព័រ

គេហទំព័រ ក្រសួងមហាផ្ទៃ ៖ http://www.interior.gov.kh/

គេហទំព័រ ក្រសួង មុខងារសាធារណៈ ៖ http://www.mcs.gov.kh/

គេហទំព័រ គណៈកម្មាធិការសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ៖ http://www.ncdd.gov.kh/km/

# ឧបសម្ព័ន្ធ

# តារាងឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី ១៖ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ឧបសម្ព័ន្ធទី ២៖ អនុក្រឹត្យស្តីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

ឧបសម្ព័ន្ធទី៣៖ អនុក្រឹត្យស្តីពី ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

# ឧបសម្ព័ន្ធទី ១

# ព្រះរាជក្រម

នស/រកម/០៥០៨/០១៧

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បាន អនុម័តកាលពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមរយៈសេចក្តីសម្រេចលេខ០៩៦/០០១/២០០៨ កបធ.ច ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៨ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

# ច្បាប់

## ស្តីពី

## ការគ្រប់គ្រងរដ្ឋបាល
## រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## ជំពូកទី ១
## អំពីបទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងកំណត់ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ២.-**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ។

**មាត្រា ៣.-**

ឃុំ សង្កាត់ត្រូវគ្រប់គ្រងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ លើកលែងតែបញ្ញាទាំងឡាយណាដែលបានចែងក្នុងច្បាប់នេះ ។

**មាត្រា ៤.-**

ភ្នំពេញ ជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ។

រាជធានីភ្នំពេញ ចែកជាខណ្ឌ ។

ខណ្ឌ ចែកជាសង្កាត់ ។

**មាត្រា ៥.-**

ខេត្ត ចែកជាក្រុង និងជាស្រុក ។

ក្រុង ចែកជាសង្កាត់ ។

ស្រុក ចែកជាឃុំ និងជាសង្កាត់ ។

**មាត្រា ៦.-**

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ និងការកំណត់ឈ្មោះខេត្ត ត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួង

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ការកំណត់ព្រំប្រទល់រាជធានីភ្នំពេញ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ៧.-

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ និងការកំណត់ឈ្មោះក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ៨.-

ការបង្កើតរដ្ឋបាលឯកភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺសំដៅដល់ការពង្រឹងអង្គឯកភាពរបស់រដ្ឋ ដើម្បីសម្របសម្រួលនូវរាល់សកម្មភាពរដ្ឋបាលសាធារណៈនៅក្នុងដែនដីរបស់ខ្លួន ។

មាត្រា ៩.-

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជានីតិបុគ្គលនៃនីតិសាធារណៈ ។

មាត្រា ១០.-

នីតិបុគ្គលនីមួយៗ ត្រូវមានក្រុមប្រឹក្សាមួយជាតំណាងដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើង ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

មាត្រា ១១.-

នីតិបុគ្គលនីមួយៗត្រូវបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

មាត្រា ១២.-

ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យរួមមាន :

-ភាពជាតំណាងសាធារណៈ

-ស្វ័យភាពរបស់មូលដ្ឋាន

-ការពិគ្រោះយោបល់ និងការចូលរួម

-ការឆ្លើយតប និងគណនេយ្យភាព

-ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជននៅក្នុងមូលដ្ឋាន

-ការលើកស្ទួយសមធម៌

-តម្លាភាព និងសុចរិតភាព

-វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច ។

**មាត្រា ១៣.–**

នីតិបុគ្គលទទួលសិទ្ធិអំណាចរបស់ខ្លួន ដោយរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានដទៃទៀត ដែលស្របនឹងច្បាប់នេះ ។

## ជំពូកទី ២
## អំពីក្រុមប្រឹក្សា

### ផ្នែកទី ១
### ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**មាត្រា ១៤.–**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានក្រុមប្រឹក្សារបស់ខ្លួន ដែលត្រូវបានជ្រើសរើសឡើង តាមការបោះឆ្នោតអសកល ស្របតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលហៅកាត់ថា "ក្រុមប្រឹក្សា" ។

**មាត្រា ១៥.–**

ក្រុមប្រឹក្សាមានអាណត្តិប្រាំ (០៥) ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង ។

អាណត្តិរបស់ក្រុមប្រឹក្សា ត្រូវគិតចាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងផុតកំណត់នៅថ្ងៃបោះឆ្នោតបន្ទាប់ ។

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

**មាត្រា ១៦.-**

ក្នុងពេលរង់ចាំក្រុមប្រឹក្សាថ្មីចូលកាន់មុខតំណែង ក្រុមប្រឹក្សាដែលចប់អាណត្តិមានសិទ្ធិអនុវត្តតែកិច្ចការរដ្ឋបាលប្រចាំថ្ងៃតែប៉ុណ្ណោះ ។

**មាត្រា ១៧.-**

ក្រុមប្រឹក្សានីមួយៗ ត្រូវមានប្រធានម្នាក់ ។

ប្រធានក្រុមប្រឹក្សា គឺជាបេក្ខជនដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានអាសនៈច្រើនជាងគេ នៅក្នុងក្រុមប្រឹក្សា ។

ក្នុងករណីដែលបញ្ជីបេក្ខជនមានអាសនៈស្មើគ្នានៅក្នុងក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សា ត្រូវជ្រើសរើសយកបេក្ខជន ដែលមានលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានសំឡេងឆ្នោតបានការច្រើនជាងគេ ។

**មាត្រា ១៨.-**

ចំនួនសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយផ្អែកតាមកត្តាប្រជាសាស្ត្រនិងកត្តាភូមិសាស្ត្រ ដូចខាងក្រោម ៖

-ក្រុមប្រឹក្សារាជធានីភ្នំពេញ មានចំនួនសមាជិកមិនលើសពីម្ភៃមួយ(២១)រូប

-ក្រុមប្រឹក្សាខេត្ត មានចំនួនសមាជិកពីប្រាំបួន(០៩)រូប ដល់ម្ភៃមួយ(២១)រូប

-ក្រុមប្រឹក្សាក្រុង មានចំនួនសមាជិកពីប្រាំពីរ(០៧)រូប ដល់ដប់ប្រាំ(១៥)រូប

-ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ មានចំនួនសមាជិកពីប្រាំពីរ(០៧)រូប ដល់ដប់ប្រាំបួន(១៩)រូប ។

ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងរយៈពេលយ៉ាងតិចមួយរយម្ភៃ (១២០)ថ្ងៃ មុនពេលផុតកំណត់អាណត្តិរបស់ក្រុមប្រឹក្សា ។

ក្នុងករណីគ្មានអនុក្រឹត្យ ចែងអំពីចំនួនសមាជិកក្រុមប្រឹក្សាអាណត្តិបន្ទាប់ទេនោះ ចំនួនសមាជិកសរុបរបស់ក្រុមប្រឹក្សា សម្រាប់ក្រុមប្រឹក្សានីមួយៗ ត្រូវយកតាមចំនួនសរុបសមាជិកនៃក្រុមប្រឹក្សាអាណត្តិចាស់ ។

មាត្រា ១៩.-

ក្រុមប្រឹក្សានីមួយៗត្រូវធ្វើជាតំណាង និងធ្វើសកម្មភាពក្នុងនាមប្រជាពលរដ្ឋទាំងអស់ ដែលរស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

មាត្រា ២០.-

ក្រុមប្រឹក្សានីមួយៗ ត្រូវបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

មាត្រា ២១.-

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបំពេញតាមលក្ខខណ្ឌ និងមានលក្ខណសម្បត្តិ ដូចខាងក្រោម :

-មានសញ្ជាតិខ្មែរពីកំណើត

-មានអាយុយ៉ាងតិចម្ភៃប្រាំ(២៥)ឆ្នាំ គិតមកដល់ថ្ងៃបោះឆ្នោត

-មានសិទ្ធិបោះឆ្នោត និងមានលក្ខណសម្បត្តិគ្រប់គ្រាន់ តាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

មាត្រា ២២.-

សមាជិកក្រុមប្រឹក្សាម្នាក់ ត្រូវបាត់បង់សមាជិកភាពពីសមាជិកក្រុមប្រឹក្សាក្នុងករណីណាមួយ ដូចខាងក្រោម :

-សាមីខ្លួនបាត់បង់លក្ខណសម្បត្តិ និងលក្ខខណ្ឌ សម្រាប់ឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា

-សាមីខ្លួនសុំលាឈប់ពីក្រុមប្រឹក្សា តាមការដាក់ពាក្យសុំលាឈប់ជាលាយលក្ខណ៍អក្សរទៅប្រធានក្រុមប្រឹក្សា

-សាមីខ្លួនទទួលមរណភាព

-សាមីខ្លួនមិនបានចូលរួមក្នុងកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាជាប់ៗគ្នា ចាប់ពីពីរ(០២)ដងឡើងទៅ ដោយគ្មានច្បាប់អនុញ្ញាត

ROYAUME DU CAMBODGE - LE MINISTRE ... PALAIS ROYAL

-សាមីខ្លួនត្រូវបណ្តេញចេញពីសមាជិកក្រុមប្រឹក្សា អនុលោមតាមច្បាប់ នីតិវិធី ឬ បទបញ្ជាផ្ទៃក្នុង ឬ ក្រមសីលធម៌របស់ក្រុមប្រឹក្សា

-សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ

-សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសម្រេច និងប្រកាសពីការបាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ក្នុងករណីដូចខាងលើនេះ ។

**មាត្រា ២៣.-**

នៅពេលដែលមានសមាជិកក្រុមប្រឹក្សាណាម្នាក់បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវជ្រើសរើសបេក្ខជនលំដាប់លេខរៀងបន្ទាប់ ពីក្នុងបញ្ជីបេក្ខជនជាមួយមកជំនួស ក្នុងរយៈពេលយ៉ាងយូរដប់បួន(១៤)ថ្ងៃ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ២៤.-**

ប្រសិនបើក្រុមប្រឹក្សាណាមួយអនុវត្តផ្ទុយពីបទប្បញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើការណែនាំជាលាយលក្ខណ៍អក្សរដល់ក្រុមប្រឹក្សានោះឱ្យគោរព និងអនុវត្តបទប្បញ្ញត្តិទាំងនោះ នៅក្នុងអំឡុងពេលជាក់លាក់ និងសមហេតុផល ។

ក្នុងករណីក្រុមប្រឹក្សានោះនៅតែមិនព្រមអនុវត្តតាមការណែនាំ រាជរដ្ឋាភិបាលត្រូវរំលាយក្រុមប្រឹក្សានោះដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ២៥.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត "គ.ជ.ប" ត្រូវរៀបចំការបោះឆ្នោតឡើងវិញ ដើម្បីជ្រើសរើសក្រុមប្រឹក្សា ក្នុងករណីណាមួយដូចខាងក្រោម ៖

-ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបង្កើតថ្មីដូចមានចែងក្នុងមាត្រា ៦ និងមាត្រា ៧ នៃច្បាប់នេះ ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរពីររយសែសិប (២៤០) ថ្ងៃ

-ក្រុមប្រឹក្សាដែលត្រូវរំលាយតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ២៤ នៃច្បាប់នេះ ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរមួយរយម្ភៃ(១២០)ថ្ងៃ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ក្រុមប្រឹក្សាដែលកើតឡើងដោយការបោះឆ្នោតឡើងវិញខាងលើនេះ មានអាណត្តិស្មើនឹងអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សានោះ ។

**មាត្រា ២៦.-**

ការបោះឆ្នោតឡើងវិញមិនត្រូវអនុញ្ញាតឱ្យធ្វើឡើយ ប្រសិនបើអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាមានរយៈពេលមិនលើសពីមួយរយប៉ែតសិប(១៨០)ថ្ងៃ ។

**មាត្រា ២៧.-**

ក្នុងករណីដែលមានក្រុមប្រឹក្សាណាមួយត្រូវរំសាយ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចាត់វិធានការដើម្បីគ្រប់គ្រងជំនួសរហូតដល់មានក្រុមប្រឹក្សាថ្មីចូលកាន់តំណែង ។

**មាត្រា ២៨.-**

សមាជិកក្រុមប្រឹក្សានៅក្នុងមុខតំណែង ត្រូវទទួលប្រាក់ឧបត្ថម្ភ ដែលត្រូវបើកចេញពីគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សានោះ ។

ប្រាក់ឧបត្ថម្ភខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ផ្នែកទី ២

## តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា

**មាត្រា ២៩.-**

ក្រុមប្រឹក្សាមានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចនូវគោលបំណងក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិប-តេយ្យ ព្រមទាំងដើម្បីបំពេញមុខងារភារកិច្ចដែលបានប្រគល់ និងដែលបានធ្វើប្រតិភូកម្មតាមច្បាប់នេះ ឬ ដែលស្របតាមច្បាប់នេះ ។

**មាត្រា ៣០.-**

ក្រុមប្រឹក្សា មានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាង

ROYAUME DU CAMBODGE - LE MINISTRE DU PALAIS ROYAL - ព្រះបរមរាជវាំង

មាត្រា ៣១.-

ក្រុមប្រឹក្សា ត្រូវបំពេញមុខងារ និងភារកិច្ច ដោយធ្វើសេចក្តីសម្រេចនៅក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាថាសេចក្តីសម្រេចនោះត្រូវបានអនុវត្ត ។

មាត្រា ៣២.-

ក្រុមប្រឹក្សា ប្រើប្រាស់សិទ្ធិអំណាចបញ្ញត្តិរបស់ខ្លួនដោយការធ្វើដីកា ស្របទៅតាមបទប្បញ្ញត្តិដូចមានចែងក្នុងផ្នែកទី ៣ ជំពូកទី ២ នៃច្បាប់នេះ ។

មាត្រា ៣៣.-

ក្រុមប្រឹក្សាប្រើប្រាស់សិទ្ធិអំណាចប្រតិបត្តិរបស់ខ្លួនដោយធ្វើសេចក្តីសម្រេច នៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សា ។

មាត្រា ៣៤.-

ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋទាំងអស់អំពីជម្រើសជាអាទិភាព ដើម្បីធ្វើសេចក្តីសម្រេច ធានាបានការអភិវឌ្ឍតាមបែបប្រជាធិប-តេយ្យ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្រុមប្រឹក្សាអាចធ្វើការអង្កេតលើករណីទាំងឡាយណា ដែលខ្លួនយល់ឃើញថាមានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង ព្រមទាំងអាចផ្សព្វផ្សាយលទ្ធផលនៃការធ្វើអង្កេតនោះ រួចហើយត្រូវផ្តល់គោលការណ៍ណែនាំអនុវត្តដល់គណៈអភិបាលនិងអភិបាល ។

មាត្រា ៣៥.-

ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការប្រតិបត្តិតាមរដ្ឋ-ធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាននានា ។

មាត្រា ៣៦.-

រៀងរាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាត្រូវធ្វើសេចក្តីសម្រេច ឬ ដីកាតាមការចាំបាច់ទាក់ទិនទៅនឹង :

-ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មី ស្របតាមច្បាប់នេះ

-មុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សា

-មុខងារជាជម្រើសរបស់ក្រុមប្រឹក្សា

-កម្មវិធីវិនិយោគបី(៣)ឆ្នាំរំកិលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍរយៈពេលប្រាំ (៥) ឆ្នាំ រួមទាំងសមាសភាគនៃផែនការនោះ ដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សារួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា

-គម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

-បញ្ហាហិរញ្ញវត្ថុផ្សេងទៀត

-ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងគណៈកម្មាធិការ អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា

-ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ

-ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជនក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋ

-កិច្ចការផ្សេងៗទៀត ដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានដែលបានធ្វើឡើងស្របតាមច្បាប់នេះ ។

**មាត្រា ៣៧.-**

ក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តផែនការអភិវឌ្ឍរយៈពេលប្រាំ(៥)ឆ្នាំ ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ តាមការរៀបចំកម្មវិធីវិនិយោគបី(៣)ឆ្នាំរំកិលប្រចាំឆ្នាំ ។

**មាត្រា ៣៨.-**

ក្នុងការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍ ក្រុមប្រឹក្សាត្រូវពិគ្រោះយោបល់ជាមួយ :

-ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-ប្រភេទក្រុមប្រឹក្សាផ្សេងទៀតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល

-អ្នកពាក់ព័ន្ធនានា ។

ROYAUME DU CAMBODGE LE MINISTERE ... ROYAL

នីតិវិធីនៃការពិគ្រោះយោបល់នៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិភាក្សាជាមួយក្រសួងផែនការ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ៣៩.-**

ក្រុមប្រឹក្សាត្រូវរៀបចំផែនការអភិវឌ្ឍ ដែលរួមមាន ៖

-ចក្ខុវិស័យរបស់ក្រុមប្រឹក្សា ដោយបង្ហាញពីគោលដៅ និងគោលបំណងសម្រាប់អភិវឌ្ឍនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

-ការប៉ាន់ប្រមាណពីកម្រិតនៃការអភិវឌ្ឍដែលមានស្រាប់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងការ ប៉ាន់ប្រមាណពីតម្រូវការអភិវឌ្ឍសំខាន់ៗរួមមាន ៖

+ តម្រូវការរបស់ក្រុមប្រឹក្សានៅក្នុងការរៀបចំទទួលយកនូវការផ្ទេរមុខងារ ភារកិច្ច និងធនធានថ្មីៗ

+ សេវា មធ្យោបាយ សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាមូលដ្ឋាន និងចាំបាច់នានា

+ ការកាត់បន្ថយភាពក្រីក្រ

+ តម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ កុមារ ក្រុមជនងាយរងគ្រោះ រួមទាំងជនក្រីក្រ ជនជាតិដើមភាគតិច ។

-ក្របខ័ណ្ឌអភិវឌ្ឍដែលត្រូវចែងអំពីគោលការណ៍ណែនាំជាមូលដ្ឋានក្នុងការប្រើប្រាស់ និងគ្រប់គ្រងការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិនៅតំបន់នោះ

-ផែនការគ្រប់គ្រងគ្រោះមហន្តរាយ

-ផែនការហិរញ្ញវត្ថុ ដោយត្រូវរាប់បញ្ចូលទាំងផែនការអភិវឌ្ឍមូលធន ការគ្រោងថវិកាសម្រាប់រយៈពេលដប់ពីរ (១២)ខែ ចាប់ពីពេលរៀបចំផែនការ និងសម្រាប់រយៈពេលបី (៣)ឆ្នាំចាប់ពីពេលរៀបចំផែនការ ហើយត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ

…យុទ្ធសាស្ត្រអនុវត្តផែនការអភិវឌ្ឍ ដើម្បីធានាឱ្យ មានតម្លាភាពនិងគណនេយ្យ ចំពោះប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-ស្ទូចនាករបំពេញការងារសំខាន់ៗ និងគោលដៅនានាទាក់ទិននឹងអាទិភាព និងទិសដៅអភិវឌ្ឍនីមួយៗដូចមានចែងក្នុងផែនការអភិវឌ្ឍ

ក្រុមប្រឹក្សាត្រូវកំណត់ឱ្យដាច់ពីគ្នានៅក្នុងផែនការអភិវឌ្ឍ និងថវិកានូវមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច ។

បែបបទ នីតិវិធីជាក់ស្ដែងនៃការរៀបចំ ការគ្រប់គ្រង និងការអនុវត្តផែនការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពី បានពិគ្រោះពិភាក្សាជាមួយក្រសួងផែនការ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ។

## មាត្រា ៤០.-

ក្រុមប្រឹក្សា ត្រូវតាមដាន និងវាយតម្លៃជារៀងរាល់ឆ្នាំ ទៅលើការអនុវត្តផែនការអភិវឌ្ឍរបស់ខ្លួន ដោយរាប់ទាំងផ្នែកនៃផែនការអភិវឌ្ឍដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ :

-ក្រុមប្រឹក្សាប្រភេទរួមគ្នា

-ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត

-ក្រសួង ស្ថាប័ន អង្គភាពនានារបស់រាជរដ្ឋាភិបាល

-អ្នកពាក់ព័ន្ធនានា។

## មាត្រា ៤១.-

ក្រុមប្រឹក្សា ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់នូវផែនការអភិវឌ្ឍបន្ទាប់ពី បានអនុម័តរួចហើយភ្លាម ។

សាធារណជន អាចពិនិត្យឯកសារផែនការនេះ នៅការិយាល័យរបស់ក្រុមប្រឹក្សា ដោយឥតគិតថ្លៃ ឬ អាចស្នើសុំជាវឯកសារផែនការនេះពីក្រុមប្រឹក្សា ដោយគិតត្រឹមតម្លៃដើម ។

## មាត្រា ៤២.-

ក្រុមប្រឹក្សាត្រូវចាត់ចែងកិច្ចការហិរញ្ញវត្ថុសាធារណៈ ដើម្បីជំរុញដល់ការអភិវឌ្ឍក្នុងរបបប្រជាធិបតេយ្យ និងដែលផ្ដោតទៅលើតម្រូវការអភិវឌ្ឍសំខាន់ៗបំផុតរួមមាន :

-តម្រូវការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំសម្រាប់ទទួលមុខងារ ភារកិច្ច និងធនធានថ្មីៗ

-សេវា មធ្យោបាយ សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាមូលដ្ឋាន និងចាំបាច់

-ការកាត់បន្ថយភាពក្រីក្រ

-តម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ និងកុមារ ក្រុមជនងាយរងគ្រោះដោយរួមបញ្ចូលទាំងជនក្រីក្រ ជនជាតិដើមភាគតិច ។

មាត្រា ៤៣.-

ក្រុមប្រឹក្សាត្រូវចាត់ចែងកិច្ចការហិរញ្ញវត្ថុ ឱ្យមានតម្លាភាព និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន ។

មាត្រា ៤៤.-

រាជធានី ខេត្ត ក្រុង ស្រុក ត្រូវមានថវិកាផ្ទាល់របស់ខ្លួន ដែលហៅកាត់ថាថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ។

ខណ្ឌ និងសង្កាត់ចំណុះរាជធានី ត្រូវមានថវិការបស់ខ្លួននៅក្នុងថវិការបស់រាជធានី ។

សង្កាត់ចំណុះក្រុង ត្រូវមានថវិការបស់ខ្លួននៅក្នុងថវិការបស់ក្រុង ។

ក្រុមប្រឹក្សាត្រូវអនុម័តលើថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមនីតិវិធីនិងប្រតិទិននៃការកសាងថវិការដ្ឋជារៀងរាល់ឆ្នាំ ។

ក្រុមប្រឹក្សាត្រូវអនុម័តក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ហើយត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ។

ការគ្រប់គ្រងនិងការអនុវត្តគម្រោងថវិកាប្រចាំឆ្នាំ ត្រូវផ្អែកតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរៀបចំឡើងស្របតាមច្បាប់នេះ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។

ថវិកាត្រូវរៀបចំឡើងដោយគោរពតាមគោលការណ៍សំខាន់ៗទាំងអស់នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតែមានតុល្យភាពរវាងចំណូល និងចំណាយ ។

**មាត្រា ៤៥.-**

ក្នុងការគ្រប់គ្រងកិច្ចការហិរញ្ញវត្ថុ ក្រុមប្រឹក្សាត្រូវធានាអនុវត្តតាមបទដ្ឋាន វិធាន ប្រព័ន្ធ និងនីតិវិធី ដែលបានកំណត់ទាក់ទិនទៅនឹង :

-ការរៀបចំ ការអនុម័ត និងការអនុវត្តថវិកា

-គណនេយ្យ និងរបាយការណ៍

-ទ្រព្យសកម្ម និងទ្រព្យអកម្ម

-តម្លាភាព និងគណនេយ្យភាព

-ការគ្រប់គ្រង :

+ ចំណូលផ្ទាល់

+ ចំណូលដែលចែករំលែក មូលនិធិផ្ទេរពីថវិកាជាតិ និងថ្លៃសេវាសម្រាប់អនុវត្តមុខងារជាភ្នាក់ងារក្នុងនាមក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល

+ ចំណូលពីប្រភពផ្សេងៗទៀត ។

-លទ្ធកម្មសាធារណៈ

-ការធ្វើសវនកម្មផ្ទៃក្នុង

-ការធ្វើសវនកម្មផ្ទៃក្រៅ

-តម្រូវការផ្នែកហិរញ្ញវត្ថុសាធារណៈផ្សេងៗទៀត ។

បទដ្ឋាន វិធាន ប្រព័ន្ធ និងនីតិវិធីសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយច្បាប់ស្ដីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរៀបចំឡើងស្របតាមច្បាប់នេះ និងច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដោយផ្អែកតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៤៦.-**

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យ

ROYAUME du CAMBODGE LE MINISTRE du PALAIS ROYAL ក្រសួងព្រះបរមរាជវាំង

សម្បត្តិរដ្ឋដែលបានផ្ទេរមកឱ្យខ្លួន ឬ ដែលបានទទួលដោយមធ្យោបាយផ្ទាល់ខ្លួនផ្សេងទៀតឱ្យមានប្រសិទ្ធភាព ។

នីតិវិធីនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

### មាត្រា ៤៧.-

ក្នុងករណីដែលមានការរំលោភអំណាចកើតមានឡើង នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្រុមប្រឹក្សាត្រូវមានភារកិច្ចរាយការណ៍ជាលាយលក្ខណ៍អក្សរជាបន្ទាន់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

### មាត្រា ៤៨.-

ការរំលោភអំណាចកើតឡើងនៅពេលដែលអ្នកជាប់ឆ្នោតណាម្នាក់ ឬ អ្នកដែលបានទទួលការតែងតាំងនៅក្នុងក្រសួង ស្ថាប័ន ឬ ភ្នាក់ងាររបស់រដ្ឋ ឬ ក្នុងក្រុមប្រឹក្សាណាមួយ ឬ ជនណាម្នាក់ ដែលបានប្រព្រឹត្តអំពើដោយចេតនា ហើយដែលមិនអាចធ្វើយុត្តិកម្មបានដូចជា :

-ការប្រើប្រាស់តួនាទី ឬ អំណាចរបស់ខ្លួន ដើម្បីកេងប្រវ័ញ្ច ឬ ធ្វើទុក្ខបុកម្នេញដល់បុគ្គលណាម្នាក់ ឬ ក្រុមមនុស្ស ឬ ទ្រព្យសម្បត្តិសាធារណៈ ឬ ធនធានសាធារណៈណាមួយ

-ការមិនបានប្រើប្រាស់តួនាទី ឬ អំណាចរបស់ខ្លួន ដើម្បីទប់ស្កាត់ជនម្នាក់ទៀតដែលស្ថិតនៅក្រោមអំណាច ឬ ការត្រួតពិនិត្យរបស់ខ្លួន នៅពេលដែលខ្លួនបានដឹងអំពីកំហុសឆ្គងរបស់ជននោះ ដែលបានកេងប្រវ័ញ្ច ឬ ធ្វើទុក្ខបុកម្នេញដល់បុគ្គលណាម្នាក់ ឬ ក្រុមមនុស្ស ឬ ទ្រព្យសម្បត្តិសាធារណៈ ឬ ធនធានសាធារណៈ ។

### មាត្រា ៤៩.-

ការរំលោភអំណាច រួមមានសកម្មភាពណាមួយ ដូចខាងក្រោម :

-ការរំលោភសិទ្ធិស្របច្បាប់ ឬ សិទ្ធិមនុស្សរបស់ជនណាម្នាក់

-ការកាន់កាប់ ឬ ការរឹបអូសទ្រព្យសម្បត្តិសាធារណៈ ឬ ទ្រព្យសម្បត្តិឯកជន និងធនធានធម្មជាតិមកធ្វើជារបស់ខ្លួនដោយខុសច្បាប់

-ការធ្វើឱ្យអន្តរាយដល់បរិស្ថាន ធនធានធម្មជាតិ

-ការដកយកថវិកា ឬ ទ្រព្យសម្បត្តិរដ្ឋដោយខុសច្បាប់ ឬ ការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋមិនត្រឹមត្រូវ

-ការស្នើសុំ ឬ ការទទួលប្រាក់ ឬ រង្វាន់អ្វីមួយជាថ្នូរនឹងការធ្វើ ឬ មិនធ្វើកិច្ចការណាមួយ ដែលស្ថិតនៅក្នុងវិសាលភាពនៃភារកិច្ចផ្លូវការរបស់ជននោះ ហើយដែលការចំណាយ ឬ រង្វាន់ នោះមិនបានកំណត់នៅក្នុងច្បាប់

-ភាពមិនប្រក្រតីនៅក្នុងការអនុវត្តច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ឬប្រកាស

-ភាពមិនប្រក្រតីនៅក្នុងការអនុវត្តដីការបស់ក្រុមប្រឹក្សា

-ការធ្វើសេចក្តីសម្រេចនៅក្នុងវិសាលភាពនៃភារកិច្ចផ្លូវការ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ឬ ផលប្រយោជន៍គ្រួសាររបស់ខ្លួន ។

**មាត្រា ៥០.-**

ក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តរបាយការណ៍ប្រចាំឆ្នាំដែលពាក់ព័ន្ធ :

-ដីកា និងសេចក្តីសម្រេចនានាដែលបានដាក់ចេញ

-សកម្មភាពនានាដែលបានអនុវត្ត

-របាយការណ៍ហិរញ្ញវត្ថុ

-ការវាយតម្លៃការបំពេញការងាររបស់គណៈអភិបាល និងបុគ្គលិកក្រុមប្រឹក្សា

-លទ្ធផលនៃការតាមដាន និងវាយតម្លៃ ដូចមានចែងក្នុងមាត្រា ៤០ នៃច្បាប់នេះ

-វិធានការចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សា

ក្រុមប្រឹក្សាត្រូវពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំឆ្នាំខាងលើនេះ មិនឱ្យលើសពីសែសិបប្រាំ(៤៥)ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំ ។

**មាត្រា ៥១.-**

ក្រុមប្រឹក្សា ត្រូវបង្កលក្ខណៈងាយស្រួលដល់សាធារណជនក្នុងការជូនព័ត៌មានជា

សាធារណៈអំពីរបាយការណ៍ របៀបវារៈប្រជុំ កំណត់ហេតុប្រជុំ ដីកា ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាសទាំងអស់ដែលពាក់ព័ន្ធនឹងក្រុមប្រឹក្សា និងឯកសារដទៃទៀតរបស់ក្រុមប្រឹក្សា ។

**មាត្រា ៥២.-**

ក្រុមប្រឹក្សានីមួយៗត្រូវមានក្តារព័ត៌មានជាសាធារណៈ ឬ មធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងទៀតនៅការិយាល័យកណ្តាលរបស់ខ្លួន និងនៅតាមទីកន្លែងនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតាមការចាំបាច់ ហើយទីកន្លែងទាំងនោះមានភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋទទួលបានព័ត៌មានជាសាធារណៈទាំងនោះ ។

## ផ្នែកទី ៣
## ដីការបស់ក្រុមប្រឹក្សា

**មាត្រា ៥៣.-**

ដីកា គឺជាវិធានខាងផ្លូវច្បាប់ដែលបានអនុម័តដោយក្រុមប្រឹក្សា ។

យោងតាមបទប្បញ្ញត្តិនៃច្បាប់នេះ ក្រុមប្រឹក្សាប្រើប្រាស់សិទ្ធិអំណាចបញ្ញត្តិរបស់ខ្លួន តាមការធ្វើសេចក្តីសម្រេចដើម្បីដាក់ចេញនូវដីកាតាមការចាំបាច់ ។

**មាត្រា ៥៤.-**

ដីការបស់ក្រុមប្រឹក្សា មានវិសាលភាពដើម្បីកំណត់ ដើម្បីហាមឃាត់ ឬ ដើម្បីត្រួតពិនិត្យលើសកម្មភាព លើនីតិវិធី ឬ លើកិច្ចការណាមួយ ដែលស្ថិតនៅក្នុងវិសាលភាពនៃមុខងារ ភារកិច្ច និងធនធានរបស់ក្រុមប្រឹក្សារួមមាន :

-តួនាទី ភារកិច្ច សិទ្ធិអំណាចរបស់ក្រុមប្រឹក្សា

-មុខងារ ឬ ភារកិច្ច ដែលប្រគល់ឱ្យក្រុមប្រឹក្សា

-មុខងារ ឬ ភារកិច្ច ដែលបានធ្វើប្រតិភូកម្មទៅឱ្យក្រុមប្រឹក្សា ក្នុងករណីដែលការធ្វើប្រតិភូកម្មនោះ មិនបានដកចេញនូវសិទ្ធិអំណាចខ្លះ ឬ ទាំងអស់ដើម្បីដាក់ចេញដីកាក្នុងកិច្ចការណាមួយដែលច្បាប់នេះ ឬ ច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ឬ ប្រកាសផ្សេងទៀត តម្រូវឱ្យក្រុមប្រឹក្សាដាក់ចេញដីកា ។

**មាត្រា ៥៥.-**

ដីកាដែលដាក់ចេញដោយក្រុមប្រឹក្សា ត្រូវប្រតិបត្តិ និងអនុវត្តនៅក្នុងដែនសមត្ថកិច្ចទាំងមូលរបស់ខ្លួន លើកលែងតែដីកាចែងផ្សេងពីនេះ ឬ លើកលែងតែច្បាប់ណាមួយបានតម្រូវឱ្យដកចេញពីដីកានូវតំបន់ដែលបានកំណត់ព្រំប្រទល់ច្បាស់លាស់ ។

**មាត្រា ៥៦.-**

ដីកាដែលក្រុមប្រឹក្សាបានអនុម័តរួច ត្រូវចូលជាធរមាននៅថ្ងៃដែលក្រុមប្រឹក្សាប្រកាសផ្សាយដីកានោះ ។

ដីកា អាចកំណត់យកកាលបរិច្ឆេទណាមួយនាពេលអនាគត សម្រាប់ការចូលជាធរមាននូវដីកាទាំងមូល ឬ ផ្នែកខ្លះនៃដីកា ។

ដីកា មិនអាចមានប្រតិសកម្ម និងមិនអាចចូលជាធរមានមុនពេលដែលដីកាត្រូវបានអនុម័ត និងប្រកាសផ្សាយនោះឡើយ ។

**មាត្រា ៥៧.-**

ដីកាដែលចែងផ្ទុយពីបទប្បញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ដីកានោះនឹងមិនមានសុពលភាពបានឡើយ ។

**មាត្រា ៥៨.-**

ដីកាណាមួយដែលធ្វើឡើងដោយមានការរើសអើងក្នុងន័យជាអវិជ្ជមាន ឬ អនុវត្តចំពោះតែបុគ្គលណាម្នាក់ ឬ ក្រុមមនុស្សណាមួយ ដោយផ្អែកលើកត្តាជាតិសាសន៍ សាសនា ភេទ អាយុ ពណ៌សម្បុរ ជាតិ ឬ ជាតិកំណើត ឬ អសមត្ថភាពខាងស្មារតី ឬ ខាងកាយសម្បទា ដីកានោះមិនមានសុពលភាពបានឡើយ ។

**មាត្រា ៥៩.-**

ដីកាអាចបង្កើតបទប្បញ្ញត្តិសម្រាប់ការពិន័យជាប្រាក់ចំពោះការប្រព្រឹត្តល្មើស ឬ ការមិនគោរពតាមបទប្បញ្ញត្តិមួយ ឬ ច្រើននៃដីកានោះបាន ។

ប្រភេទ នីតិវិធីនៃការរៀបចំបទប្បញ្ញត្តិ សម្រាប់ការពិន័យជាប្រាក់ដោយដីការបស់

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ក្រុមប្រឹក្សា និងកម្រិតនៃប្រាក់ពិន័យនេះ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ៦០.-

ក្រុមប្រឹក្សានីមួយៗត្រូវអនុវត្តទៅតាមនីតិវិធីក្នុងការរៀបចំតាក់តែង ការកែប្រែ ឬ ការលុបចោលដីការបស់ខ្លួន ។

ការកែប្រែដីកា ឬ ការលុបចោលដីការបស់ក្រុមប្រឹក្សា ត្រូវសម្រេចដោយដីការបស់ក្រុមប្រឹក្សា ។

នីតិវិធីនៃការរៀបចំ ការកែប្រែ និងការលុបចោលដីការបស់ក្រុមប្រឹក្សា ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ៦១.-

ក្រុមប្រឹក្សា ត្រូវអនុវត្ត និងពង្រឹងការអនុវត្តដីកាទាំងអស់របស់ខ្លួន ។

ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាអាចពង្រឹងការអនុវត្តដីការបស់ខ្លួនតាមរយៈ ឬ ដោយមានកិច្ចសហការជាមួយមន្ត្រីនគរបាលយុត្តិធម៌ ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវជួយក្រុមប្រឹក្សា ដើម្បីពង្រឹងការអនុវត្តដីការបស់ក្រុមប្រឹក្សា នៅពេលដែលមានការស្នើសុំជាលាយលក្ខណ៍អក្សរពីក្រុមប្រឹក្សា ។

## ផ្នែកទី ៤
## អង្គប្រជុំ និង បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សា

មាត្រា ៦២.-

អង្គប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សា ត្រូវប្រារព្ធធ្វើឡើងនៅក្នុងរយៈពេលមិនឱ្យលើសពីដប់បួន(១៤)ថ្ងៃ បន្ទាប់ពីថ្ងៃដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

ក្រសួងមហាផ្ទៃ ត្រូវចាត់តាំងមន្ត្រីមួយរូបឱ្យធ្វើជាអធិបតីក្នុងអង្គប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សា ។

មាត្រា ៦៣.-

ប្រធានក្រុមប្រឹក្សា គឺជាប្រធានអង្គប្រជុំទាំងអស់របស់ក្រុមប្រឹក្សា ។

មាត្រា ៦៤.-

ប្រធានអង្គប្រជុំរបស់ក្រុមប្រឹក្សា មានភារកិច្ច :

-ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សា ដោយឱនលំអៀង

-គោរព អនុវត្តច្បាប់ និងបទបញ្ជាផ្ទៃក្នុងសម្រាប់អង្គប្រជុំរបស់ក្រុមប្រឹក្សា ។

មាត្រា ៦៥.-

ក្នុងករណីប្រធានក្រុមប្រឹក្សាអវត្តមាន ត្រូវជ្រើសយកសមាជិកក្រុមប្រឹក្សាដែលស្ថិតនៅលេខរៀងលំដាប់បន្តបន្ទាប់នៃបញ្ជីបេក្ខជនជាមួយប្រធានក្រុមប្រឹក្សាធ្វើជាអធិបតីនៃអង្គប្រជុំ ។

ក្នុងករណីសមាជិកក្រុមប្រឹក្សា ដែលស្ថិតក្នុងលំដាប់លេខរៀងបន្តបន្ទាប់នៃបញ្ជីបេក្ខជនជាមួយប្រធានក្រុមប្រឹក្សាអវត្តមាន ត្រូវជ្រើសយកសមាជិកក្រុមប្រឹក្សាដែលស្ថិតនៅលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលជាប់ឆ្នោតលំដាប់ទី ២ ក្នុងក្រុមប្រឹក្សា ដើម្បីធ្វើជាអធិបតីនៃអង្គប្រជុំ ។

ករណីសមាជិកក្រុមប្រឹក្សា ដែលស្ថិតនៅលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលជាប់ឆ្នោតលំដាប់ទី ២ ក្នុងក្រុមប្រឹក្សាអវត្តមាន ត្រូវជ្រើសយកសមាជិកក្រុមប្រឹក្សាដែលស្ថិតក្នុងលេខរៀងលំដាប់បន្តបន្ទាប់នៃបញ្ជីបេក្ខជនជាមួយនោះឱ្យធ្វើជាអធិបតីនៃអង្គប្រជុំ ។

មាត្រា ៦៦.-

រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សានឹងមានសុពលភាពទៅបាន លុះត្រាតែមានវត្តមានសមាជិកក្រុមប្រឹក្សាមិនតិចជាងពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាទាំងមូល ។

សមាជិកក្រុមប្រឹក្សាគ្រប់ៗរូបដែលមានវត្តមាននៅក្នុងអង្គប្រជុំ មានសិទ្ធិបោះឆ្នោតមួយសំឡេងដើម្បីអនុម័តរាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ។

ក្រុមប្រឹក្សាត្រូវអនុម័តដីកា ឬ សេចក្តីសម្រេច ដោយសំឡេងលើសពីពាក់កណ្តាល

ROYAUME DU CAMBODGE · LE MINISTRE ... PALAIS

នៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល ។

**មាត្រា ៦៧.-**

ក្នុងករណីមានសំឡេងឆ្នោតស្មើគ្នា សំឡេងរបស់អធិបតីនៃអង្គប្រជុំក្រុមប្រឹក្សាមានឧត្តមានុភាព ។

**មាត្រា ៦៨.-**

អង្គប្រជុំរបស់ក្រុមប្រឹក្សា ត្រូវធ្វើឡើងជាសាធារណៈ ។

ក្រុមប្រឹក្សាអាចប្រជុំជាសម្ងាត់បាន ។

កិច្ចដំណើរការនៃការប្រជុំជាសម្ងាត់ ត្រូវកំណត់ដោយសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៦៩.-**

អង្គប្រជុំរបស់ក្រុមប្រឹក្សាត្រូវអនុវត្តទៅតាមបទបញ្ជាផ្ទៃក្នុងសម្រាប់ការប្រជុំ តាមប្រភេទក្រុមប្រឹក្សានីមួយៗ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីគំរូបទបញ្ជាផ្ទៃក្នុងសម្រាប់ការប្រជុំ តាមប្រភេទក្រុមប្រឹក្សានីមួយៗ ។

**មាត្រា ៧០.-**

អង្គប្រជុំសាមញ្ញលើកទី ១ របស់ក្រុមប្រឹក្សា ត្រូវប្រារព្ធឡើងមិនឱ្យហួសពីដប់ប្រាំ (១៥)ថ្ងៃ បន្ទាប់ពីអង្គប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សា ។

**មាត្រា ៧១.-**

ក្នុងកិច្ចប្រជុំលើកទី ២ របស់ខ្លួន ក្រុមប្រឹក្សាត្រូវចាត់វិធានការដើម្បីអនុម័តបទបញ្ជាផ្ទៃក្នុងសម្រាប់ការប្រជុំរបស់ខ្លួនតាមទម្រង់ជាដីកា ។

ក្រុមប្រឹក្សាអាចអនុម័តយកគំរូបទបញ្ជាផ្ទៃក្នុងសម្រាប់ការប្រជុំ តាមការណែនាំរបស់ក្រសួងមហាផ្ទៃ ដោយមានការកែប្រែ ឬ ដោយមិនមានការកែប្រែ ។

**មាត្រា ៧២.-**

ក្រុមប្រឹក្សា ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងសម្រាប់ការប្រជុំរបស់ខ្លួន ។

សេចក្តីសម្រេចទាំងឡាយណាដែលធ្វើឡើងមិនស្របនឹងបទបញ្ជាផ្ទៃក្នុងសម្រាប់ការប្រជុំរបស់ក្រុមប្រឹក្សា សេចក្តីសម្រេចនោះពុំមានសុពលភាពឡើយ ។

**មាត្រា ៧៣.-**

សមាជិកក្រុមប្រឹក្សា មានសេរីភាពក្នុងការបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន ។

គ្មានសមាជិកក្រុមប្រឹក្សាណាម្នាក់ត្រូវបានចាប់ខ្លួន ឬ ឃុំខ្លួន ឬ ប្រឈមនឹងសកម្មភាព ឬ ចំណាត់ការណាមួយដោយសារតែហេតុផលនៃការបញ្ចេញមតិ ឬ ការបោះឆ្នោតរបស់ខ្លួនក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាឡើយ ។

**មាត្រា ៧៤.-**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវប្រជុំសាមញ្ញនៅក្នុងដែនដីរបស់ខ្លួនយ៉ាងហោចណាស់ចំនួនដប់ពីរ(១២)ដង ជារៀងរាល់ឆ្នាំ ។

អង្គប្រជុំសាមញ្ញក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវប្រារព្ធឡើងមិនឱ្យមុនម្ភៃប្រាំ(២៥)ថ្ងៃ ឬ លើសពីសាមសិបប្រាំ(៣៥)ថ្ងៃ បន្ទាប់ពីអង្គប្រជុំសាមញ្ញលើកមុនរបស់ក្រុមប្រឹក្សាបានឡើយ ។

**មាត្រា ៧៥.-**

ក្រុមប្រឹក្សា ត្រូវអនុម័តប្រតិទិននៃការប្រជុំសាមញ្ញរបស់ខ្លួន សម្រាប់រយៈពេលដប់ពីរ (១២)ខែ មិនឱ្យហួសពីអង្គប្រជុំសាមញ្ញលើកទី ២ និងសម្រាប់រយៈពេលជាបន្តបន្ទាប់ទៀតក្នុងរយៈពេលដប់ពីរ(១២)ខែម្តងៗ ដោយបញ្ជាក់អំពីកាលបរិច្ឆេទ និងទីកន្លែងជាក់លាក់ ។

**មាត្រា ៧៦.-**

ក្រុមប្រឹក្សា ត្រូវផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់នូវប្រតិទិននៃការប្រជុំសាមញ្ញរបស់ខ្លួន ។

មាត្រា ៧៧.-

ក្រុមប្រឹក្សា អាចកោះប្រជុំវិសាមញ្ញនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានតាមការចាំបាច់ ដើម្បីដោះស្រាយបញ្ហាបន្ទាន់ ឬ ពិសេសណាមួយ ។

## ផ្នែកទី ៥
## ទង្វើមិនស្របច្បាប់ ដោយក្រុមប្រឹក្សា ឬដោយបុគ្គលិករបស់ក្រុមប្រឹក្សា

មាត្រា ៧៨.-

សកម្មភាព ឬ សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សា ឬ សមាជិកក្រុមប្រឹក្សា ឬ គណៈកម្មាធិការ ឬ គណៈអភិបាល ឬ អភិបាល ឬ បុគ្គលិក ដែលធ្វើឡើងហួសពីសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា ឬ ហួសពីសិទ្ធិអំណាចរបស់សមាជិកក្រុមប្រឹក្សា ឬ របស់គណៈកម្មាធិការ ឬ របស់គណៈអភិបាល ឬ របស់អភិបាល ឬ របស់បុគ្គលិករបស់ក្រុមប្រឹក្សា គឺជាទង្វើមិនស្របច្បាប់ ។

មាត្រា ៧៩.-

សកម្មភាព ឬ សេចក្តីសម្រេចទាំងឡាយណាដែលខុសច្បាប់ សកម្មភាព ឬ សេចក្តីសម្រេចនោះ ពុំមានសុពលភាពឡើយ ។

មាត្រា ៨០.-

ការចំណាយទាំងឡាយណាដែលធ្វើឡើងដោយក្រុមប្រឹក្សា ឬ ក្នុងនាមក្រុមប្រឹក្សា ដើម្បីអនុវត្តសកម្មភាព ឬ សេចក្តីសម្រេចណាមួយដែលមិនស្របច្បាប់ គឺជាការចំណាយមិនស្របច្បាប់ ។

មាត្រា ៨១.-

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សា និងគណៈអភិបាលអំពីសកម្មភាព ឬ សេចក្តីសម្រេចមិនស្របច្បាប់ណាមួយ ដែលធ្វើឡើងដោយក្រុមប្រឹក្សា ឬ សមាជិកក្រុមប្រឹក្សា ឬ គណៈកម្មាធិការ ឬ គណៈអភិបាល ឬ អភិ-

បាល ឬ បុគ្គលិកក្រុមប្រឹក្សានោះ ។

ក្រោយទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្រុមប្រឹក្សា ឬ គណៈអភិបាល ត្រូវឆ្លើយបំភ្លឺតបវិញក្នុងរយៈពេលយ៉ាងយូរមួយ (០១)ខែ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវឆ្លើយតបវិញក្នុងរយៈពេលយ៉ាងយូរមួយ(០១)ខែ បើសិនក្រសួងយល់ឃើញថាទង្វើនោះមិនស្របច្បាប់ ។

**មាត្រា ៨២.-**

មុនពេលចេញដីកា ឬ សេចក្តីសម្រេច ឬ កិច្ចព្រមព្រៀងណាមួយ ក្រុមប្រឹក្សា ឬ គណៈអភិបាលអាចលើកសំណើជាលាយលក្ខណ៍អក្សរសុំយោបល់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រសិនបើយល់ឃើញថាបញ្ហាទាំងនោះជាបញ្ហារសើប ឬ មិនច្បាស់លាស់ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវឆ្លើយតបវិញនៅក្នុងរយៈពេលមួយ(០១)ខែ បន្ទាប់ពីបានទទួលសំណើនោះ ។

**មាត្រា ៨៣.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវផ្តល់យោបល់ដល់ក្រុមប្រឹក្សា និងគណៈអភិបាលអំពីវិធានការចាំបាច់ដើម្បីឱ្យក្រុមប្រឹក្សា ឬ គណៈអភិបាលធ្វើសកម្មភាព ឬ ធ្វើសេចក្តីសម្រេចឱ្យបានស្របច្បាប់ឡើងវិញ ។

**មាត្រា ៨៤.-**

ក្នុងករណីដែលក្រុមប្រឹក្សាបានអនុវត្តរួចហើយនូវសកម្មភាព ឬ សេចក្តីសម្រេចមិនស្របច្បាប់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំក្រុមប្រឹក្សា ឱ្យចាត់វិធានការចាំបាច់នានានៅក្នុងក្របខ័ណ្ឌសិទ្ធិអំណាចរបស់ខ្លួន ដើម្បីធ្វើសកម្មភាព ឬ សេចក្តីសម្រេចឱ្យបានស្របច្បាប់ឡើងវិញនៅក្នុងរយៈពេលមួយ(០១)ខែ ។

ក្រុមប្រឹក្សា ត្រូវផ្សព្វផ្សាយជាសាធារណៈភ្លាមនូវការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃទាក់ទងនឹងបញ្ហានេះ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។



**មាត្រា ៨៥.-**

ក្នុងករណីដែលក្រុមប្រឹក្សាមិនអាចធ្វើឱ្យសកម្មភាព ឬ សេចក្តីសម្រេចមិនស្របច្បាប់ ឱ្យស្របតាមច្បាប់ឡើងវិញនៅក្នុងសិទ្ធិអំណាចរបស់ខ្លួននោះ ក្រុមប្រឹក្សាត្រូវលុបចោលសកម្មភាព ឬ សេចក្តីសម្រេចមិនស្របច្បាប់នៅក្នុងអង្គប្រជុំរបស់ខ្លួន និងត្រូវផ្សព្វផ្សាយជាសាធារណៈពីការលុបចោលនោះ ។

ជនណា ឬ បុគ្គលណាដែលបានទទួលរងនូវការខូចខាត ឬ បានបង់ពន្ធ ឬ កម្រៃ ដោយសារតែសកម្មភាព ឬ សេចក្តីសម្រេចមិនស្របច្បាប់នោះ អាចទាមទារឱ្យក្រុមប្រឹក្សាផ្តល់សំណង និងការបង់ប្រាក់មកវិញឱ្យបានគ្រប់ចំនួន ។

ជនណាដែលត្រូវបានក្រុមប្រឹក្សាបដិសេធមិនផ្តល់សំណង ឬ ការបង់ប្រាក់មកឱ្យវិញនៅក្នុងរយៈពេលពីរ(០២)ខែ ជននោះអាចជូនដំណឹង និងអាចប្តឹងតវ៉ាទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីសម្របសម្រួលដោះស្រាយ ។

ក្នុងករណីដែលជនណាមិនឯកភាពតាមការសម្របសម្រួលដោះស្រាយរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជននោះមានសិទ្ធិប្តឹងទៅតុលាការ ។

**មាត្រា ៨៦.-**

ការចំណាយ ឬ ផលប៉ះពាល់ពីសេចក្តីសម្រេចមិនស្របច្បាប់ណាមួយ ដែលធ្វើឡើងដោយក្រុមប្រឹក្សា ឬ ក្នុងនាមក្រុមប្រឹក្សានោះ ក្រុមប្រឹក្សាត្រូវទទួលសងនូវការចំណាយ ឬ សងការខូចខាតដែលមានផលប៉ះពាល់ពីសេចក្តីសម្រេច ឬ សកម្មភាពមិនស្របច្បាប់នោះមកវិញ នៅក្នុងរយៈពេលមួយ(០១)ខែ ។

**មាត្រា ៨៧.-**

ក្នុងករណីដែលការចំណាយមិនស្របច្បាប់ធ្វើឡើង ដើម្បីអនុវត្តសេចក្តីសម្រេច ឬ សកម្មភាពរបស់ក្រុមប្រឹក្សាឬគណៈកម្មាធិការណាមួយ ឬ គណៈអភិបាល ហើយដែលសមាជិកក្រុមប្រឹក្សា ឬ គណៈអភិបាលទាំងមូលបានគាំទ្រសកម្មភាព ឬ សេចក្តីសម្រេចនោះ សមាជិកក្រុមប្រឹក្សាម្នាក់ៗ ឬ គណៈអភិបាលម្នាក់ៗនោះ ត្រូវទទួលសងការចំណាយដែលមិនស្របច្បាប់ឱ្យបានគ្រប់ចំនួនមកវិញក្នុងចំណែកស្មើៗគ្នា ។

ក្នុងករណីដែលការចំណាយមិនស្របច្បាប់ មិនបានធ្វើឡើងដើម្បីអនុវត្តសេចក្តីសម្រេច ឬ សកម្មភាពរបស់ក្រុមប្រឹក្សា ឬ គណៈកម្មាធិការណាមួយ ឬ គណៈអភិបាលទេនោះ ការចំណាយមិនស្របច្បាប់ទាំងអស់ ត្រូវទទួលសងឱ្យបានគ្រប់ចំនួនពីសមាជិកក្រុមប្រឹក្សាជាក់លាក់ណាមួយ ឬ ពីអភិបាល ឬ អភិបាលរង ឬ ពីបុគ្គលិកជាក់លាក់ណាមួយដែលទទួលខុសត្រូវចំពោះសកម្មភាព ឬ សេចក្តីសម្រេចនោះ ។

មាត្រា ៨៨.-

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចធ្វើប្រតិភូកម្មទៅឱ្យក្រុមប្រឹក្សាស្រុក ដើម្បីពិនិត្យនីត្យានុកូលភាពនៃការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ តាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់នេះ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

## ផ្នែកទី ៦

## ការដោះស្រាយវិវាទនៅមូលដ្ឋាន

មាត្រា ៨៩.-

ក្រុមប្រឹក្សាត្រូវចាត់វិធានការសមស្រប ដើម្បីដោះស្រាយវិវាទនៅមូលដ្ឋានដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

មាត្រា ៩០.-

វិវាទនៅមូលដ្ឋាន គឺជាវិវាទមានលក្ខណៈឯកជនរវាងប្រជាពលរដ្ឋដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាជាមួយគ្នា ឬ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាផ្សេងគ្នា ។

មាត្រា ៩១.-

ការដោះស្រាយវិវាទ ត្រូវផ្អែកតាមពាក្យបណ្តឹងរបស់ភាគីណាមួយ ឬ ភាគីទាំងសងខាង នៅក្នុងវិវាទទៅក្រុមប្រឹក្សាដែលភាគីនោះស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ ។

**មាត្រា ៩២.-**

ក្រុមប្រឹក្សាត្រូវសម្រុះសម្រួលដោះស្រាយវិវាទនៅមូលដ្ឋាន ដោយផ្អែកតាមលក្ខណៈដែលអាចទទួលយកបានដោយភាគីនៅក្នុងវិវាទទាំងសងខាង ។

ក្នុងករណីភាគីណាមួយនៅក្នុងវិវាទ មិនអាចទទួលយកបាននូវការសម្រុះសម្រួលដោះស្រាយ ក្រុមប្រឹក្សាត្រូវណែនាំភាគីនោះអំពីនីតិវិធីតាមផ្លូវច្បាប់សម្រាប់បន្តដោះស្រាយវិវាទនោះ ។

**មាត្រា ៩៣.-**

ក្នុងករណីមានសំណូមពរ ឬ ការតវ៉ានានាពីប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្រុមប្រឹក្សាត្រូវពិនិត្យ និងដោះស្រាយសំណូមពរ ឬ ការតវ៉ានោះឱ្យបានសមស្រប ។

ក្នុងករណីសំណូមពរ ឬ ការតវ៉ានោះស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន ក្រុមប្រឹក្សាត្រូវចាត់វិធានការដោះស្រាយ រួចហើយត្រូវជូនដំណឹងទៅប្រជាពលរដ្ឋវិញ ។

ករណីសំណូមពរ ឬ ការតវ៉ានោះមិនស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន ក្រុមប្រឹក្សាត្រូវធ្វើសេចក្ដីរាយការណ៍ជូនក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬ ក្រុមប្រឹក្សាដែលពាក់ព័ន្ធ ដើម្បីដោះស្រាយ ។

**មាត្រា ៩៤.-**

ក្នុងការសម្រុះសម្រួលដោះស្រាយវិវាទនៅមូលដ្ឋាន ក្រុមប្រឹក្សាមិនត្រូវធ្វើសេចក្ដីសម្រេចទៅលើបញ្ហាទាំងឡាយណាដែលពាក់ព័ន្ធ ករណីដូចខាងក្រោម :

-ការលែងលះ

-អំពើហិង្សាក្នុងគ្រួសារដែលមានលក្ខណៈជាបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិម

-បទល្មើសឧក្រិដ្ឋ ឬ មជ្ឈិមដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ឬ ករណីដែលស្ថិតនៅក្នុងក្របខ័ណ្ឌសណ្ដាប់ធ្នាប់សាធារណៈ

-វិវាទដែលកំពុងដោះស្រាយដោយតុលាការ ឬ ដែលមានសេចក្ដីសម្រេចពីតុលាការ

-វិវាទដែលច្បាប់ ឬ ដែលរាជរដ្ឋាភិបាលបានកំណត់ឱ្យស្ថាប័ន ឬ យន្តការ

ជាក់លាក់ណាមួយសម្រុះសម្រួលដោះស្រាយ ។

**មាត្រា ៩៥.-**

នីតិវិធីក្នុងការដោះស្រាយវិវាទនៅមូលដ្ឋាន ត្រូវផ្អែកតាមច្បាប់ ឬ អនុក្រឹត្យ ។

## ផ្នែកទី ៧
## បទប្បញ្ញត្តិពិសេសសម្រាប់ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ដែលស្ថិតក្នុងស្រុក

**មាត្រា ៩៦.-**

ក្រុមប្រឹក្សាស្រុក ត្រូវបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យក្នុងស្រុករបស់ខ្លួន ។

**មាត្រា ៩៧.-**

ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងស្រុក ក្រុមប្រឹក្សាស្រុកត្រូវ :

-ជួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់នីមួយៗឱ្យបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាព សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

-រួមជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដើម្បីជំរុញឱ្យមានការចូលរួមពីសាធារណជន នៅក្នុងដំណើរការអភិបាលកិច្ចនៅក្នុងស្រុក និងឃុំ សង្កាត់

-ស្វែងយល់និងឆ្លើយតប ចំពោះតម្រូវការក្នុងស្រុករបស់ខ្លួន និងសំណើរបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ។

**មាត្រា ៩៨.-**

ក្រុមប្រឹក្សាស្រុកត្រូវមានគណនេយ្យភាព ចំពោះក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់និងប្រជាពលរដ្ឋទាំងអស់នៅក្នុងស្រុកអំពីជម្រើស សេចក្តីសម្រេច ការអនុវត្តរបស់ខ្លួន ព្រមទាំងផលប៉ះពាល់នៃជម្រើស សេចក្តីសម្រេច និងការអនុវត្តទាំងនោះ ។



**មាត្រា ៩៩.-**

ក្រុមប្រឹក្សាស្រុក ត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់និង អ្នកពាក់ព័ន្ធនានា ដើម្បីវាយតម្លៃឱ្យ បានទៀងទាត់អំពីសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និងធ្វើការបណ្តុះបណ្តាល កសាងសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និងបុគ្គលិករបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ព្រមទាំងធ្វើការអប់រំបណ្តុះបណ្តាលដល់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់នីមួយៗឱ្យ បានទៀងទាត់ ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យ មានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលស្គាល់គុណភាពនៃការអប់រំបណ្តុះបណ្តាល ដែលស្របជាមួយខ្លឹមសារនៃច្បាប់នេះ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

**មាត្រា ១០០.-**

ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ដែលពាក់ព័ន្ធ ត្រូវដាក់បញ្ចូល យុទ្ធសាស្ត្រ កម្មវិធី និងសកម្មភាពដែលបានកំណត់ សម្រាប់ឆ្លើយតបទៅនឹងតម្រូវការនិង សំណើរបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ទៅក្នុងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិល ប្រចាំឆ្នាំ និងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំរបស់ស្រុក និងរបស់ឃុំ សង្កាត់ព្រមទាំងគម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់ស្រុក និងឃុំ សង្កាត់ ។

**មាត្រា ១០១.-**

បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ក្រុមប្រឹក្សាស្រុកត្រូវសម្របសម្រួល និងគាំទ្រដល់ការបង្កើនសមត្ថភាពផ្នែករដ្ឋបាល ឬ ធនធានផ្នែករដ្ឋបាលដែលចាំបាច់ដល់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដើម្បីឱ្យ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ មានសមត្ថភាពផ្នែករដ្ឋបាល ឬ ធនធានផ្នែករដ្ឋបាលគ្រប់គ្រាន់ និងជាអចិន្ត្រៃយ៍ដើម្បី :

- ជំរុញ ឬ ធ្វើឱ្យ មានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ឬ បំពេញមុខងារ ភារកិច្ចចាំបាច់មួយ ឬ ច្រើន

ROYAUME du CAMBODGE LE MINISTRE du PALAIS ROYAL

-បំពេញសមត្ថភាពផ្នែករដ្ឋបាល និងធនធានផ្នែករដ្ឋបាល រួមទាំងបុគ្គលិក ឧបករណ៍ ទ្រព្យសម្បត្តិ និងសម្ភារៈចាំបាច់នានា ។

**មាត្រា ១០២.-**

ការរៀបចំចាត់ចែងបង្កើនសមត្ថភាពផ្នែករដ្ឋបាល ឬ ធនធានផ្នែករដ្ឋបាលនៅក្នុងឃុំ សង្កាត់ អាចធ្វើឡើងដោយអនុញ្ញាតឱ្យក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ពីរ ឬ ច្រើន ប្រើប្រាស់រួមគ្នានូវបុគ្គលិក ឧបករណ៍ ទ្រព្យសម្បត្តិ ឬ សម្ភារៈខ្លះ ឬ ទាំងអស់តាមការចាំបាច់ ។

**មាត្រា ១០៣.-**

ក្នុងករណីដែលក្រុមប្រឹក្សាស្រុកបានប្រឹងប្រែងសម្របសម្រួលបង្កើនសមត្ថភាពផ្នែករដ្ឋបាល ឬ ធនធានផ្នែករដ្ឋបាលដល់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់រួចហើយ ប៉ុន្តែក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់នោះនៅតែមិនអាចបំពេញភារកិច្ចជាមូលដ្ឋាន និងចាំបាច់របស់ខ្លួនបាន ឬ មិនអាចជំរុញការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យឱ្យបានគ្រប់គ្រាន់ ក្រុមប្រឹក្សាស្រុកត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដើម្បីរាយការណ៍ជាលាយលក្ខណ៍អក្សរជាបន្ទាន់ទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

របាយការណ៍ខាងលើនេះ ត្រូវដាក់បញ្ចូលនូវអនុសាសន៍សម្រេបអំពីសំណើកែតម្រូវកង្វះខាតទាំងនេះ ។

**មាត្រា ១០៤.-**

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឯកភាពតាមរបាយការណ៍របស់ក្រុមប្រឹក្សាស្រុក រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើការពិគ្រោះពិភាក្សាជាមួយក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ពាក់ព័ន្ធ ដើម្បីរៀបចំផ្តល់ការគាំទ្រដល់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ឱ្យមានសមត្ថភាពក្នុងការជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យឱ្យមានប្រសិទ្ធភាព ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ១០៥.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្តដើម្បីអនុវត្តបទប្បញ្ញត្តិចាំបាច់មួយចំនួនក្នុងផ្នែកទី ៧ នៃច្បាប់នេះ ។

## ផ្នែកទី ៨
## រាជធានីភ្នំពេញ

**មាត្រា ១០៦.-**

ក្រុមប្រឹក្សារាជធានីភ្នំពេញត្រូវមានដែនសមត្ថកិច្ចនៅក្នុងតំបន់របស់ខ្លួន សម្រាប់បង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

**មាត្រា ១០៧.-**

ក្រុមប្រឹក្សាសង្កាត់ និងក្រុមប្រឹក្សាខណ្ឌ ត្រូវស្ថិតក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សារាជធានីភ្នំពេញ ។

**មាត្រា ១០៨.-**

ក្រុមប្រឹក្សារាជធានីភ្នំពេញត្រូវធ្វើប្រតិភូកម្មមុខងារ និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាសង្កាត់ ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

**មាត្រា ១០៩.-**

តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ផ្នែកទី ៩
## ក្រុងក្រៅពីរាជធានីភ្នំពេញ

**មាត្រា ១១០.-**

ក្រុមប្រឹក្សាក្រុងត្រូវមានដែនសមត្ថកិច្ចក្នុងតំបន់របស់ខ្លួនសម្រាប់បង្កើត ជំរុញនិង

ធ្វើឱ្យ មានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

**មាត្រា ១១១.-**

ក្រុមប្រឹក្សាសង្កាត់ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សាក្រុង ។

**មាត្រា ១១២.-**

ក្រុមប្រឹក្សាក្រុងត្រូវធ្វើប្រតិភូកម្មមុខងារ ភារកិច្ច ទៅឱ្យ ក្រុមប្រឹក្សាសង្កាត់ ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យ មានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

**មាត្រា ១១៣.-**

តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាសង្កាត់ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៣
## អំពីគណៈកម្មាធិការក្រុមប្រឹក្សា និងគណៈអភិបាល
### ផ្នែកទី ១
### គណៈកម្មាធិការរបស់ក្រុមប្រឹក្សា

**មាត្រា ១១៤.-**

ក្រុមប្រឹក្សា មានកាតព្វកិច្ចរៀបចំឱ្យ មានគណៈកម្មាធិការដូចខាងក្រោម ៖

-គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

-គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

-គណៈកម្មាធិការលទ្ធកម្ម ។

**មាត្រា ១១៥.-**

ក្រៅពីគណៈកម្មាធិការទាំងបីខាងលើនេះ ក្រុមប្រឹក្សាអាចបង្កើតគណៈកម្មាធិការបន្ថែមទៀត ដើម្បីជួយការងាររបស់ក្រុមប្រឹក្សាតាមការចាំបាច់ ។

ក្រុមប្រឹក្សាអាចតែងតាំងសមាជិកក្រុមប្រឹក្សា អភិបាល អភិបាលរង បុគ្គលិកក្រុមប្រឹក្សាជាសមាជិកគណៈកម្មាធិការបាន ។

គណៈកម្មាធិការខាងលើនេះ មិនត្រូវមានតួនាទី ភារកិច្ចត្រួតគ្នាជាមួយនឹងតួនាទី ភារកិច្ចរបស់គណៈកម្មាធិការទាំងបីរបស់ក្រុមប្រឹក្សា ឬ តួនាទី ភារកិច្ចរបស់គណៈអភិបាលឡើយ ។

**មាត្រា ១១៦.-**

ក្រុមប្រឹក្សា ត្រូវសម្រេចអំពីចំនួនសមាជិកគណៈកម្មាធិការនីមួយៗ អំពីការតែងតាំងប្រធាន អនុប្រធាន និងអំពីការកំណត់តួនាទី ភារកិច្ច សកម្មភាពរបស់គណៈកម្មាធិការនីមួយៗដែលខ្លួនបានបង្កើតឡើង ។

**មាត្រា ១១៧.-**

ក្រុមប្រឹក្សា អាចអនុញ្ញាតឱ្យគណៈកម្មាធិការនីមួយៗជ្រើសរើសបុគ្គល ដែលមិនមែនជាសមាជិកក្រុមប្រឹក្សា ធ្វើជាទីប្រឹក្សាតាមការចាំបាច់ ។

**មាត្រា ១១៨.-**

ក្រុមប្រឹក្សា ត្រូវធានាឱ្យមានតំណាងស្ត្រីនៅក្នុងគណៈកម្មាធិការរបស់ខ្លួនរួមទាំងប្រធាន ឬ អនុប្រធានគណៈកម្មាធិការផង ។

**មាត្រា ១១៩.-**

គណៈកម្មាធិការនីមួយៗនៃក្រុមប្រឹក្សា ត្រូវរាយការណ៍អំពីសកម្មភាពរបស់ខ្លួនឱ្យបានទៀងទាត់ឱ្យក្រុមប្រឹក្សា និងគណៈអភិបាល ។

**មាត្រា ១២០.-**

ក្រុមប្រឹក្សា អាចបញ្ឈប់សមាជិកណាមួយពីគណៈកម្មាធិការដែលខ្លួនបានបង្កើតឡើង ។

ក្នុងករណីដែលសមាជិកគណៈកម្មាធិការនោះ ជាសមាជិកក្រុមប្រឹក្សា សមាជិកនោះនៅតែជាសមាជិកក្រុមប្រឹក្សាដដែល ។

**មាត្រា ១២១.-**

ក្រុមប្រឹក្សា ត្រូវទទួលខុសត្រូវរាល់សេចក្តីសម្រេច និងសកម្មភាពរបស់គណៈកម្មាធិការនានា ដែលខ្លួនបានបង្កើតឡើង និងទទួលខុសត្រូវចំពោះផលវិបាកពីសកម្មភាពរបស់គណៈកម្មាធិការទាំងនោះ ។

**មាត្រា ១២២.-**

ក្រុមប្រឹក្សា ត្រូវផ្តល់ការគាំទ្រកិច្ចការផ្នែកលេខាធិការដ្ឋាន និងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការនានាដែលខ្លួនបានបង្កើតឡើង ។

## ផ្នែកទី ២

## គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

**មាត្រា ១២៣.-**

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស មានសមាសភាព :

- អភិបាល ជាប្រធាន
- ប្រធានអង្គភាពទាំងអស់របស់ក្រុមប្រឹក្សា
- ប្រធានហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា
- ប្រធានមន្ទីរ អង្គភាពនៃក្រសួង ស្ថាប័ននានារបស់រដ្ឋាភិបាលដែលផ្តល់សេវាសម្ភារៈ ឬ ហេដ្ឋារចនាសម្ព័ន្ធដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ។
- តំណាងផ្សេងៗទៀតតាមការចាំបាច់ ។

**មាត្រា ១២៤.-**

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសត្រូវខិតខំធានាឱ្យបានថា ផែនការអភិវឌ្ឍនិងថវិការបស់ក្រសួង ស្ថាប័ន ឬ មន្ទីរ អង្គភាពនានារបស់រដ្ឋាភិបាលដែលផ្តល់សេវាសម្ភារៈ ឬ ហេដ្ឋារចនាសម្ព័ន្ធដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ត្រូវធានាថាមានការបញ្ចូលយ៉ាងត្រឹមត្រូវទៅក្នុងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងគម្រោងថវិកា

ប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ១២៥.-**

ក្រសួងមហាផ្ទៃ អាចកំណត់ឱ្យក្រុមប្រឹក្សាពីរ ឬ ច្រើនប្រើប្រាស់រួមគ្នានូវគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ។

**មាត្រា ១២៦.-**

ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ផ្នែកទី ៣

## គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

**មាត្រា ១២៧.-**

សមាជិកគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ត្រូវជ្រើសរើសចេញពីក្នុងចំណោមសមាជិកក្រុមប្រឹក្សាជាស្ត្រីនៅក្នុងក្រុមប្រឹក្សានោះ ឬ ស្ត្រី និងបុរស នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ។

**មាត្រា ១២៨.-**

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារមានសិទ្ធិ និងមានភារកិច្ចផ្តល់យោបល់និងលើកអនុសាសន៍ជូនក្រុមប្រឹក្សា គណៈអភិបាល អភិបាល និងគណៈកម្មាធិការដទៃទៀតរបស់ក្រុមប្រឹក្សា លើបញ្ហាពាក់ព័ន្ធនឹងសមភាពយេនឌ័រ បញ្ហាស្ត្រី និងកុមារដែលស្ថិតនៅក្នុងអំណាច មុខងារ និងភារកិច្ចរបស់ក្រុមប្រឹក្សា ។

**មាត្រា ១២៩.-**

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារមានសិទ្ធិចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា គណៈកម្មាធិការនានា និងគណៈអភិបាល ។

ROYAUME DU CAMBODGE • LE MINISTÈRE DU PALAIS ROYAL •
ព្រះរាជាណាចក្រកម្ពុជា

**មាត្រា ១៣០.-**

ក្នុងការចូលរួមក្នុងកិច្ចប្រជុំខាងលើនេះ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ មានសិទ្ធិទទួលបាននូវរបៀបវារៈប្រជុំ និងឯកសារសម្រាប់កិច្ចប្រជុំដូចសមាជិកអង្គប្រជុំដទៃទៀតដែរ ។

**មាត្រា ១៣១.-**

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ អាចចាត់តាំងសមាជិករបស់ខ្លួនយ៉ាងច្រើនពីរ(០២)រូប ដើម្បីចូលរួមក្នុងរាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា គណៈអភិបាល និងកិច្ចប្រជុំនៃគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ។

សមាជិកដែលបានចាត់តាំងទាំងនេះ មានសិទ្ធិបញ្ចេញយោបល់ក្នុងកិច្ចប្រជុំនានាដូចគ្នានឹងសមាជិកដទៃទៀតនៃអង្គប្រជុំដែរ ។

**មាត្រា ១៣២.-**

ក្នុងករណីសមាជិកដែលត្រូវបានចាត់តាំងឱ្យចូលរួមក្នុងកិច្ចប្រជុំ ដូចមានចែងក្នុងមាត្រា ១៣១ ជាសមាជិកក្រុមប្រឹក្សា សមាជិកនោះមានសិទ្ធិបោះឆ្នោតអនុម័តក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ប៉ុន្តែមិនមានសិទ្ធិបោះឆ្នោតអនុម័តក្នុងកិច្ចប្រជុំរបស់គណៈអភិបាលបានឡើយ ។

**មាត្រា ១៣៣.-**

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំ ដើម្បីដាក់បញ្ចូលនៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា ។

**មាត្រា ១៣៤.-**

របាយការណ៍ប្រចាំឆ្នាំខាងលើនេះ ត្រូវរួមបញ្ចូលនូវ :

-ស្ថានភាពរួមនៃការចូលរួមរបស់ស្ត្រី ក្នុងការលើកកម្ពស់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យ និងស្ថានភាពរបស់កុមារ នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា

-លទ្ធផល និងបញ្ហាប្រឈមរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ស្ត្រី និងកុមារ និងអនុសាសន៍ ដើម្បីពង្រឹងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

-អនុសាសន៍ដើម្បីធ្វើឱ្យប្រសើរឡើងនូវការចូលរួមរបស់ស្ត្រីក្នុងការលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

**មាត្រា ១៣៥.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចចេញប្រកាសណែនាំអំពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារតាមការចាំបាច់ ដោយផ្អែកតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

## ផ្នែកទី ៤
## គណៈកម្មាធិការលទ្ធកម្ម

**មាត្រា ១៣៦.-**

គណៈកម្មាធិការលទ្ធកម្មមានសិទ្ធិ និងភារកិច្ចធានាឱ្យសកម្មភាពកិច្ចលទ្ធកម្មទាំងអស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រព្រឹត្តធ្វើឡើងប្រកបដោយភាពស្មោះត្រង់ បើកចំហ តម្លាភាព មិនលំអៀង ដោយអនុលោមតាមច្បាប់ បទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ដើម្បីការពារផលប្រយោជន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋរបស់ខ្លួន ។

**មាត្រា ១៣៧.-**

ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ផ្នែកទី ៥
## គណៈអភិបាល

**មាត្រា ១៣៨.-**

ត្រូវរៀបចំឱ្យមានគណៈអភិបាលសម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ១៣៩.-**

គណៈអភិបាលរួមមាន ប្រធានមួយរូប ដែលហៅថា អភិបាល និងអភិបាលរងមួយចំនួន ។

**មាត្រា ១៤០.-**

គណៈអភិបាលរាជធានីភ្នំពេញមានចំនួនយ៉ាងច្រើនប្រាំពីរ(០៧)រូប ។

គណៈអភិបាលខេត្តមានចំនួនពីបី(០៣)រូប ទៅប្រាំពីរ(០៧)រូប ។

គណៈអភិបាលក្រុង ស្រុក ខណ្ឌមានចំនួនពីបី(០៣)រូប ទៅប្រាំ(០៥)រូប ។

ចំនួនជាក់ស្តែងនៃគណៈអភិបាល សម្រាប់ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៤១.-**

អភិបាលរាជធានី អភិបាលខេត្ត ត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

អភិបាលរងរាជធានី អភិបាលរងខេត្ត អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌ ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

អភិបាលរងក្រុង អភិបាលរងស្រុក អភិបាលរងខណ្ឌ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៤២.-**

អភិបាលរាជធានី អភិបាលខេត្ត ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទ ដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ដែលមានលក្ខណសម្បត្តិដូចខាងក្រោម ៖

-មានឋានន្តរសក្តិឧត្តមមន្ត្រី

-មានអាយុចាប់ពីសាមសិបប្រាំ(៣៥)ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង

-មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនប្រាំពីរ(០៧) ឆ្នាំ និងមានសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា

ROYAUME DE CAMBODGE - LE MINISTRE DU PALAIS ROYAL

-មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង

-មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ ។

មាត្រា ១៤៣.-

អភិបាលរងរាជធានី អភិបាលរងខេត្ត ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរប្រភេទ ដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃដែលមានលក្ខណៈសម្បត្តិ ដូចខាងក្រោម ៖

-មានឋានន្តរសក្តិ ចាប់ពីវរមន្ត្រីឡើងទៅ

-មានអាយុចាប់ពីសាមសិបប្រាំ(៣៥)ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង

-មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនប្រាំ(០៥)ឆ្នាំ ឬ/និងមានសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា

-មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង

-មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ ។

មាត្រា ១៤៤.-

អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌ ត្រូវធ្វើការជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ដែលមានលក្ខណសម្បត្តិ ដូចខាងក្រោម ៖

-មានឋានន្តរសក្តិចាប់ពីអនុមន្ត្រីឡើង

-មានអាយុ ចាប់ពីសាមសិប(៣០)ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង

-មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនប្រាំ(០៥)ឆ្នាំ ឬ/និងមានសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា

-មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង

-មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ ។

មាត្រា ១៤៥.-

អភិបាលរងក្រុង អភិបាលរងស្រុក អភិបាលរងខណ្ឌ ត្រូវធ្វើការជ្រើសរើសពីក្នុង

ចំណោមមន្ត្រីទាំងពីរភេទ ដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ដែលមានលក្ខណសម្បត្តិដូចខាងក្រោម :

-មានឋានន្តរសក្តិចាប់ពីនាយក្រមការឡើង

-មានអាយុចាប់ពីម្ភៃប្រាំ(២៥) ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង

-មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនបី(០៣)ឆ្នាំ ឬ/និងមានសញ្ញាបត្របរិញ្ញាបត្ររងដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជននិងកីឡា

-មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង

-មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ ។

**មាត្រា ១៤៦.-**

ក្នុងករណីចាំបាច់ អភិបាល អភិបាលរង អាចជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ក្រៅពីក្របខ័ណ្ឌក្រសួងមហាផ្ទៃបាន ប៉ុន្តែមន្ត្រីនោះត្រូវមានលក្ខណសម្បត្តិ សមស្របតាមមាត្រា ១៤២ មាត្រា ១៤៣ មាត្រា ១៤៤ និងមាត្រា ១៤៥ នៃច្បាប់នេះ ។

**មាត្រា ១៤៧.-**

អភិបាល អភិបាលរង មានអាណត្តិការងារមិនលើសពីបួន(០៤)ឆ្នាំ ។

អភិបាល អភិបាលរងអាចត្រូវបានតែងតាំងបានបួន(០៤)ឆ្នាំទៀត សម្រាប់អាណត្តិទី ២ របស់ខ្លួននៅក្នុងដែនសមត្ថកិច្ចដដែល ។

**មាត្រា ១៤៨.-**

អភិបាល អភិបាលរងមិនមែនជាសមាជិកក្រុមប្រឹក្សាឡើយ ។

**មាត្រា ១៤៩.-**

អភិបាល អភិបាលរងអាចចូលរួមគ្រប់អង្គប្រជុំ និងមានសិទ្ធិបញ្ចេញមតិក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាបាន តែមិនអាចធ្វើការបោះឆ្នោតបានឡើយ ។

ROYAUME DU CAMBODGE
LE MINISTRE ... ROYAL
ព្រះបរមរាជវាំង

**មាត្រា ១៥០.-**

អភិបាល អភិបាលរង ត្រូវបញ្ឈប់ពីមុខតំណែងនៅមុនពេលបញ្ចប់អាណត្តិការងារ ប្រសិនបើសាមីខ្លួន ៖

-ដាក់ពាក្យលាលែងជាលាយលក្ខណ៍អក្សរជូនទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬ

-ត្រូវបានដកហូតពីមុខតំណែង ។

**មាត្រា ១៥១.-**

អភិបាល អភិបាលរងណាមួយ ត្រូវដកហូតពីមុខតំណែងមុនពេលបញ្ចប់អាណត្តិការងារ ក្នុងករណីណាមួយដូចខាងក្រោម ៖

-បាត់បង់លក្ខណសម្បត្តិជាអភិបាល ឬ អភិបាលរង

-អសមត្ថភាព

-បំពេញការងារមិនបានល្អ

-មានបញ្ហាសុខភាព ឬ បាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច

-បោះបង់ចោលការងារ

-ប្រព្រឹត្តខុសឆ្គងពីក្រមសីលធម៌វិជ្ជាជីវៈ ។

**មាត្រា ១៥២.-**

ក្រុមប្រឹក្សា អាចស្នើជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីដកហូតអភិបាល អភិបាលរងចេញពីមុខតំណែង ដោយផ្អែកតាមករណីណាមួយក្នុងចំណោមករណីដូចមានចែងក្នុងមាត្រា ១៥១ នៃច្បាប់នេះ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់នូវសំណើខាងលើនេះ ដើម្បីធ្វើសេចក្តីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ពិនិត្យសម្រេចចំពោះអភិបាលរាជធានី អភិបាលខេត្ត អភិបាលរងរាជធានី អភិបាលរងខេត្ត អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌ ។

ចំពោះអភិបាលរងក្រុង ស្រុក ខណ្ឌ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើការស៊ើបអង្កេត និងសម្រេចលើសំណើនោះ ដោយជាបន្ទាន់ ។

មាត្រា ១៥៣.-

អភិបាល អភិបាលរង ត្រូវទទួលប្រាក់បៀវត្ស និងអាចទទួលកម្រៃផ្សេងៗទៀតដែលសមស្របទឹងមុខតំណែងនេះ ។

ប្រាក់បៀវត្ស និងកម្រៃផ្សេងៗទៀតរបស់អភិបាល អភិបាលរងត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយរដ្ឋ-មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ១៥៤.-

អភិបាល មានតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដើម្បីណែនាំ សម្របសម្រួល តម្រង់ទិសមន្ទីរ អង្គភាព ខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ននានា និងទីភ្នាក់ងារនានារបស់រាជរដ្ឋាភិបាល ដែលធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ។

អភិបាល ត្រូវធ្វើជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការងារ សន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ ច្បាប់ និងសិទ្ធិមនុស្សក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្នុងតួនាទីជាតំណាងរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល អភិ-បាល ត្រូវមានគណនេយ្យភាព ចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័ននានា ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចស្នើរាជរដ្ឋាភិបាលចេញអនុក្រឹត្យដើម្បីកំណត់តួនាទី សិទ្ធិអំណាចរបស់អភិបាលក្នុងតួនាទីជាតំណាងរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ននានា តាមការចាំបាច់ ។

មាត្រា ១៥៥.-

គណៈអភិបាល ត្រូវផ្តល់យោបល់ជូនក្រុមប្រឹក្សា រាយការណ៍ជូនក្រុមប្រឹក្សា និងជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ។

គណៈអភិបាល ត្រូវជួយក្រុមប្រឹក្សា ដើម្បីឱ្យក្រុមប្រឹក្សាសម្រេចបាននូវការអនុវត្ត

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL ព្រះបរមរាជវាំង

មុខងារ សិទ្ធិអំណាច និងភារកិច្ចរបស់ខ្លួន ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ១៥៦.-**

គណៈអភិបាល ត្រូវជួយក្រុមប្រឹក្សាក្នុងការពិនិត្យមើលមុខងារ ភារកិច្ច និងធនធានទាំងអស់ ដែលបានបែងចែក ឬ បានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយច្បាប់នេះ ឬ ដែលស្របតាមច្បាប់នេះ រួចហើយត្រូវផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាអំពីរបៀបបំពេញមុខងារ ភារកិច្ច និងការចាត់ចែងធនធានទាំងនោះ ។

**មាត្រា ១៥៧.-**

ក្រុមប្រឹក្សាត្រូវត្រួតពិនិត្យសកម្មភាព និងការអនុវត្តរបស់គណៈអភិបាល និងអភិបាល ។

ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាអាចកោះអញ្ជើញគណៈអភិបាល ឬ អភិបាល និងបុគ្គលដែលពាក់ព័ន្ធមកសាកសួរបំភ្លឺក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ក្រុមប្រឹក្សា ។

**មាត្រា ១៥៨.-**

គណៈអភិបាល ឬ អភិបាលដែលបានសម្រេច ឬ បានអនុវត្តកិច្ចការណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សា ការសម្រេច ឬ សកម្មភាពនោះ ពុំមានសុពលភាពបានឡើយ ។

**មាត្រា ១៥៩.-**

គណៈអភិបាល ត្រូវរាយការណ៍ជូនក្រុមប្រឹក្សាអំពីការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា និងសកម្មភាពដែលបានអនុវត្តដោយគណៈអភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ក្នុងចន្លោះអង្គប្រជុំសាមញ្ញមួយទៅអង្គប្រជុំសាមញ្ញមួយទៀតរបស់ក្រុមប្រឹក្សា ។

**មាត្រា ១៦០.-**

គណៈអភិបាលត្រូវផ្តល់យោបល់ និងរាយការណ៍ជូនក្រុមប្រឹក្សាពីការរៀបចំយុទ្ធ-សាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធានរបស់ក្រុមប្រឹក្សា ដើម្បីទទួលយក

មុខងារ ភារកិច្ច និងធនធាន ដែលនឹងត្រូវផ្ទេរទៅឱ្យក្រុមប្រឹក្សាដោយច្បាប់នេះ ឬដែលស្របតាមច្បាប់នេះ ។

**មាត្រា ១៦១.-**

គណៈអភិបាល ក្នុងនាមក្រុមប្រឹក្សា ត្រូវមានវិធានការដើម្បីធានាឱ្យមន្ត្រី អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សាបំពេញតួនាទី ភារកិច្ចរបស់ខ្លួន និងបំពេញការងារប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា ព្រមទាំងអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រកបដោយប្រសិទ្ធភាព ។

**មាត្រា ១៦២.-**

គណៈអភិបាល ត្រូវផ្តល់អនុសាសន៍ និងដាក់ជូនក្រុមប្រឹក្សា ដើម្បីពិភាក្សាសម្រេចអំពី :

-ការបង្កើត ឬរំសាយអង្គភាព

-ការរៀបចំតួនាទី ភារកិច្ច និងលក្ខខណ្ឌការងាររបស់បុគ្គលិក

-ការតែងតាំង ការដំឡើងឋានន្តរស័ក្តិ និងការបញ្ឈប់បុគ្គលិក ដោយផ្អែកតាមបទប្បញ្ញត្តិនៃការគ្រប់គ្រងបុគ្គលិករបស់ក្រុមប្រឹក្សា

-ការកំណត់លក្ខណសម្បត្តិនៃការជ្រើសរើស ការតែងតាំង ការកំណត់ប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗទៀតនៃបុគ្គលិករបស់ក្រុមប្រឹក្សា

-ការកំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុ សម្រាប់អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា

-ការកំណត់យុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សា និងបុគ្គលិករបស់ខ្លួន ។

**មាត្រា ១៦៣.-**

គណៈអភិបាល ត្រូវរៀបចំដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនដើម្បីពិនិត្យ និងអនុម័តនូវ :

-កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ និងគម្រោងថវិកាប្រចាំឆ្នាំ

-ផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំនិង ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ និង

ROYAUME DU CAMBODGE · LE MINISTRE ... PALAIS ROYAL

-របាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាដូចមានចែងក្នុងមាត្រា ៤០ នៃច្បាប់នេះ ដើម្បីផ្សព្វផ្សាយជូនប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា ១៦៤.-**

គណៈអភិបាល ត្រូវលើកសំណើទៅក្រុមប្រឹក្សា ដើម្បីកំណត់អំពីយុទ្ធសាស្ត្រ និង របៀបនៃការពិគ្រោះយោបល់លើបញ្ហាចាំបាច់ផ្សេងៗរួមទាំងផែនការអភិវឌ្ឍជាមួយ :

-ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា

-ផ្នែកផ្សេងទៀតរបស់ក្រុមប្រឹក្សាដែលអនុវត្តមុខងារ និងភារកិច្ចនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានារបស់រដ្ឋាភិបាល

-ដៃគូពាក់ព័ន្ធដទៃទៀត ។

ការពិគ្រោះយោបល់លើបញ្ហាចាំបាច់ផ្សេងៗ រួមទាំងផែនការអភិវឌ្ឍដែលត្រូវធ្វើឡើងដោយក្រុមប្រឹក្សាផ្ទាល់ ឬ ដោយគណៈអភិបាលក្នុងនាមក្រុមប្រឹក្សា ។

**មាត្រា ១៦៥.-**

គណៈអភិបាលត្រូវរាយការណ៍ជូនគ្រប់អង្គប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាជាមួយនឹងអនុសាសន៍ចាំបាច់នានា សម្រាប់លើកកម្ពស់ការអនុវត្ត :

-មុខងារជាកាតព្វកិច្ចដែលបានផ្ទេរឱ្យក្រុមប្រឹក្សា

-មុខងារជាជម្រើសរបស់ក្រុមប្រឹក្សា

-កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍរយៈពេលប្រាំ (០៥) ឆ្នាំរបស់ក្រុមប្រឹក្សា រួមទាំងសមាសភាគនៃផែនការដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ :

+ ក្រុមប្រឹក្សារួមគ្នា

+ ប្រភេទក្រុមប្រឹក្សាផ្សេងៗ

+ ក្រសួង ស្ថាប័ន ឬ មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល



+ ដៃគូពាក់ព័ន្ធនានា ។

-គម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

-ស្ថានភាពហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

-ដីការបស់ក្រុមប្រឹក្សា ។

**មាត្រា ១៦៦.-**

គណៈអភិបាល ត្រូវពិគ្រោះយោបល់ជាមួយគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដើម្បីធានាឱ្យផែនការសកម្មភាព និងថវិការបស់បណ្តាក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាលដែលផ្តល់សេវា សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធ ដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា បានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ ព្រមទាំងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ១៦៧.-**

គណៈអភិបាល ត្រូវលើកទឹកចិត្ត សម្របសម្រួល និងគាំទ្រដល់សមាជិកក្រុមប្រឹក្សា បុគ្គលិករបស់ក្រុមប្រឹក្សា ដើម្បីរាយការណ៍ជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាបន្ទាន់ នៅពេលដែលបានឃើញ ឬ ដែលបានសង្ស័យដោយមានហេតុផល ឬ ដែលមានការប្តឹងតវ៉ា ឬ ប្តឹងបរិហារ អំពីការរំលោភអំណាចដោយបុគ្គលណាម្នាក់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ។

**មាត្រា ១៦៨.-**

គណៈអភិបាល ត្រូវផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាពីការបង្កើតគណៈកម្មាធិការនានាតាមការចាំបាច់ ដើម្បីជួយដល់ក្រុមប្រឹក្សាក្នុងការអនុវត្តការងារអនុលោមតាមច្បាប់នេះ ។

**មាត្រា ១៦៩.-**

គណៈអភិបាលត្រូវធានាឱ្យមានក្តារបិទផ្សាយព័ត៌មាន និងមធ្យោបាយផ្សព្វផ្សាយ

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ព័ត៌មានផ្សេងៗទៀត តាមតម្រូវការរបស់ក្រុមប្រឹក្សារបស់ខ្លួន ។

រាល់ឯកសារទាំងអស់ដែលបានបោះពុម្ពផ្សាយស្របតាមច្បាប់នេះ ត្រូវតែបិទផ្សាយនៅលើក្តារព័ត៌មាន ឬ ត្រូវផ្សព្វផ្សាយតាមមធ្យោបាយផ្សេងៗទៀតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ។

**មាត្រា ១៧០.-**

គណៈអភិបាល ត្រូវធានាឱ្យសាធារណជនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការពិនិត្យមើលព័ត៌មាននានានៅលើក្តារបិទផ្សាយព័ត៌មាន ហើយត្រូវធានាថែរក្សាការពារសុវត្ថិភាពក្តារព័ត៌មាន ដែលមានក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ។

**មាត្រា ១៧១.-**

គណៈអភិបាល ត្រូវធ្វើការបែងចែកភារកិច្ចជាលាយល័ក្ខណ៍អក្សរនូវកិច្ចការដែលស្ថិតនៅក្នុងសិទ្ធិអំណាចរបស់ខ្លួន ។

**មាត្រា ១៧២.-**

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចលើកសំណើជូនរាជរដ្ឋាភិបាលដើម្បីកំណត់នូវតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដោយអនុក្រឹត្យ ។

## ជំពូកទី ៤
## អំពីបុគ្គលិក និងអង្គភាពរបស់ក្រុមប្រឹក្សា

### ផ្នែកទី ១
### បុគ្គលិករបស់ក្រុមប្រឹក្សា

**មាត្រា ១៧៣.-**

ក្រុមប្រឹក្សានីមួយៗ ត្រូវមានបុគ្គលិកក្រុមប្រឹក្សារបស់ខ្លួន ។

បុគ្គលិកក្រុមប្រឹក្សា គឺជាបុគ្គលិករបស់ក្រុមប្រឹក្សាដែលបានតែងតាំងដោយក្រុមប្រឹក្សា ឬ ជាបុគ្គលិកដែលបានតែងតាំងឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សា ឬ ជា

# ឧបសម្ព័ន្ធទី ២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតយន្តការច្រកចេញចូលតែមួយ សម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពសមាជិករាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

- បានឃើញអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ២៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលបំណងលើកកម្ពស់គុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាពនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការប្រមូលផ្តុំការផ្តល់សេវារដ្ឋបាលលើវិស័យនានានៅកន្លែងតែមួយ ដើម្បីបង្កលក្ខណៈងាយស្រួល និងឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីយន្តការ គោលការណ៍ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការគាំទ្រ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃទៅលើការផ្តល់សេវារដ្ឋបាលទាំងនោះ។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងក្របខ័ណ្ឌសមត្ថកិច្ចដែលទទួលបានតាមរយៈការប្រគល់ឬការធ្វើប្រតិភូកម្មពីក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល និងក្នុងក្របខ័ណ្ឌសមត្ថកិច្ចនៃអាណត្តិទូទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។



៥

## ជំពូកទី២
## យន្តការនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលរាជធានី ខេត្ត
### ផ្នែកទី១
### រចនាសម្ព័ន្ធនិងតួនាទី

**មាត្រា៤.-**

រដ្ឋបាលរាជធានី ខេត្តនីមួយៗ ត្រូវបង្កើតឱ្យមាន**អង្គភាពច្រកចេញចូលតែមួយ**សម្រាប់ផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋនៅក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា៥.-**

អង្គភាពច្រកចេញចូលតែមួយ គឺជាកន្លែងប្រមូលផ្តុំការផ្តល់សេវារដ្ឋបាលនៅកន្លែងតែមួយតាមនីតិវិធីសាមញ្ញ ប្រកបដោយគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាព។

អង្គភាពច្រកចេញចូលតែមួយ ត្រូវរៀបចំជាពីរផ្នែកគឺ ផ្នែកជួរមុខ និងផ្នែកជួរក្រោយ។

**ផ្នែកជួរមុខ** គឺជាកន្លែងសម្រាប់ប្រជាពលរដ្ឋប្រាស្រ័យទាក់ទងដោយផ្ទាល់ ដើម្បីទទួលព័ត៌មាននានាអំពីការផ្តល់សេវារដ្ឋបាល ទទួលទម្រង់បែបបទ ដាក់ពាក្យស្នើសុំ បង់ប្រាក់កម្រៃ និងទទួលលទ្ធផលសម្រេចជាផ្លូវការនៃសេវារដ្ឋបាលដែលបានស្នើសុំ។

**ផ្នែកជួរក្រោយ** គឺជាកន្លែងពិនិត្យ និងផ្តល់យោបល់ផ្នែកបច្ចេកទេសលើសំណុំបែបបទនៃការស្នើសុំសេវារដ្ឋបាល។

**មាត្រា៦.-**

អង្គភាពច្រកចេញចូលតែមួយត្រូវដឹកនាំដោយប្រធានមួយ(១)រូប និងអនុប្រធានយ៉ាងច្រើនពីរ(២)រូបជាជំនួយការ។

ប្រធានអង្គភាពច្រកចេញចូលតែមួយ មានឋានៈស្មើនាយកទីចាត់ការនៃសាលារាជធានី ខេត្ត។

អនុប្រធានអង្គភាពច្រកចេញចូលតែមួយ មានឋានៈស្មើនាយករងទីចាត់ការនៃសាលារាជធានី ខេត្ត។

ការតែងតាំងប្រធាននិងអនុប្រធានអង្គភាពច្រកចេញចូលតែមួយ ត្រូវអនុលោមលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន។

**មាត្រា៧.-**

ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

### ផ្នែកទី២
### ទីកន្លែងធ្វើការ បុគ្គលិក និងប្រភេទសេវារដ្ឋបាល

**មាត្រា៨.-**

អភិបាលរាជធានី ខេត្ត ត្រូវរៀបចំឱ្យមានទីកន្លែងបំពេញការងាររបស់អង្គភាពច្រកចេញចូលតែមួយឱ្យបានសមស្រប និងបំពាក់នូវសម្ភារៈ បរិក្ខារ ឧបករណ៍ និងមធ្យោបាយសម្រាប់គាំទ្រដល់បុគ្គលិកបំពេញការងារនៅក្នុងអង្គភាពនេះ ព្រមទាំងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការទទួលសេវារដ្ឋបាល។

**មាត្រា៩.-**

រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំចាត់តាំងបុគ្គលិកដែលមានសមត្ថភាព និងបទពិសោធការងារក្នុងចំនួនសមស្របតាមទំហំការងារ និងស្ថានភាពជាក់ស្តែងនៃរដ្ឋបាលរាជធានី ខេត្តនីមួយៗសម្រាប់បំពេញការងារនៅផ្នែកជួរមុខនៃអង្គភាពច្រកចេញចូលតែមួយ។

**មាត្រា១០.-**

អភិបាលរាជធានី ខេត្ត ត្រូវសម្របសម្រួលជាមួយប្រធានមន្ទីរ អង្គភាពជំនាញពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាលដើម្បីចាត់តាំងបុគ្គលិកជំនាញយ៉ាងតិចចំនួនមួយ(១)រូប ដែលមានសមត្ថភាព និងបទពិសោធមកបំពេញការងារពេញម៉ោងនៅផ្នែកជួរក្រោយនៃអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត។

អភិបាលរាជធានី ខេត្ត ត្រូវរាយការណ៍អំពីការចាត់តាំងបុគ្គលិកមកបំពេញការងារនៅអង្គភាពច្រកចេញចូលតែមួយនេះជូនក្រុមប្រឹក្សារបស់ខ្លួន។

បុគ្គលិកដែលត្រូវបានចាត់តាំងឱ្យមកបំពេញការងារនៅផ្នែកជួរក្រោយនៃអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវបានប្រគល់សិទ្ធិក្នុងការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសលើសេវារដ្ឋបាលតាមវិស័យជំនាញរបស់ខ្លួន លើកលែងតែប្រភេទសេវារដ្ឋបាលមួយចំនួនដែលមានលក្ខណៈបច្ចេកទេសសាំញ៉ាំ ស្មុគស្មាញ មានតម្រូវការបច្ចេកទេសច្រើន និងតម្រូវឱ្យមានការទទួលខុសត្រូវខ្ពស់។

ក្នុងករណីខាងលើនេះ អភិបាលរាជធានី ខេត្ត ត្រូវពិគ្រោះយោបល់ជាមួយប្រធានមន្ទីរ អង្គភាពជំនាញនីមួយៗ ដើម្បីកំណត់អំពីប្រភេទសេវារដ្ឋបាលមួយចំនួនដែលមានលក្ខណៈបច្ចេកទេសសាំញ៉ាំ ស្មុគស្មាញ មានតម្រូវការបច្ចេកទេសច្រើន និងតម្រូវឱ្យមានការទទួលខុសត្រូវខ្ពស់ ព្រមទាំងចាត់តាំងបុគ្គលិកជំនាញទទួលខុសត្រូវឱ្យបានច្បាស់លាស់នៅតាមមន្ទីរ អង្គភាពពាក់ព័ន្ធ ដើម្បីពិនិត្យ និងផ្តល់យោបល់បច្ចេកទេសលើប្រភេទសេវារដ្ឋបាលទាំងនេះ។

**មាត្រា១១.-**

អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវផ្តល់សេវារដ្ឋបាលតាមប្រភេទសេវារដ្ឋបាលដូចបានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធទី១ ភ្ជាប់នឹងអនុក្រឹត្យនេះ។

កម្រៃសេវា រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាល ត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងរវាងក្រសួង ស្ថាប័នពាក់ព័ន្ធនីមួយៗ ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ត្រូវបន្តផ្ទេរមុខងារក្នុងការផ្តល់សេវារដ្ឋបាលបន្ថែមទៀតទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ដើម្បីបង្កលក្ខណៈងាយស្រួល និងបង្ហិតការផ្តល់សេវារដ្ឋបាលឱ្យទៅជិតអ្នកប្រើប្រាស់សេវា។

**មាត្រា១២.-**

ក្រសួងមហាផ្ទៃដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ត្រូវផ្តល់ការណែនាំអំពីទម្រង់បែបបទ នីតិវិធី និងលក្ខខណ្ឌភ្ជាប់សម្រាប់ស្នើសុំសេវារដ្ឋបាលឱ្យមានលក្ខណៈសាមញ្ញងាយយល់និងច្បាស់លាស់។

## ជំពូកទី៣

## យន្តការនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ

## ផ្នែកទី១

## រចនាសម្ព័ន្ធនិងតួនាទី

**មាត្រា១៣._**

រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ ត្រូវបង្កើតឱ្យមានការិយាល័យច្រកចេញចូលតែមួយ ឬយន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋនៅក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន។

លក្ខណសម្បត្តិនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់បង្កើតការិយាល័យច្រកចេញចូលតែមួយ ត្រូវកំណត់ដោយសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា១៤._**

ការិយាល័យច្រកចេញចូលតែមួយ គឺជាកន្លែងប្រមូលផ្តុំការផ្តល់សេវារដ្ឋបាលនៅកន្លែងតែមួយ តាមនីតិវិធីសាមញ្ញ ប្រកបដោយគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាព។

ការិយាល័យច្រកចេញចូលតែមួយ ត្រូវរៀបចំជាពីរផ្នែកគឺ ផ្នែកជួរមុខ និងផ្នែកជួរក្រោយ។

**ផ្នែកជួរមុខ** គឺជាកន្លែងសម្រាប់ប្រជាពលរដ្ឋប្រាស្រ័យទាក់ទងដោយផ្ទាល់ ដើម្បីទទួលព័ត៌មាននានាអំពីការផ្តល់សេវារដ្ឋបាល ទទួលទម្រង់បែបបទ ដាក់ពាក្យស្នើសុំ បង់ប្រាក់កម្រៃ និងទទួលលទ្ធផលសម្រេចជាផ្លូវការនៃសេវារដ្ឋបាលដែលបានស្នើសុំ។

**ផ្នែកជួរក្រោយ** គឺជាផ្នែកដែលទ្រទ្រង់ដ៏សំខាន់លើការងារបច្ចេកទេស។ ផ្នែកជួរក្រោយមានតួនាទីពិនិត្យ និងផ្តល់យោបល់ផ្នែកបច្ចេកទេសលើការផ្តល់សេវារដ្ឋបាលតាមវិស័យជំនាញ។

**មាត្រា១៥._**

ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមប្រកាសលេខ ៩២៨ប្រក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៩ របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យច្រកចេញចូលតែមួយនៅក្រុង ស្រុក ខណ្ឌគោលដៅ។

បែបបទនិងនីតិវិធីនៃការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ផ្នែកទី២

## ទីកន្លែងធ្វើការ បុគ្គលិក និងប្រភេទសេវារដ្ឋបាល

**មាត្រា១៦._**

អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំឱ្យមានទីកន្លែងបំពេញការងាររបស់ការិយាល័យច្រកចេញចូលតែមួយឱ្យបានសមស្រប និងបំពាក់នូវសម្ភារៈ បរិក្ខារ ឧបករណ៍ និងមធ្យោបាយសម្រាប់គាំទ្រដល់

បុគ្គលិកបំពេញការងារនៅក្នុងការិយាល័យនេះ ព្រមទាំងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការទទួលសេវារដ្ឋបាល។

**មាត្រា១៧._**

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់តាំងបុគ្គលិកមានសមត្ថភាព និងបទពិសោធការងារក្នុងចំនួនសមស្របតាមទំហំការងារ និងតាមស្ថានភាពជាក់ស្តែងនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗឱ្យមកបំពេញការងារនៅផ្នែកជួរមុខនៃការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធនានា ត្រូវចាត់តាំងបុគ្គលិកជំនាញមានសមត្ថភាព និងបទពិសោធការងារឱ្យមកបំពេញការងារជាផ្នែកជួរក្រោយនៅក្នុងការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវរាយការណ៍អំពីការចាត់តាំងបុគ្គលិកមកបំពេញការងារនៅការិយាល័យច្រកចេញចូលតែមួយនេះជូនក្រុមប្រឹក្សារបស់ខ្លួន។

ក្នុងករណីដែលក្រសួង ស្ថាប័ន មន្ទីរ អង្គភាពណាមួយពុំទាន់មានបុគ្គលិកជំនាញសម្រាប់ចាត់តាំងឱ្យមកបំពេញការងារនៅផ្នែកជួរក្រោយ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់តាំងបុគ្គលិករដ្ឋបាលរបស់ខ្លួនឱ្យមកបំពេញការងារជាបុគ្គលិកផ្នែកជួរក្រោយទទួលរ៉ាប់រងក្នុងនាមជាភ្នាក់ងារតំណាងឱ្យវិស័យជំនាញនោះ។ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញ ត្រូវផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកដែលត្រូវបានចាត់តាំងនោះ។

បុគ្គលិកដែលបំពេញការងារនៅក្នុងការិយាល័យច្រកចេញចូលតែមួយ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់អភិបាលក្រុង ស្រុក ខណ្ឌ។ ក្របខ័ណ្ឌ និងបៀវត្សរបស់បុគ្គលិកមកពីក្រសួង ស្ថាប័នពាក់ព័ន្ធនានាដែលបំពេញការងារនៅការិយាល័យច្រកចេញចូលតែមួយ ត្រូវស្ថិតនៅក្នុងក្រសួង ស្ថាប័នសាមីដោយទទួលបានការដំឡើងថ្នាក់ ឋានន្តរស័ក្តិ គ្រឿងឥស្សរិយយស ការលើកទឹកចិត្ត និងអត្ថប្រយោជន៍នានាតាមនីតិវិធីជាធរមាន។

**មាត្រា១៨._**

ការិយាល័យច្រកចេញចូលតែមួយ និងយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវផ្តល់សេវារដ្ឋបាលដូចបានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធទី២ ភ្ជាប់នឹងអនុក្រឹត្យនេះ។

កម្រៃសេវា រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាល ត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ត្រូវបន្តផ្ទេរមុខងារក្នុងការផ្តល់សេវារដ្ឋបាលបន្ថែមទៀតទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីបង្កលក្ខណៈងាយស្រួល និងបង្កើតការផ្តល់សេវារដ្ឋបាលឱ្យទៅជិតអ្នកប្រើប្រាស់សេវា។

មាត្រា១៩.-

ក្រសួងមហាផ្ទៃ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ត្រូវផ្តល់ការណែនាំអំពីទម្រង់បែបបទ នីតិវិធី និងលក្ខខណ្ឌភ្ជាប់សម្រាប់ស្នើសុំសេវារដ្ឋបាលឱ្យមានលក្ខណៈសាមញ្ញ ងាយយល់ និងច្បាស់លាស់។

## ជំពូកទី៤

## យន្តការនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលឃុំ សង្កាត់

មាត្រា២០.-

រដ្ឋបាលឃុំ សង្កាត់ត្រូវរៀបចំឱ្យមានយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋនៅក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន។

យន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ ត្រូវស្ថិតនៅក្រោមការដឹកនាំរបស់មេឃុំ ចៅសង្កាត់ក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានស្មៀនឃុំ សង្កាត់ជាសេនាធិការ។

មេឃុំ ចៅសង្កាត់ អាចប្រគល់សិទ្ធិក្នុងការពិនិត្យ ការសម្រេច និងការចុះហត្ថលេខាលើលិខិតអនុញ្ញាតឬលិខិតបញ្ជាក់ចាំបាច់មួយចំនួនជូនជំទប់ ចៅសង្កាត់រងរបស់ខ្លួនស្របតាមមាត្រា៤០នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

មាត្រា២១.-

មេឃុំ ចៅសង្កាត់ ត្រូវចាត់តាំងស្មៀន ឬបុគ្គលិកជំនួយការរដ្ឋបាលឱ្យបំពេញភារកិច្ចជាបុគ្គលិកផ្តល់ព័ត៌មាន ទទួលប្រគល់ឯកសារ ទទួលកម្រៃសេវារដ្ឋបាល និងពិនិត្យផ្តល់យោបល់លើសំណើសុំសេវារដ្ឋបាលដើម្បីដាក់ជូនមេឃុំ ចៅសង្កាត់ពិនិត្យ និងសម្រេច។

ការចាត់តាំងឬការប្រគល់ភារកិច្ចជូនបុគ្គលិកផ្តល់ព័ត៌មាន ទទួលប្រគល់ឯកសារ និងទទួលកម្រៃសេវារដ្ឋបាល ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់រដ្ឋបាលឃុំ សង្កាត់។

មេឃុំ ចៅសង្កាត់ ត្រូវរៀបចំឱ្យមានទីកន្លែងសម្រាប់ការផ្តល់សេវារដ្ឋបាលឱ្យបានសមស្រប និងបំពាក់នូវសម្ភារៈ បរិក្ខារ ឧបករណ៍ និងមធ្យោបាយសម្រាប់គាំទ្រដល់ការផ្តល់សេវារដ្ឋបាល ព្រមទាំងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការទទួលសេវារដ្ឋបាល។

មាត្រា២២.-

យន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ ត្រូវផ្តល់សេវារដ្ឋបាលទៅតាមប្រភេទសេវា កម្រៃសេវា រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាល ដូចបានកំណត់នៅក្នុងប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

មាត្រា២៣.-

ក្រសួងមហាផ្ទៃត្រូវផ្តល់ការណែនាំអំពីទម្រង់បែបបទ នីតិវិធី និងលក្ខខណ្ឌភ្ជាប់សម្រាប់ស្នើសុំសេវារដ្ឋបាលឱ្យមានលក្ខណៈសាមញ្ញ ងាយយល់ និងច្បាស់លាស់។



៥

## ជំពូកទី៥
## ការគ្រប់គ្រងនិងការចាត់ចែងចំណូលសេវារដ្ឋបាល

**មាត្រា២៤._**

រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិទទួលបានចំណូលពីកម្រៃសេវារដ្ឋបាល។

ចំណូលដែលទទួលបានពីកម្រៃនៃការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់នីមួយៗ ត្រូវបង់ចូលថវិកាថ្នាក់ជាតិ និង/ឬថវិកាថ្នាក់ក្រោមជាតិតាមគោលការណ៍កំណត់។

ការគ្រប់គ្រងចំណូល ចំណាយ ការកត់ត្រា និងការបែងចែកប្រាក់រង្វាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តតាមច្បាប់ លិខិតបទដ្ឋាន គោលការណ៍ និងនីតិវិធីនានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា២៥._**

ការបែងចែកចំណូលដែលប្រមូលបានពីការផ្តល់សេវារដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ឧបត្ថម្ភដល់បុគ្គលិក និងសម្រាប់ពង្រឹងយន្តការផ្តល់សេវារដ្ឋបាល ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន លើកលែងតែមានការកំណត់ផ្សេងពីនេះ។

## ជំពូកទី៦
## ការគាំទ្រ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ

**មាត្រា២៦._**

គ.ជ.អ.ប មានតួនាទីក្នុងការសម្របសម្រួលជាមួយក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធនានាក្នុងការគាំទ្រផ្នែកគោលនយោបាយ ការកៀរគរធនធាន និងការគាំទ្របច្ចេកទេសពីអ្នកពាក់ព័ន្ធនានាក្នុងដំណើរការនៃការផ្ទេរមុខងារ និងដំណើរការអនុវត្តការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

គ.ជ.អ.ប អាចប្រើប្រាស់យន្តការដែលមានស្រាប់ដូចជា ក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួងដើម្បីសម្របសម្រួលក្នុងដំណើរការនៃការផ្ទេរមុខងារ និងដំណើរការអនុវត្តការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា២៧._**

ក្រសួងមហាផ្ទៃមានតួនាទីសម្របសម្រួលក្នុងការបង្កើតអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ព្រមទាំងគាំទ្រផ្នែកបច្ចេកទេសដល់ដំណើរការផ្តល់សេវារដ្ឋបាល ការអភិវឌ្ឍសមត្ថភាព ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តការផ្តល់សេវារដ្ឋបាលដោយសហការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា។



25

ក្រសួងមហាផ្ទៃ ត្រូវសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងរដ្ឋបាលរាជធានី ខេត្ត ដើម្បីគាំទ្រដល់ការរៀបចំទីកន្លែងផ្តល់សេវា និងបំពាក់សម្ភារៈ បរិក្ខារ ឧបករណ៍ និងមធ្យោបាយដល់អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត និងការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ក្រសួងមហាផ្ទៃ អាចប្រើប្រាស់ប្រព័ន្ធគ្រប់គ្រង ឬយន្តការដែលមានស្រាប់ដើម្បីធានាលើការគ្រប់គ្រង ការគាំទ្រ ការសម្របសម្រួល និងការអនុវត្តកិច្ចការនេះ។

**មាត្រា២៨.–**

ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ត្រូវសម្របសម្រួល និងជំរុញមន្ទីរ អង្គភាពជំនាញរបស់ខ្លួនក្នុងការចាត់តាំងបុគ្គលិកដែលមានសមត្ថភាព និងបទពិសោធការងារឱ្យមកបំពេញការងារជាបុគ្គលិកផ្នែកជួរក្រោយនៅក្នុងអង្គភាពច្រកចេញចូលតែមួយ ការិយាល័យច្រកចេញចូលតែមួយ និងយន្តការច្រកចេញចូលតែមួយ ព្រមទាំងផ្តល់ការគាំទ្រលើការអភិវឌ្ឍសមត្ថភាព ការគាំទ្រផ្នែកបច្ចេកទេស ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការផ្តល់សេវារដ្ឋបាលដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា២៩.–**

រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវធានាឱ្យមានការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃជាប្រចាំ ព្រមទាំងទទួលដោះស្រាយនូវរាល់ភាពមិនប្រក្រតីក្នុងការផ្តល់សេវារដ្ឋបាលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

## ជំពូកទី៧

## អន្តរប្បញ្ញត្តិ

**មាត្រា៣០.–**

រដ្ឋបាលរាជធានី ខេត្ត ត្រូវបង្កើតអង្គភាពច្រកចេញចូលតែមួយឱ្យបានយ៉ាងយូរត្រឹមដំណាច់ឆមាសទី១នៃឆ្នាំ២០១៧។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានលក្ខណសម្បត្តិស្របតាមការកំណត់របស់ក្រសួងមហាផ្ទៃ ត្រូវបង្កើតការិយាល័យច្រកចេញចូលតែមួយឱ្យបានយ៉ាងយូរត្រឹមដំណាច់ឆ្នាំ២០១៧។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលពុំទាន់មានលក្ខណសម្បត្តិសមស្របសម្រាប់បង្កើតការិយាល័យច្រកចេញចូលតែមួយ និងរដ្ឋបាលឃុំ សង្កាត់ ត្រូវបង្កើតយន្តការច្រកចេញចូលតែមួយឱ្យបានយ៉ាងយូរត្រឹមដំណាច់ឆ្នាំ២០១៧។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

**មាត្រា៣១.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## តារាងឧបសម្ព័ន្ធទី១

## សេវារដ្ឋបាលនៃរដ្ឋបាលរាជធានី ខេត្ត

## ភ្ជាប់នឹងអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ២០១៧

## ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

| ល.រ | បរិយាយ |
|---|---|
| **១. ការងារនីត្យានុកូលកម្ម (ការបញ្ជាក់លើឯកសារថតចម្លង)** | |
| ១ | សេចក្តីអនុញ្ញាតឱ្យប្រកបអាជីវកម្ម អាហារ៉ែ នីហារ៉ែ សណ្ឋាគារ វិនិយោគទុនបរទេស |
| ២ | លក្ខន្តិកៈក្រុមហ៊ុនអាជីវកម្មនានា វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុន លិខិតក្រសួងពាណិជ្ជកម្ម កិច្ចសន្យា |
| ៣ | ប្លង់សាងសង់ |
| ៤ | វិញ្ញាបនបត្រសម្គាល់ម្ចាស់កម្មសិទ្ធិអចលនវត្ថុ |
| ៥ | សញ្ញាបត្រក្រោយឧត្តមសិក្សា(ក្នុងប្រទេស) |
| ៦ | សញ្ញាបត្រពុទ្ធិកសិក្សា |
| ៧ | លិខិតអនុញ្ញាតចុះបញ្ជីសមាគម អង្គការ ព្រះវិហារសាសនា និងសហគមន៍ |
| ៨ | លិខិត ឬឯកសារផ្សេងៗទៀត(ដែលមិនមែនជាសមត្ថកិច្ចរបស់ស្ថាប័នណាមួយ) |
| **២. ការងាររដ្ឋបាល** | |
| ១ | ការអនុញ្ញាតឱ្យដឹកឆ្លងផ្លូវ ឬតាមបណ្តោយផ្លូវក្នុងរាជធានី ខេត្ត |
| ២ | លិខិត/ប័ណ្ណឆ្លងព្រំដែន(laissez-passer) |
| ៣ | លិខិតអនុញ្ញាតទីតាំងប៉ាណូអចល័ត |
| ៤ | ការចេញលិខិតអនុញ្ញាតបំពេញអាចម៍ដីកម្មសិទ្ធិឯកជនចាប់ពី ១០០០ម៉ែត្រការ៉េឡើងទៅ |
| ៥ | ការចុះបញ្ជីវិនិយោគជាគម្រោងមានលក្ខណសម្បត្តិគ្រប់គ្រាន់នៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត(ទុនវិនិយោគក្រោម២លានដុល្លារអាមេរិក) |
| **៣. វិស័យសុខាភិបាល** | |
| ១ | ការផ្តល់លិខិតអនុញ្ញាតដល់ឱសថស្ថានចំពោះ ការបើកថ្មី ការប្តូរទីតាំង ការប្តូរឈ្មោះឱសថការី និងការបន្តសុពលភាព |
| ២ | ការផ្តល់លិខិតអនុញ្ញាតដល់អគារឱសថបូរាណចំពោះ ការបើកថ្មី ការប្តូរទីតាំង ការប្តូរឈ្មោះគ្រូឱសថបូរាណ និងការបន្តសុពលភាព |
| ៣ | ការផ្តល់វិញ្ញាបនបត្របញ្ជាក់អនាម័យចំណីអាហារតាមភោជនីយដ្ឋាន និងអាហារដ្ឋានដែលមានចំណុះចាប់ពី៥១កៅអីឡើង(មិនមែនអាហារដ្ឋាននិងភោជនីយដ្ឋានប្រណីត) |
| **៤. វិស័យទេសចរណ៍** | |
| ១ | **អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍** |
| | - សណ្ឋាគារ ឬសណ្ឋាគារអាផាតមិន ឬសណ្ឋាគារស្វីត ឬសណ្ឋាគាររីសត ឬប៊ីងហ្គាឡូ ឬម៉ូតែល ឬឡូដ៍(Lodge) ចំណុះត្រឹម២០បន្ទប់ |



85

| ល.រ | បរិយាយ |
|---|---|
| | - ផ្ទះភ្ញៀវត្រូវបង់ថ្លៃអាជ្ញាប័ណ្ណទេសចរណ៍ |
| | - អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់ភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍ចំណុះពី៥១ ដល់១០០នាក់ |
| | - អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់បៀហ្គាឌិន |
| | - អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់ខារ៉ាអូខេចាប់ពី៦បន្ទប់ឡើងទៅ |
| | - អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់ម៉ាស្សាសុខភាពចំណុះពី០៦ ដល់១០គ្រែ ឬកៅអី |
| | - អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់ស្ប៉ា |
| | - អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់វង្គសាលឌីស្កូតែក ឬវង្គសាល-ឌីស្កូតែក |
| | - អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់ដឹកជញ្ជូនភ្ញៀវទេសចរណ៍តាមផ្លូវទឹក(មិនមែនជាលក្ខណៈក្រុមហ៊ុន) |
| | - អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់ដឹកជញ្ជូនភ្ញៀវទេសចរណ៍តាមផ្លូវគោកចាប់ពី៦កៅអីឡើងទៅ |
| ២ | **អាជ្ញាប័ណ្ណទេសចរណ៍សម្រាប់កីឡាទេសចរណ៍** |
| | - កីឡាស្គកយ័រចាប់ពី៦តុឡើងទៅ |
| | - ម៉ាស៊ីនហ្គេម |
| | - កីឡាសៀក |
| | - កីឡាជិះកង់វង្វង់ |
| | - កីឡាជិះដំរី |
| | - កីឡាជិះសេះ |
| | - រថយន្ត ឬរថភ្លើងអគ្គិសនី |
| **៥. វិស័យសាធារណការ និងដឹកជញ្ជូន** | |
| | **ក. ផ្នែកដឹកជញ្ជូនផ្លូវគោក** |
| ១ | **ការប្រឡងយកប័ណ្ណបើកបរយានយន្ត និងប្តូរ ពន្យារ ទុតិយតា តតិយតា(លើកលែងជនបរទេស)** |
| | - ប្រឡងយកប័ណ្ណបើកបរទោចក្រយានយន្តប្រភេទ **ក** |
| | - ប្រឡងយកប័ណ្ណបើកបរឡើងវិញ ទោចក្រយានយន្តប្រភេទ **ក** |
| | - ប្តូរ ពន្យារ ទុតិយតា ឬតតិយតាប័ណ្ណបើកបរទោចក្រយានយន្តប្រភេទ **ក** |
| | - ប្រឡងយកប័ណ្ណបើកបររថយន្តប្រភេទ **ខ** |
| | - ប្រឡងយកប័ណ្ណបើកបរឡើងវិញ រថយន្តប្រភេទ **ខ** |
| | - ប្តូរ ពន្យារ ទុតិយតា ឬតតិយតាប័ណ្ណបើកបររថយន្ត |
| ២ | **ការចុះបញ្ជីយានយន្ត** |
| | - ផ្ទេរកម្មសិទ្ធិទោចក្រយានយន្ត ឬត្រីចក្រយានយន្តក្នុងរាជធានី-ខេត្ត |
| | - ផ្ទេរកម្មសិទ្ធិទោចក្រយានយន្ត ឬត្រីចក្រយានយន្តឆ្លងរាជធានី-ខេត្ត |
| | - ផ្ទេរកម្មសិទ្ធិម៉ែក(ទោចក្រយានយន្ត) ក្នុងរាជធានី-ខេត្ត |
| | - ផ្ទេរកម្មសិទ្ធិម៉ែក(ទោចក្រយានយន្ត) ឆ្លងរាជធានី-ខេត្ត |
| | - ចុះបញ្ជីរថយន្តធុនតូច |
| | - ចុះបញ្ជីរថយន្តធុនធំ |
| | - ចុះបញ្ជីម៉ែក ឬសីមីម៉ែករថយន្ត |



៥

| ល.រ | បរិយាយ |
|---|---|
| | - ផ្ទេរកម្មសិទ្ធិរថយន្តធុនតូចក្នុងរាជធានី-ខេត្ត |
| | - ផ្ទេរកម្មសិទ្ធិរថយន្តធុនតូចឆ្លងរាជធានី-ខេត្ត |
| | - ផ្ទេរកម្មសិទ្ធិរថយន្តធុនធំក្នុងរាជធានី-ខេត្ត |
| | - ផ្ទេរកម្មសិទ្ធិរថយន្តធុនធំឆ្លងរាជធានី-ខេត្ត |
| | - ផ្ទេរកម្មសិទ្ធិរ៉ឺម៉ក ឬសឺមីរ៉ឺម៉ករថយន្តក្នុងរាជធានី-ខេត្ត |
| | - ផ្ទេរកម្មសិទ្ធិរ៉ឺម៉ក ឬសឺមីរ៉ឺម៉ករថយន្តឆ្លងរាជធានី-ខេត្ត |
| | - ប្តូរ ទុតិយតា ឬតតិយតាប័ណ្ណរថយន្តធុនតូច |
| | - ប្តូរ ទុតិយតា ឬតតិយតាប័ណ្ណរថយន្តធុនធំ រ៉ឺម៉ក ឬសឺមីរ៉ឺម៉ក |
| | - ប្តូរ ទុតិយតា ឬតតិយតាផ្លាកលេខរថយន្តធុនតូច( ផ្លាកម្ខាង ) |
| | - ប្តូរ ទុតិយតា ឬតតិយតាផ្លាកលេខរថយន្តធុនតូច( ផ្លាក ១គូ ) |
| | - ប្តូរ ទុតិយតា ឬតតិយតាផ្លាកលេខរថយន្តធុនធំ រ៉ឺម៉ក ឬសឺមីរ៉ឺម៉ក( ផ្លាកម្ខាង ) |
| | - ប្តូរ ទុតិយតា ឬតតិយតាផ្លាកលេខរថយន្តធុនធំ( ផ្លាក ១គូ ) |
| ៣ | **ការចុះបញ្ជី និងលិខិតអនុញ្ញាតធ្វើអាជីវកម្មសាលា និងសាខាសាលាបង្រៀនបើកបរយានយន្ត** |
| | - ផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មសាខាសាលាបង្រៀនបើកបរ |
| ៤ | **ការផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មយានយន្ត** |
| ៤.១ | **ការផ្តល់លិខិតអនុញ្ញាតយានយន្តធ្វើអាជីវកម្មក្នុងប្រទេស** |
| | - រថយន្តដឹកទំនិញមានចំណុះផ្ទុកមិនលើសពី៥តោន |
| | - រថយន្តដឹកទំនិញមានចំណុះផ្ទុកលើសពី៥តោន ដល់១០តោន |
| | - រថយន្តដឹកទំនិញមានចំណុះផ្ទុកលើសពី១០តោន |
| | - រថយន្តដឹកអ្នកដំណើរមានចំណុះផ្ទុកមិនលើសពី៩នាក់ |
| | - រថយន្តដឹកអ្នកដំណើរមានចំណុះផ្ទុកចាប់ពី១០នាក់ ដល់២០នាក់ |
| | - រថយន្តដឹកអ្នកដំណើរមានចំណុះផ្ទុកលើសពី២០នាក់ |
| ៤.២ | **ការចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតក្រុមហ៊ុនដឹកជញ្ជូនក្នុងប្រទេស** |
| | - ផ្តល់លិខិតអនុញ្ញាតបើកស្នាក់ការ ឬសាខាក្រុមហ៊ុនដឹកជញ្ជូន |
| ៥ | **ការចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មយានដ្ឋានជួសជុលកែច្នៃ ដំឡើងយានយន្ត** |
| | - ចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មយានដ្ឋានក្នុងរាជធានី ខេត្ត |
| | **ខ. សេវាសាធារណៈលើវិស័យដឹកជញ្ជូនផ្លូវទឹក** |
| ៦ | **ការផ្តល់ប័ណ្ណសម្គាល់ជលយាន** |
| ៦.១ | **ជលយានដែលមានចំណុះផ្ទុក២០តោនចុះក្រោម កំលាំងម៉ាស៊ីន៤០សេះចុះក្រោម និង២៥កៅអីចុះក្រោម** |
| | - ផ្តល់ប័ណ្ណសម្គាល់ជលយាន( បញ្ជាក់អ៊ីវ/ប្លង់/ពន្ធនាំចូលជលយាន ជាបន្ទុករបស់ម្ចាស់ជលយាន ) |
| | - ប្តូរម៉ាស៊ីន ពណ៌ កែមាឌ ឬផ្ទេរម្ចាស់កម្មសិទ្ធិជលយាន( បញ្ជាក់អ៊ីវ/ប្លង់កែមាឌ/ប្រថាប់ត្រា ជាបន្ទុករបស់ម្ចាស់ជលយាន ) |
| | - ប្តូរ( ប្តូរឈ្មោះជលយាន ) ទុតិយតា ឬតតិយតាប័ណ្ណសម្គាល់ជលយាន |
| ៦.២ | **ជលយានដែលមានចំណុះផ្ទុកលើសពី២០តោន ដល់៤០តោន កំលាំងម៉ាស៊ីនលើសពី៤០សេះ ដល់៩០** |



25

| ល.រ | បរិយាយ |
|---|---|
| | **សេះ និងលើសពី២៥កៅអី ដល់៥០កៅអី** |
| | - ផ្តល់ប័ណ្ណសម្គាល់ជលយាន(បញ្ជាក់អ៊ីវ/ប្លង់/ពន្ធនាំចូលជលយាន ជាបន្ទុករបស់ម្ចាស់ជលយាន) |
| | - ប្តូរម៉ាស៊ីន ពណ៌ កែមាឌ ឬផ្ទេរម្ចាស់កម្មសិទ្ធិជលយាន(បញ្ជាក់អ៊ីវ/ប្លង់កែមាឌ/ប្រថាប់ត្រា ជាបន្ទុករបស់ម្ចាស់ជលយាន) |
| | - ប្តូរ(ប្តូរឈ្មោះជលយាន) ទុតិយតា ឬ តតិយតាប័ណ្ណសម្គាល់ជលយាន |
| ៧ | **ត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន** |
| ៧.១ | **ជលយានដែលមានចំណុះផ្ទុក២០តោនចុះក្រោម កម្លាំងម៉ាស៊ីន៤០សេះចុះក្រោម និង២៥កៅអីចុះក្រោម** |
| | - ជលយានក្នុងស្រុក |
| | - ជលយានដចម្លង |
| ៧.២ | **ជលយានដែលមានចំណុះផ្ទុកលើសពី ២០តោន ដល់៤០តោន កំលាំងម៉ាស៊ីនលើសពី៤០សេះ ដល់៩០សេះ និងលើសពី២៥កៅអី ដល់៥០កៅអី** |
| | - ជលយានក្នុងស្រុក |
| | - ជលយានដចម្លង |
| ៨ | **លិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវទឹក** |
| | - នាវាដឹកទំនិញ |
| | - សាឡង់ដឹកទំនិញ(គ្មានម៉ាស៊ីន) |
| | - នាវាដឹកអ្នកដំណើរ |
| | - ដចម្លង |
| | - នាវាសណ្តោង/រុញ |
| **៦. វិស័យវប្បធម៌ និងវិចិត្រសិល្បៈ** | |
| ១ | ការចេញលិខិតអនុញ្ញាតការប្រគំតន្ត្រីតាមទីសាធារណៈលក្ខណៈអន្តរជាតិ |
| ២ | ការផ្តល់ប័ណ្ណអនុញ្ញាតបើកអាជីវកម្មបណ្ណាគារដែលមានផ្ទៃក្រឡាចាប់ពី៥០ម៉ែត្រការ៉េឡើងទៅ |
| **៧. វិស័យព័ត៌មាន** | |
| ១ | **ការផ្តល់លិខិតអនុញ្ញាតចំពោះការស្នើសុំប្រកបអាជីវកម្ម និងបន្តសុពលភាព៖** |
| | - បោះពុម្ពដោយដៃ(អូសស្បៃ) បោះពុម្ពលើអាវយឺត |
| | - តូបលក់កាសែត តូបលក់សៀវភៅ ផលិតផលបោះពុម្ព និងផលិតផលសោតទស្សន៍ |
| | - សេវាជួសជុលម៉ាស៊ីនថត ម៉ាស៊ីនថតចំលង សេវាជួសជុលកុំព្យូទ័រ វាយកុំព្យូទ័រ សេវាជួសជុលវិទ្យុ ទូរទស្សន៍ ម៉ាញេ រ៉ូណេអូ អំភ្លី មេក្រូ |
| | - អគារលក់ឧបករណ៍សោតទស្សន៍ |
| | - Internet Café |
| **៨. វិស័យបរិស្ថាន** | |
| ១ | ផ្តល់លិខិតអនុញ្ញាតបញ្ចេញសំណល់រាវចេញពីទីតាំងអាជីវកម្ម ចំណុះតិចជាង៥០ម៉ែត្រគូប/ថ្ងៃ(តម្រូវឱ្យស្នើសុំ) |
| ២ | ផ្តល់លិខិតអនុញ្ញាតបញ្ចេញសំណល់រឹងចេញពីទីតាំងអាជីវកម្ម(តម្រូវឱ្យស្នើសុំ) |

| ល.រ | បរិយាយ |
| --- | --- |
| **៩. វិស័យឧស្សាហកម្ម និងសិប្បកម្ម** | |
| ១ | ការចុះបញ្ជីសហគ្រាស និងសិប្បកម្មដែលមានដើមទុនក្រោម២០០លានរៀល(៥០ ០០០ដុល្លារ) ដែលគ្មានហានិភ័យ |
| ២ | ការចេញវិញ្ញាបនបត្រដំណើរការសិប្បកម្ម(ថ្មី ឬបន្ត) ដែលមានដើមទុនក្រោម២០០លានរៀល (៥០ ០០០ដុល្លារ) |
| ៣ | ការចេញលិខិតអនុញ្ញាតពង្រីកសិប្បកម្ម ឬប្តូរទីតាំង ឬប្តូរម្ចាស់ ឬប្តូរឈ្មោះ ឬទុតិយតាដែលមានដើមទុនក្រោម២០០លានរៀល(៥០ ០០០ដុល្លារ) |
| ៤ | ការត្រួតពិនិត្យផ្ទៀងផ្ទាត់ប្រភេទឧបករណ៍មាត្រាសាស្ត្រដែលត្រូវបានប្រើសម្រាប់ការធ្វើអាជីវកម្ម(គិត១ឯកតានៃឧបករណ៍) |
| ៤.១ | **ផ្នែកទម្ងន់** |
| | **ជញ្ជីងមិនស្វ័យប្រវត្តិ** |
| | - ទម្ងន់តិចជាង ឬស្មើ១០គីឡូក្រាម(សម្រាប់ជញ្ជីងដាក់តាំងលក់) |
| | - ទម្ងន់លើសពី១០គីឡូក្រាម ដល់១០០គីឡូក្រាម(សម្រាប់ជញ្ជីងដាក់តាំងលក់) |
| | - ទម្ងន់លើសពី១០០គីឡូក្រាម ដល់១ ០០០គីឡូក្រាម |
| ៤.២ | **ឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ និងហ្គាស)** |
| | - ដៃបាញ់ប្រេងចំនួន១(តាមស្ថានីយ) |
| | - ធុងហ្គាស(អប្បបរមារ ៧គីឡូក្រាម) |
| | - ធុងហ្គាស(១៥ គីឡូក្រាម) |
| | - ធុងហ្គាស(លើសពី១៥ គីឡូក្រាម) |
| | - ដៃវៃបូមប្រេងចំនួន១ |
| ៥ | **ត្រួតពិនិត្យផ្ទៀងផ្ទាត់បរិមាណ និងផ្លាកសញ្ញាមាត្រាសាស្ត្រលើទំនិញផលិត និងទំនិញវេចខ្ចប់** |
| ៥.១ | **ទំនិញផលិត** |
| | **+ វាយនភ័ណ្ឌ(មួយមុខផលិតផល)** |
| | - សំលៀកបំពាក់ |
| | - កំរាលព្រំ |
| | សម្ភារៈសំណង់(មួយមុខផលិតផល) |
| | បរិក្ខារអគ្គិសនី អេឡិកត្រូនិច និងអុបទិក(មួយមុខផលិតផល) |
| ៥.២ | **ទំនិញវេចខ្ចប់** |
| | **+ ជាឧស្ម័ន ផលិតផលចំណីអាហារ និងវត្ថុរាវគ្រប់ប្រភេទ(មួយមុខផលិតផល)** |
| | - តិចជាង ឬស្មើ ៥គីឡូក្រាម ឬលីត្រ |
| | - លើសពី៥គីឡូក្រាម ឬលីត្រ ដល់១០គីឡូក្រាម ឬលីត្រ |
| | - លើសពី១០គីឡូក្រាម ឬលីត្រ ដល់២០គីឡូក្រាម ឬលីត្រ |
| | - លើសពី២០គីឡូក្រាម ឬលីត្រ ដល់៣០គីឡូក្រាម ឬលីត្រ |
| | - លើសពី៣០គីឡូក្រាម ឬលីត្រ ដល់៥០គីឡូក្រាម ឬលីត្រ |

| ល.រ | បរិយាយ |
|---|---|
| | - លើសពី៥០គីឡូក្រាម ឬលីត្រ |
| | - សំណើមក្នុងគ្រាប់ធញ្ញជាតិ |
| | - ភាពក្លីលើគ្រាប់ធញ្ញជាតិ |
| | **+ ផលិតផលថ្នាំជក់ និងក្រដាស(មួយមុខផលិតផល)** |
| | **+ ផលិតផលគីមី** |
| | - សាប៊ូដុំ ម្សៅសាប៊ូ គ្រឿងសំអាត ប៉ូលាគ្រឿងក្រអូប ឬគ្រឿងសំអាង |
| | - ថ្នាំសម្លាប់សត្វល្អិត ឬជីគីមីកសិកម្ម |
| | - ថ្នាំលាបពណ៌ វ៉ែរនី ថ្នាំទ្រនាប់ ទឹកថ្នាំបោះពុម្ព ឬម៉ាស្ទិក |
| **១០. វិស័យរ៉ែ និងថាមពល** | |
| ១ | **ការផ្តល់អាជ្ញាប័ណ្ណធនធានរ៉ែ** |
| | - សេវាពិនិត្យ រៀបចំ និងដំណើរការឯកសារសម្រាប់ការផ្តល់អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ និងអាជីវកម្មធនធានរ៉ែខ្នាតតូច(ការដាក់ពាក្យស្នើសុំ និងដំណើរការឯកសារ) ស្របតាមការកំណត់របស់ក្រសួងរ៉ែ និងថាមពល |
| | - សេវាពិនិត្យ រៀបចំ និងដំណើរការឯកសារសម្រាប់ការផ្តល់លិខិតអនុញ្ញាតលើសកម្មភាពធ្វើអាជីវកម្មជីកយកអាចម៍ដីសម្រាប់ប្រើប្រាស់ក្នុងមូលដ្ឋានដែលមានទំហំផ្ទៃក្រឡាមិនលើសពី៣០០ម៉ែត្រក្រឡា និងជម្រៅមិនលើសពី៣ម៉ែត្រ |
| ២ | **ការចុះបញ្ជីអាជ្ញាប័ណ្ណ** |
| | - អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ និងអាជីវកម្មធនធានរ៉ែខ្នាតតូច |
| ៣ | **ការពិន័យអន្តរការណ៍ជាប្រាក់** |
| | ករណីដំណើរការដោយអាជ្ញាប័ណ្ណធនធានរ៉ែផុតសុពលភាពចំពោះ៖<br>- អាជ្ញាប័ណ្ណសិប្បកម្ម<br>- អាជ្ញាប័ណ្ណអាជីវកម្មធនធានរ៉ែខ្នាតតូច |
| **១១. វិស័យពាណិជ្ជកម្ម** | |
| ១ | ការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មលោហៈជាតុត្បូងថ្មមានតម្លៃជាងគ្រឿងអលង្ការ |
| ២ | ការចេញលិខិតអនុញ្ញាតបិទស្លាកថ្លៃជារូបិយប័ណ្ណបរទេស |
| **១២. វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** | |
| | **ក. សេវាសុរិយោដី និងភូមិសាស្ត្រ** |
| ១ | ការចុះបញ្ជីដីលើកដំបូង ដែលមានលក្ខណៈជាប្រព័ន្ធ(ក្នុង១ម $^{2}$) |
| ២ | ការចុះបញ្ជីដីលើកដំបូងមានលក្ខណៈដាច់ដោយដុំ និងចេញប័ណ្ណ(ក្នុង១ក្បាលដី) |
| ៣ | ការផ្ទេរអចលនវត្ថុទាំងមូល(ក្នុង១ប័ណ្ណ) |
| ៤ | ការបំបែកក្បាលដីដោយផ្ទេរ ឬដោយមិនផ្ទេរអចលនវត្ថុ(ក្នុង១ក្បាលដីដែលបំបែក) និងការបង្រួមក្បាលដី(ក្នុង១ក្បាលដីដើម) (តាមការស្នើសុំ) |
| ៥ | ការស្វែងរកចំណុចព្រំដីឡើងវិញ(ក្នុង១បង្គោល) |



២៥

| ល.រ | បរិយាយ |
| --- | --- |
| ៦ | ការចេញលិខិតបញ្ជាក់ព័ត៌មានសុរិយោដីក្នុង១ក្បាលដី( ការចេញលិខិតបញ្ជាក់ ការចេញសលាកប័ត្រព័ត៌មាន ការចេញលិខិតបញ្ជាក់សុរិយោដី ) |
| ៧ | ការដាក់បន្ទុក និងការលើកលែង ៖ ឯកសិទ្ធិ ការដាក់បញ្ចាំ និងការដាក់ហ៊ីប៉ូតែក (ក្នុង១ក្បាលដី ឬ១ប័ណ្ណ) |
| ៨ | ការថតចម្លងឯកសារសុរិយោដី( ក្នុង១ទំព័រក្រដាស់ A4 ) |
| ៩ | ការប្តូរប្រភេទដី( ក្នុង១ម²) |
| ១០ | ការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ( ក្នុង១ចំណែកឯកជន ) |
| ១១ | ការចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍( ក្នុង១ប័ណ្ណ) |
| ១២ | ការចុះបញ្ជីសិទ្ធិសម្បទានដីសេដ្ឋកិច្ច( ក្នុង១ប័ណ្ណ ) |
| ១៣ | ការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី( ក្នុង១ប័ណ្ណ ) |
| ១៤ | ផែនទីជាក្រដាស( ក្នុង១សន្លឹក ) |
| ១៥ | រូបថតអ័រតូហ្វូតូ ទំរង់ជាឌីជីថល( ក្នុង១គ.ម²) |
| ១៦ | រូបថតអ័រតូហ្វូតូទំរង់ជាក្រដាស( បោះពុម្ពជាក្រដាសខ្នាតA0) ក្នុង០១សន្លឹក |
| ១៧ | ទិន្នន័យបង្គោលប្រថពីវិភាគ( ប្លង់ទីតាំង និងនិយាមកា ) គិតក្នុង០១បង្គោល( តាមការស្នើសុំ ) |
| | **ខ. សេវាសំណង់** |
| ១ | លិខិតអនុញ្ញាតសាងសង់សំណង់លំនៅដ្ឋានដែលមានក្រឡាផ្ទៃសំណង់ទំហំ ≤៣០០០ម² |
| ២ | សំណង់អគារផ្សេងៗក្រៅពីលំនៅដ្ឋានដែលមានក្រឡាផ្ទៃសំណង់ទំហំ ≤៣០០០ម² |
| ៣ | សំណង់រដ្ឋ សំណង់សប្បុរសជន ឬអង្គការមនុស្សធម៌ អំណោយជូនសហគមន៍ ឬជនក្រីក្រ ដែលមានក្រឡាផ្ទៃសំណង់ទំហំ ≤៣០០០ម² |
| ៤ | ការផ្តល់គោលការណ៍សាងសង់ និងអភិវឌ្ឍន៍ដី |
| | **គ. ការចុះបញ្ជីសហគ្រាស-ក្រុមហ៊ុនប្រកបអាជីវកម្មសំណង់ រូបវន្តបុគ្គលសិក្សាគម្រោងប្លង់ និងក្រុមជាងសំណង់** |
| ១ | ចុះបញ្ជីលើកដំបូង និងបន្តសុពលភាពសម្រាប់ក្រុមជាងសំណង់ |
| | **ឃ. ការថតចម្លងឯកសារប្លង់ និងផែនទី (តាមការស្នើសុំ)** |
| ១ | ឯកសារស្នើសុំសាងសង់( ក្នុង១ច្បាប់ ) |
| ២ | ប្លង់ស្ថាបត្យកម្ម ឬប្លង់គ្រឿងផ្គុំសំណង់( ក្នុង១ច្បាប់) |
| ៣ | ផែនទី ទំហំ A-4( ក្នុង១សន្លឹក ) |
| ៤ | ផែនទី ទំហំ A-3( ក្នុង១សន្លឹក ) |
| ៥ | ផែនទី ទំហំ A-2( ក្នុង១សន្លឹក ) |
| ៦ | ផែនទី ទំហំ A-1( ក្នុង១សន្លឹក ) |
| ៧ | ផែនទី ទំហំ A-0( ក្នុង១សន្លឹក ) |
| | **ង. សេវាពិគ្រោះយោបល់លើផ្នែកច្បាប់ និងបច្ចេកទេស(តាមការស្នើសុំ)** |
| ១ | លើការងារទាក់ទងទៅនឹងដីធ្លី និងសំណង់ទូទៅ( សម្រាប់មួយករណី ) |

| ល.រ | បរិយាយ |
|---|---|
| **១៣. ទិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | |
| ១ | **ផលផល** |
| | - ចេញលិខិតអនុញ្ញាតធ្វើវារីវប្បកម្ម |
| ២ | **ផលិតកម្ម និងបសុព្យាបាល** |
| ២.១ | **ចេញលិខិតអនុញ្ញាតប្រមូលទិញសត្វនិងផលិតផលមានដើមកំណើតពីសត្វ "ប្រភេទ ខ"** |
| | - បង្កើតសត្តឃាតដ្ឋាន |
| | - ធ្វើអាជីវកម្មពិឃាតសត្វ |
| | - បង្កើតកន្លែងប្រមូលផ្តុំសត្វ |
| | - បង្កើតកន្លែងផលិត ឬលាយផ្សំចំណីសត្វ |
| | - បង្កើតកន្លែងផលិត កែច្នៃសាច់និងផលិតផលសត្វបឋម |
| | - បង្កើតកសិកដ្ឋានចិញ្ចឹមសត្វ |
| | - បង្កើតកន្លែងលក់សត្វកំដរ |
| | - បង្កើតកន្លែងពិនិត្យនិងព្យាបាលសត្វ |
| | - បង្កើតកន្លែងលក់បសុឱសថ និងសម្ភារៈ បរិក្ខាបសុពេទ្យ-ចំណីសត្វ |
| | - បង្កើតកន្លែងស្តុកនិងចែកចាយសាច់ |
| | - បង្កើតកន្លែងឃ្លាំងស្តុកស្បែកគោក្របី |
| ២.២ | **សោហ៊ុយសេវាកម្មត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ និងការប្រមូលកម្រៃសេវាកម្មត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វនៅសត្តឃាតដ្ឋាន "ចរាចរក្នុងផ្ទៃប្រទេស"** |
| | **សេវាត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វៈ** |
| | **ក. សត្វ** |
| | - សត្វចតុប្បាទស្រុកធំ(ពេញវ័យ)៖ គោ ក្របី សេះ...(ក្បាល) |
| | - សត្វចតុប្បាទស្រុកធំ(កូន)៖ គោ ក្របី សេះ...(ក្បាល) |
| | - សត្វចតុប្បាទតូច(ពេញវ័យ)៖ ជ្រូក ពពែ ចៀម...(ក្បាល) |
| | - សត្វចតុប្បាទតូច(កូន)៖ ជ្រូក ពពែ ចៀម...ចំពោះកូនជ្រូកមានទម្ងន់តិចជាង ៣០គ.ក្រ(ក្បាល) |
| | - បក្សីស្រុក(ពេញវ័យ)៖ មាន់ ទា មាន់បារាំង ក្រួច ...(ក្បាល) |
| | - បក្សី(កូន)៖ មាន់ ទា មាន់បារាំង ក្រួច ...ទម្ងន់តិចជាង ១៨៥ក្រាម(ក្បាល) |
| | - ស៊ុតបក្សីសម្រាប់ភ្ញាស់(ក្បាល) |
| | - ទឹកកាមសត្វ(កំរិត) |
| | - អំប្រ៊ីយ៉ុងសត្វ(ក្បាល) |
| | **ខ. សាច់ និងផ្នែកបន្ទាប់បន្សំដទៃទៀតរបស់សត្វដែលអាចបរិភោគបាន "ចរាចរក្នុងផ្ទៃប្រទេស"** |
| | - សាច់សត្វ ឬបក្សីទាំងមូល សាច់សត្វ ឬបក្សីពុះជា២ផ្លាំង សាច់សត្វ ឬបក្សីកាប់ជាដុំ សាច់ជាប់ឆ្អឹង សាច់កាប់ជាប់ឆ្អឹង សាច់សុទ្ធ(គ្មានជាប់ឆ្អឹង) និងផ្នែកបន្ទាប់បន្សំដទៃទៀត ស្រស់ ឬរក្សាទុកក្នុងទូត្រជាក់ ឬបង្កក(គ.ក្រ) |
| | - សាច់ងៀត សាច់ក្រក ម្សៅសាច់ ស្បែកជ្រូកក្រៀម(គ.ក្រ) |



២៥

| ល.រ | បរិយាយ |
|---|---|
| | - ខ្លាញ់សត្វគ្រប់ប្រភេទ មិនទាន់ចំរាញ់ នៅស្រស់ បង្កក ប្រឡាក់ ត្រាំទឹកអំបិល រាវ ឬ កក(គ.ក្រ) |
| | - ទឹកដោះស្រស់(លីត្រ) |
| | - ស៊ុតស្រស់ ប្រៃ កំណរកូន សម្ងួត ចំអិន និងបង្កក(គ្រាប់) |
| | **គ. ផលិតផលមានដើមកំណើតពីសត្វសម្រាប់ប្រើក្នុងផ្នែកផ្សេងៗ ដែលមិនអាចបរិភោគបាន "ចរាចរក្នុងផ្ទៃប្រទេស"** |
| | - ស្បែកស្រស់ប្រឡាក់អំបិល ឬ ស្ងួត(គ.ក្រ) |
| | - ផ្នែកបន្ទាប់បន្សំដទៃទៀតរបស់សត្វ ដូចជា ឈាមស្រស់ ម្សៅឈាម ឆ្អឹង ម្សៅឆ្អឹង...(គ.ក្រ) |
| | - ចំណីសត្វ(គ.ក្រ) |
| ២.៣ | **សេវាត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វនៅសត្តឃាតដ្ឋាន** |
| ២.៤ | **ប្រាក់រង្វាន់លើកទឹកចិត្តដល់មន្ត្រីដែលបានចូលរួមបង្ក្រាបបទល្មើសអនាម័យសត្វសាច់និងផលិតផលមានដើមកំណើតពីសត្វ** |
| | - ប្រាក់រង្វាន់បង្ក្រាបបទល្មើសអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ និងប្រាក់រង្វាន់បង្ក្រាបបទល្មើសអនាម័យសត្វ សាច់ និងផលិតផលសត្វនៅសត្តឃាតដ្ឋាន |
| ៣ | **នីតិកម្មកសិកម្ម** |
| ៣.១ | **កម្រៃសេវាកម្មលើការចេញលិខិតអនុញ្ញាតលក់ដុំលក់រាយថ្នាំកសិកម្ម ឬជីកសិកម្ម**<br>- កម្រៃលើការចេញលិខិតអនុញ្ញាតសម្រាប់ជីកសិកម្មតាមបរិមាណស្នើសុំធ្វើប្រតិបត្តិការប្រចាំឆ្នាំ<br>- កម្រៃលើការចេញលិខិតអនុញ្ញាតសម្រាប់ថ្នាំកសិកម្មតាមបរិមាណស្នើសុំធ្វើប្រតិបត្តិការប្រចាំឆ្នាំ<br>- ការស្នើសុំលិខិតអនុញ្ញាតលក់ដុំលក់រាយចម្រុះនូវថ្នាំកសិកម្ម និងជីកសិកម្ម |
| ៤ | **កម្រៃសេវាកម្មលើដំណើរការឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ សម្រាប់អ្នកផ្គត់ផ្គង់ចែកចាយ អ្នកលក់ដុំលក់រាយ និងប្រតិបត្តិការកម្ចាត់សមាសភាពចង្រៃ** |
| | - ដំណើរការឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ(ចេញវិញ្ញាបនបត្របញ្ជាក់ការឆ្លងវគ្គ) |
| **១៤. ទីស្តីការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** | |
| ១ | ការផ្តល់ប័ណ្ណការងារ និងសៀវភៅការងាររបស់ជនកម្ពុជា |
| ២ | ការចេញលិខិតទទួលស្គាល់ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក |
| ៣ | ការចុះបញ្ជិកាសំណុំបែបបទស្តីពីគ្រឹះស្ថាន |
| ៤ | លិខិតអនុញ្ញាតធ្វើការបន្ថែមម៉ោង |

## តារាងឧបសម្ព័ន្ធទី២

## សេវារដ្ឋបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ

## ភ្ជាប់នឹងអនុក្រឹត្យលេខ១៩៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០១៧

## ស្ដីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្ដល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

| ល.រ | បរិយាយ |
|---|---|
| **១. ការចារទីតាំងខុកុលកម្ម(ការបញ្ជាក់លើឯកសារថតចម្លង)** | |
| ១ | វិញ្ញាបនបត្របញ្ជាក់ការសិក្សា |
| ២ | វិញ្ញាបនបត្របណ្ដោះអាសន្ន មធ្យមសិក្សាកម្រិត១ |
| ៣ | វិញ្ញាបនបត្របណ្ដោះអាសន្ន មធ្យមសិក្សាកម្រិត២ |
| ៤ | វិញ្ញាបនបត្របណ្ដោះអាសន្ន មធ្យមសិក្សាបឋមភូមិ |
| ៥ | វិញ្ញាបនបត្របណ្ដោះអាសន្ន មធ្យមសិក្សាទុតិយភូមិ |
| ៦ | វិញ្ញាបនបត្របញ្ជាក់ការសិក្សាថ្នាក់ទី១២ |
| ៧ | វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម |
| ៨ | វិញ្ញាបនបត្រប្រកបអាជីវកម្ម |
| ៩ | ប័ណ្ណប៉ាតង់ |
| ១០ | វិញ្ញាបនបត្រ |
| ១១ | លិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជី |
| ១២ | លិខិតបញ្ជាក់លទ្ធផលនៃការប្រលងសញ្ញាបត្រមធ្យមសិក្សាកម្រិត១ |
| ១៣ | សញ្ញាបត្រមធ្យមសិក្សាកម្រិត២ (បំពេញវិជ្ជា) |
| ១៤ | សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ |
| ១៥ | សញ្ញាបត្រមធ្យមសិក្សាគរុកោសល្យ |
| ១៦ | សញ្ញាបត្រមធ្យមសិក្សា |
| ១៧ | សញ្ញាបត្រគ្រូបង្រៀនកម្រិតឧត្ដម |
| ១៨ | ព្រឹត្តិបត្រលទ្ធផលប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ |
| ១៩ | បរិញ្ញាបត្រ |
| ២០ | បរិញ្ញាបត្ររង |
| ២១ | លិខិតបញ្ជាក់ការសិក្សា |
| ២២ | អត្តសញ្ញាណប័ណ្ណ |
| ២៣ | សៀវភៅស្នាក់នៅ/សៀវភៅគ្រួសារ |
| ២៤ | ប័ណ្ណសំគាល់យានយន្ត |
| ២៥ | ប័ណ្ណបើកបររថយន្ត |



25

| ល.រ | បរិយាយ |
|---|---|
| ២៦ | ព្រឹត្តិបត្រពិន្ទុ |
| ២៧ | ពាក្យសុំបញ្ជាក់សញ្ញាបត្រមធ្យមសិក្សាកម្រិត២ ចំណេះដឹងទូទៅ |
| ២៨ | វិញ្ញាបនបត្របណ្ដោះអាសន្នថ្នាក់បរិញ្ញាបត្រ |
| ២៩ | វិញ្ញាបនបត្របណ្ដោះអាសន្នថ្នាក់បរិញ្ញាបត្ររង |
| **២. ការងាររដ្ឋបាល** | |
| ១ | ការចេញលិខិតអនុញ្ញាតបំពេញអាចម៍ដីកម្មសិទ្ធិឯកជនក្រោម១០០០ម៉ែត្រការ៉េ |
| **៣. ការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលពុំទាន់ចុះបញ្ជី** | |
| ១ | ដី |
| | - ដីក្នុងរាជធានីភ្នំពេញ ឬក្នុងក្រុងនៃខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប |
| | - ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប |
| | - ដីក្រៅក្រុង ឬជនបទ |
| ២ | លំនៅដ្ឋាន(ក្រៅពីភូមិគ្រឹះ) |
| | - ដីក្នុងរាជធានីភ្នំពេញ ឬក្នុងក្រុងនៃខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប |
| | - ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប |
| | - ដីក្រៅក្រុង ឬជនបទ |
| ៣ | ភូមិគ្រឹះ |
| | - ដីក្នុងរាជធានីភ្នំពេញ ឬក្នុងក្រុងនៃខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប |
| | - ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប |
| | - ដីក្រៅក្រុង ឬជនបទ |
| **៤. ការងារអត្រានុកូលដ្ឋាន** | |
| ១ | សេចក្ដីចម្លងសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត |
| ២ | សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ |
| ៣ | សេចក្ដីចម្លងសំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាព |
| **៥. វិស័យអប់រំ យុវជន និងកីឡា** | |
| ១ | អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតបើក បន្តសុពលភាពសាលា ឬថ្នាក់មត្តេយ្យសិក្សាឯកជន(កម្មវិធីជាតិ) |
| ២ | អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតបើក បន្តសុពលភាពសាលា ឬថ្នាក់មត្តេយ្យសិក្សាឯកជន(កម្មវិធីអន្តរជាតិ) |
| ៣ | អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតបើក បន្តសុពលភាពថ្នាក់បណ្ដុះបណ្ដាលជំនាញ និងភាសាបរទេសវគ្គខ្លីៗ តិចជាង១ឆ្នាំ |
| ៤ | អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតបើក បន្តសុពលភាពក្លឹបហាត់ប្រាណ |
| ៥ | អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតបើក បន្តសុពលភាពអាជីវកម្មលក់សម្ភារៈកីឡា |
| **៦. វិស័យសុខាភិបាល** | |
| ១ | លិខិតអនុញ្ញាតស្នើសុំបើកថ្មី បន្តសុពលភាព និងប្ដូរទីតាំងបន្ទប់ពិនិត្យស្ត្រីមានផ្ទៃពោះមុន និងក្រោយសម្រាល |



៩៤

| ល.រ | បរិយាយ |
|---|---|
| ២ | លិខិតអនុញ្ញាតស្នើសុំបើកថ្មី បន្តសុពលភាព និងប្តូរទីតាំងបន្ទប់ព្យាបាលដោយចលនា |
| ៣ | លិខិតអនុញ្ញាតស្នើសុំបើកថ្មី បន្តសុពលភាព និងប្តូរទីតាំងបន្ទប់ថែទាំជម្ងឺ |
| ៤ | លិខិតអនុញ្ញាតស្នើសុំបើកថ្មី បន្តសុពលភាព និងប្តូរឈ្មោះឱសថការីនៃឱសថស្ថានរង **ក** |
| ៥ | លិខិតអនុញ្ញាតបន្តសុពលភាពឱសថស្ថានរង **ខ** |
| ៦ | លិខិតអនុញ្ញាតស្នើសុំបើកថ្មី បន្តសុពលភាព និងប្តូរទីតាំងបន្ទប់ពិគ្រោះព្យាបាលជំងឺមាត់ធ្មេញ |
| ៧ | លិខិតអនុញ្ញាតស្នើសុំបើកថ្មី បន្តសុពលភាព និងប្តូរទីតាំងបន្ទប់ពិគ្រោះជំងឺទូទៅ |
| ៨ | ការផ្តល់វិញ្ញាបនបត្របញ្ជាក់អនាម័យចំណីអាហារតាមភោជនីយដ្ឋាន និងអាហារដ្ឋានដែលមានចំណុះចាប់ពី៥០កៅអីចុះក្រោម |
| **៧. វិស័យទេសចរណ៍** | |
| ១ | ផ្ទះសំណាក់ចាប់ពី០៨បន្ទប់ ចុះក្រោម |
| ២ | ផ្ទះជួលបន្ទប់ស្នាក់នៅ |
| ៣ | ភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ ចាប់ពី៥០នាក់ ចុះក្រោម |
| ៤ | ភោជនីយដ្ឋាន និងអាហារដ្ឋានក្នុងស្រុក |
| ៥ | តូបលក់អាហារ |
| ៦ | ហាងលក់គុយទាវ កាហ្វេ |
| ៧ | ម៉ាស្សា ចាប់ពី០៥គ្រែ ឬចាប់ពី០៥កៅអី ចុះក្រោម |
| ៨ | ខារ៉ាអូខេ ចាប់ពី០៥បន្ទប់ ចុះក្រោម |
| ៩ | ស្នូកឃ័រ ចាប់ពី០៥តុ ចុះក្រោម |
| ១០ | រថយន្តដឹកទេសចរណ៍ ចំណុះចាប់ពី០៥កៅអី ចុះក្រោម |
| ១១ | ម៉ូតូឌុបទេសចរណ៍ |
| ១២ | ម៉ូតូជួលទេសចរណ៍ |
| ១៣ | រ៉ឺម៉កម៉ូតូដឹកទេសចរណ៍ |
| **៨. វិស័យដឹកជញ្ជូន** | |
| ១ | **សេវាកម្មម៉ូតូ** |
| | - ចុះបញ្ជីថ្មី |
| | - ប្តូរប័ណ្ណសម្គាល់ (ពណ៌ លេខម៉ាស៊ីន) |
| | - ទុតិយតាប័ណ្ណសម្គាល់ |
| | - តតិយតាប័ណ្ណសម្គាល់ |
| | - ទុតិយតាស្លាកលេខ |
| | - តតិយតាស្លាកលេខ |
| ២ | **សេវាកម្មត្រីចក្រយានយន្ត ឬរ៉ឺម៉ក** |
| | - ចុះបញ្ជីត្រីចក្រយានយន្ត |
| | - ចុះបញ្ជីរ៉ឺម៉ក(ទោចក្រយានយន្ត) |



៦

| ល.រ | បរិយាយ |
|---|---|
| | - ប្តូរ ទុតិយតា ឬតតិយតាប័ណ្ណសម្គាល់ត្រីចក្រយានយន្ត |
| | - ប្តូរ ទុតិយតា ឬតតិយតាផ្លាកលេខត្រីចក្រយានយន្ត |
| ៣ | **ការត្រួតពិនិត្យលក្ខណបច្ចេកទេសត្រីចក្រយានយន្ត** |
| | - ត្រីចក្រយានយន្ត ឬទោចក្រយានយន្តសណ្តោងរ៉ឺម៉ក |
| | - ទុតិយតា ឬតតិយតា វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណបច្ចេកទេស |
| ៤ | **ត្រីចក្រយានយន្ត ឬ ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក** |
| | - ការផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន |
| | - ត្រីចក្រយានយន្ត |
| ៥ | **រ៉ឺម៉កសណ្តោងដោយទោចក្រយានយន្ត** |
| | - ការបន្តលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន |
| | - ត្រីចក្រយានយន្ត |
| ***៩. វិស័យវប្បធម៌ និងវិចិត្រសិល្បៈ*** | |
| ១ | **កម្មវិធីសម្តែងផ្សេងៗ (ក្រៅផ្លូវការ)** |
| | - ការប្រគំតន្ត្រីនៅទីសាធារណៈលក្ខណៈជាតិ |
| | - ការសម្តែងទស្សនីយភាពល្ខោន លក់សំបុត្រ |
| | - ការសម្តែងល្ខោនគ្រប់ទម្រង់ |
| | - អាជីវកម្មរាំកំសាន្ត លក់សំបុត្រ |
| ២ | **ការបញ្ចាំងភាពយន្ត វីដេអូ** |
| | - ការបញ្ចាំងភាពយន្ត វីដេអូ ផ្សាយពាណិជ្ជកម្ម |
| | - ការបញ្ចាំងភាពយន្ត វីដេអូ កំដរពិធីបុណ្យផ្សេងៗ |
| | - ការបញ្ចាំងភាពយន្ត វីដេអូ កំដរភ្ញៀវ |
| ៣ | **អាជីវកម្មលក់ ជួលស្នាដៃភាពយន្ត វីដេអូ** |
| | - ហាងលក់ ជួលស៊ីឌី វីស៊ីឌី ឌីវីឌី |
| | - អគារលក់ស៊ីឌី វីស៊ីឌី ឌីវីឌី |
| ៤ | **ស្លាកសញ្ញាអាជីវកម្ម** |
| | - ផ្ទាំងយីហោគ្រប់ប្រភេទ ទំហំក្រោម២ម៉ែត្រការ៉េ |
| | - ផ្ទាំងយីហោគ្រប់ប្រភេទ ទំហំចាប់ពី២ម៉ែត្រការ៉េ ដល់៤ម៉ែត្រការ៉េ |
| | - ប័ណ្ណប្រកាសផ្សាយពាណិជ្ជកម្ម(Poster) |
| | - ផ្ទាំងរូបភាព និមិត្តសញ្ញាផ្សេងៗ ទំហំក្រោម២ម៉ែត្រការ៉េ |
| | - ផ្ទាំងរូបភាព និមិត្តសញ្ញាផ្សេងៗ ទំហំចាប់ពី២ម៉ែត្រការ៉េ ដល់៤ម៉ែត្រការ៉េ |
| | - បដាផ្សាយពាណិជ្ជកម្ម |
| ៥ | **ការផ្តល់អាជ្ញាប័ណ្ណ** |
| | - ផលិតស្លាកសញ្ញា ផ្ទាំងសញ្ញា ផ្ទាំងផ្សាយពាណិជ្ជកម្ម |
| ៦ | **អាជីវកម្មគ្រឿងបំពងសំឡេង** |
| | - ជួលធុងបាស់ និងឧបករណ៍សនសព្ទ |



៩៥

| ល.រ | បរិយាយ |
| --- | --- |
| ៧ | **អាជីវកម្មលក់សៀវភៅ** |
| | - បណ្ណាគារដែលមានផ្ទៃក្រឡាក្រោម៥០ម៉ែត្រការ៉េ |
| ៨ | **អាជីវកម្មសិល្បៈសូនរូប** |
| | - ទីតាំងផលិត និងលក់ចម្លាក់ ពុម្ពស៊ីម៉ងត៍ |
| | - ទីតាំងផលិត លក់ចម្លាក់ម្នាងសិលា |
| | - ជាងគំនូរ |
| ៩ | **អាជីវកម្មថតរូប** |
| | - អគារផ្តិតរូប ថតរូប ថតវីដេអូ |
| | - ផ្ទះថតរូប ផ្តិតរូប ថតវីដេអូ |
| ១០ | **អាជីវកម្មកាត់សក់ អ៊ុតសក់ លម្អក្រចក និងសម្អាងការ (ហាង)** |
| | - កាត់សក់បុរស( ចាប់ពី២កៅអី ទៅ៤កៅអី ) |
| | - កាត់សក់បុរស( ចាប់ពី៥កៅអី ឡើងទៅ ) |
| | - អ៊ុតសក់ កាត់សក់ លម្អក្រចក( ចាប់ពី២កៅអី ទៅ៤កៅអី ) |
| | - អ៊ុតសក់ កាត់សក់ លម្អក្រចក( ចាប់ពី៥កៅអី ឡើងទៅ ) |
| | - សម្អាងការ( ថ្លៃឈ្នួលក្រោម៥០០ដុល្លារអាមេរិក ) |
| | - សម្អាងការ( ថ្លៃឈ្នួលចាប់ពី៥០០ដុល្លារអាមេរិក ដល់ក្រោម១ ០០០ដុល្លារអាមេរិក ) |
| | - សម្អាងការ( ថ្លៃឈ្នួលចាប់ពី១ ០០០ដុល្លារអាមេរិកឡើងទៅ ) |
| **១០. វិស័យឧស្សាហកម្ម និងសិប្បកម្ម និងវិស័យរ៉ែ និងថាមពល** | |
| ១ | **ចុះបញ្ជីសិប្បកម្ម** |
| | - កែច្នៃក្រណាត់ ស្បែក កៅស៊ូ ប្លាស្ទិក |
| | - កែច្នៃស័ង្កសី អាលុយមីញ៉ូម ដែក កញ្ចក់ |
| | - កែច្នៃគេនវត្ថុ |
| | - ផលិតជើងតាង ពាង លូ ឥដ្ឋការ៉ូ |
| | - ធ្វើទៀន ធូប |
| ២ | **ថាមពល** |
| | - ដំឡើងម៉ាស៊ីនអគ្គិសនីសម្រាប់ធ្វើសេវាកម្មបញ្ចូលអាគុយដែលមានកម្លាំងមិនលើសពី២៥គីឡូវ៉ាត់ (25KW) |
| ៣ | **សេវាកម្ម** |
| | - ជួសជុលគ្រឿងអគ្គិសនីអេឡិចត្រូនិក |
| | - លាងរថយន្ត ម៉ូតូ |
| | - លាងម៉ូតូ |
| **១១. វិស័យពាណិជ្ជកម្ម** | |
| | - លិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្មពាណិជ្ជកម្ម |



6

| ល.រ | បរិយាយ |
|---|---|
| **១២. វិស័យសំណង់** | |
| ១ | លិខិតអនុញ្ញាតសាងសង់ដែលមានក្រឡាផ្ទៃសំណង់ទំហំ ≤៥០០ម២ |
| ២ | លិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែម រុះរើ ជួសជុលដែលមានក្រឡាផ្ទៃសំណង់ទំហំ ≤៥០០ម២ |
| ៣ | លិខិតអនុញ្ញាតបើកការដ្ឋានដែលមានក្រឡាផ្ទៃសំណង់ទំហំ ≤៥០០ម២ |
| ៤ | លិខិតបិទការដ្ឋាន ឬវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវដែលមានក្រឡាផ្ទៃសំណង់ទំហំ ≤៥០០ម២ |
| ៥ | សេវាកម្ម ជួសជុល និងសាងសង់របង(របងថ្ម/បេតុង) |
| **១៣. វិស័យកសិកម្ម** | |
| ១ | លិខិតអនុញ្ញាតធ្វើអាជីវកម្មលក់ដុំ រាយ សម្ភារៈកសិកម្ម |
| ២ | វិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ |

# ឧបសម្ព័ន្ធទី ៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២១៥អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ២១៦អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត និងក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារនិងធនធានឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងសេចក្តីសម្រេចលេខ១២សសរ របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ស្រុក ខណ្ឌ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងធានានូវការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយគុណភាព តម្លាភាព ប្រសិទ្ធភាព និងឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងធុរជន។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់គោលការណ៍ យន្តការ បែបបទ នីតិវិធី ប្រភេទសេវា រយៈពេល និងកម្រៃនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី២

## គោលការណ៍នៃការផ្តល់សេវារដ្ឋបាល

**មាត្រា ៤.-**

ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវផ្អែកលើគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីធានាឲ្យបាននូវតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព សមធម៌ និរន្តរភាព និងការចូលរួមរបស់ប្រជាពលរដ្ឋ និងធុរជននានា។

**មាត្រា ៥.-**

វិធាន បែបបទ នីតិវិធីនៃការផ្ដល់សេវា និងកម្រៃសេវាត្រូវអនុវត្តទៅតាមការកំណត់នៃច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ៦.-**

ប្រភេទសេវា កម្រៃ រយៈពេលនៃការផ្ដល់សេវា និងសុពលភាពនៃសេវារដ្ឋបាលដែលជារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រភេទសេវា កម្រៃ រយៈពេលនៃការផ្ដល់សេវា និងសុពលភាពនៃសេវារដ្ឋបាលដែលធ្វើប្រតិភូកម្មពីក្រសួង ស្ថាប័ននានាដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ស្ថាប័នសាមី។

**មាត្រា ៧.-**

ការផ្ដល់សេវារដ្ឋបាល និងការយកកម្រៃលើការផ្ដល់សេវារដ្ឋបាល ដែលពុំស្របតាមវិធាន បែបបទ នីតិវិធីនៃច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ចាត់ទុកជាអំពើខុសច្បាប់។

## ជំពូកទី៣
## យន្តការនៃការផ្ដល់សេវារដ្ឋបាល

**មាត្រា ៨.-**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវរៀបចំឲ្យមានយន្តការនៃការផ្ដល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋ និងធុរជន ស្របតាមគោលការណ៍នៃការផ្ដល់សេវារដ្ឋបាលដូចបានកំណត់នៅក្នុងជំពូកទី២នៃអនុក្រឹត្យនេះ។

**មាត្រា ៩.-**

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានយន្តការផ្ដល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយត្រូវបន្តអនុវត្តតាមយន្តការនេះ។

**មាត្រា ១០.-**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ដែលពុំទាន់មានយន្តការផ្ដល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយ ត្រូវរៀបចំឲ្យមានយន្តការច្រកចេញចូលតែមួយសម្រាប់ផ្ដល់សេវារដ្ឋបាលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ការរៀបចំ និងការប្រព្រឹត្តទៅនៃយន្តការផ្ដល់សេវារដ្ឋបាលតាមច្រកចេញចូលតែមួយសម្រាប់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ទាំងនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីមានការសម្រេចរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប)។

## ជំពូកទី៤

## ប្រភេទសេវា កម្រៃ រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាល

**មាត្រា ១១.-**

រដ្ឋបាលរាជធានី ខេត្ត ត្រូវផ្តល់សេវារដ្ឋបាលរបស់ខ្លួន តាមប្រភេទសេវា កម្រៃ រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាលដែលកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ១២.-**

រដ្ឋបាលរាជធានី ខេត្ត ត្រូវផ្តល់សេវារដ្ឋបាលដែលទទួលបានប្រតិភូកម្មពីក្រសួង ស្ថាប័ននានាតាមប្រភេទសេវា កម្រៃ រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាលដែលកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ស្ថាប័នសាមីនីមួយៗ។

អភិបាលរាជធានី ខេត្ត ត្រូវបានទទួលអំណាចប្រតិភូកម្មក្នុងនាមរដ្ឋមន្ត្រីក្រសួង ស្ថាប័នសាមីក្នុងការចុះហត្ថលេខាសម្រេចលើការផ្តល់សេវារដ្ឋបាលដែលស្ថិតក្នុងសមត្ថកិច្ចរបស់មន្ទីរ អង្គភាពនានាដូចដែលបានកំណត់ក្នុងប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ស្ថាប័នសាមី។

ក្រសួង ស្ថាប័ននានាត្រូវបន្តបែងចែកសមត្ថកិច្ចសម្រេចក្នុងការផ្តល់សេវារដ្ឋបាលទៅឲ្យរដ្ឋបាលរាជធានី ខេត្ត ដើម្បីបង្ខិតសេវារដ្ឋបាលឲ្យទៅជិតអ្នកប្រើប្រាស់សេវា។

ក្នុងការអនុវត្តអំណាចប្រតិភូកម្មពីក្រសួង ស្ថាប័ននានា មន្ទីរ អង្គភាពជំនាញនៅថ្នាក់រាជធានី ខេត្ត ត្រូវធ្វើជាសេនាធិការជូនអភិបាលរាជធានី ខេត្តលើការងារនេះ។

ការបង់កម្រៃសេវារដ្ឋបាលដែលជារបស់រដ្ឋបាលរាជធានី ខេត្ត ត្រូវធ្វើឡើងនៅសាលារាជធានី ខេត្ត។

ក្នុងករណីចាំបាច់ គ.ជ.អ.ប ត្រូវ ធ្វើការសម្របសម្រួលនៅក្នុងការបែងចែកសមត្ថកិច្ចនេះ។

**មាត្រា ១៣.-**

រដ្ឋបាលក្រុង ស្រុក ខណ្ឌដែលមានយន្តការផ្តល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយត្រូវបន្តផ្តល់នូវប្រភេទសេវារដ្ឋបាលដែលបានធ្វើប្រតិភូកម្មដោយក្រសួង ស្ថាប័ននានារួចហើយ។ កម្រៃសេវា រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាល ត្រូវអនុវត្តតាមការកំណត់ក្នុងប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ស្ថាប័នសាមី។

**មាត្រា ១៤.-**

រដ្ឋបាលក្រុង ស្រុក ខណ្ឌដែលមិនទាន់មានយន្តការផ្តល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយ ត្រូវបានអនុញ្ញាតឲ្យផ្តល់សេវារដ្ឋបាល តាមប្រភេទសេវា កម្រៃ រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាលស្របតាមប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ស្ថាប័នសាមីនីមួយៗ ដូចរដ្ឋបាលក្រុង ស្រុកដែលមានការិយាល័យច្រកចេញចូលតែមួយដែរ។

ក្រសួង ស្ថាប័ននានាត្រូវបន្តធ្វើប្រតិភូកម្មការផ្តល់សេវារដ្ឋបាលទៅឲ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីបង្ខិតសេវារដ្ឋបាលឲ្យទៅជិតអ្នកប្រើប្រាស់សេវា។

អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវបានទទួលអំណាចប្រតិភូកម្មក្នុងនាមរដ្ឋមន្ត្រីក្រសួង ស្ថាប័នសាមី

ក្នុងការចុះហត្ថលេខាសម្រេចលើការផ្តល់សេវារដ្ឋបាល ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើនេះ។

ការិយាល័យ ឬនិងមន្ទីរ អង្គភាពជំនាញនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើជាសេនាធិការជូនអភិបាលក្រុង ស្រុក ខណ្ឌលើការងារនេះ។

ក្នុងករណីចាំបាច់ គ.ជ.អ.ប ត្រូវ ធ្វើការសម្របសម្រួលនៅក្នុងការបែងចែកសមត្ថកិច្ចនេះ។

**មាត្រា ១៥.-**

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានអនុញ្ញាតឲ្យផ្តល់សេវារដ្ឋបាលរបស់ខ្លួន តាមប្រភេទសេវា កម្រៃ រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាលដែលកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ការបង់កម្រៃសេវាដែលជារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើឡើងនៅសាលាក្រុង ស្រុក ខណ្ឌ។

**មាត្រា ១៦.-**

រដ្ឋបាលឃុំ សង្កាត់ ត្រូវផ្តល់សេវារដ្ឋបាលតាមប្រភេទសេវា កម្រៃ រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាលដែលពាក់ព័ន្ធនឹងសេវាអត្រានុកូលដ្ឋាន និងលិខិតអនុញ្ញាតមួយចំនួនដែលមិនមែនជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ប្រភេទសេវា កម្រៃ រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាលរបស់រដ្ឋបាលឃុំ សង្កាត់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៧.-**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ អាចស្នើធ្វើការកែសម្រួល បំពេញបន្ថែម ប្រភេទសេវា កម្រៃ រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាលដែលបានកំណត់រួច បន្ទាប់ពីមានការសម្រេចរបស់ក្រុមប្រឹក្សានៃថ្នាក់រដ្ឋបាលរបស់ខ្លួន។

សំណើខាងលើនេះត្រូវសម្រេចដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ១៨.-**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវបិទផ្សាយជាសាធារណៈនូវតារាងប្រភេទសេវា កម្រៃ រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាលនៅកន្លែងផ្តល់សេវារដ្ឋបាលលើក្តារព័ត៌មានរបស់ថ្នាក់រដ្ឋបាលនីមួយៗ និងតាមមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងៗទៀត។

**មាត្រា ១៩.-**

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃផ្អែកតាមការសម្រេចរបស់ គ.ជ.អ.ប អាចដាក់ចេញនូវសេចក្តីណែនាំអំពីវិធាន បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យការផ្តល់សេវារដ្ឋបាលនានាកាន់តែមានប្រសិទ្ធភាព។

## ជំពូកទី៥
## ការគ្រប់គ្រង និងការបែងចែកចំណូលដែលបានមកពីការផ្តល់សេវារដ្ឋបាល

**មាត្រា ២០.-**

រាល់ការប្រមូលកម្រៃសេវារដ្ឋបាលនានា មន្ត្រីទទួលបន្ទុកផ្តល់សេវារដ្ឋបាលត្រូវមានបង្កាន់ដៃប្រគល់ទទួលប្រាក់ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

អង្គភាពផ្តល់សេវារដ្ឋបាលត្រូវរក្សាទុកគល់បញ្ជី បង្កាន់ដៃទទួលប្រាក់តាមខែ និងតាមឆ្នាំនីមួយៗក្នុងអង្គភាពរបស់ខ្លួនតាមគោលការណ៍កំណត់។

**មាត្រា ២១.-**

ចំណូលដែលទទួលបានពីកម្រៃនៃការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់នីមួយៗ ត្រូវបង់ចូលថវិកាថ្នាក់ជាតិ ឬនិងថវិកាថ្នាក់ក្រោមជាតិតាមគោលការណ៍កំណត់។

ប្រាក់រង្វាន់លើកទឹកចិត្តដល់មន្ត្រីដែលបំពេញការងារនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ២២.-**

ប្រាក់រង្វាន់លើកទឹកចិត្តដែលបានមកពីកម្រៃនៃការផ្តល់សេវារដ្ឋបាលរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញខ្សែបណ្តោយនានា និងប្រាក់រង្វាន់លើកទឹកចិត្តពីកម្រៃនៃការផ្តល់សេវារដ្ឋបាលដែលបានធ្វើប្រតិភូកម្ម ត្រូវធ្វើការបែងចែកដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ សម្រាប់លើកទឹកចិត្តដល់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ តាមការកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយផ្អែកតាមការសម្រេចរបស់ គ.ជ.អ.ប។

## ជំពូកទី៦
## យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

**មាត្រា ២៣.-**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវរៀបចំបង្កើតឲ្យមានប្រព័ន្ធតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងដោះស្រាយភាពមិនប្រក្រតីក្នុងការផ្តល់សេវារដ្ឋបាលនៅថ្នាក់រដ្ឋបាលរបស់ខ្លួន។

ក្រសួងមហាផ្ទៃ ត្រូវធ្វើការណែនាំអំពីបែបបទ និងនីតិវិធីនៃការរៀបចំបង្កើតប្រព័ន្ធនេះ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា ២៤.-**

ត្រូវទុកជានិរាករណ៍នូវអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការកំណត់ថ្លៃជាវក្រដាសអត្រានុកូលដ្ឋាន និងថ្លៃតែមប្រឹសារពើពន្ធ។

ថ្លៃជាវក្រដាសអត្រានុកូលដ្ឋាន និងកម្រៃសេវាលើការចុះបញ្ជីអត្រានុកូលដ្ឋានត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា ២៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ២៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីជម្រាបជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

| | |
|---|---|
| **រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** | **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** |
| **ស ខេង** | **គាត ឈន់** |

**<u>កន្លែងទទួល</u>** ÷

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា២៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*